01249420



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Jun-2016, 13:34
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦**

**ម៉ោង ០៨:៥៩នាទី**

**សវនាការលើកទី៤០៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា អេវេលីន ខាំផូស សង់ចេស
*(Ms. Evelyn CAMPOS SANCHEZ)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ដេត វណ្ណលី | ខ្មែរ |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ប្រាក់ ខន (2-TCW-931) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ថ្នាក់ ខន** (2-TCW-931)

សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្ដើមពី ..... ទំព័រ ២
សួរដោយលោកស្រី ជេត វណ្ណលី ផ្ដើមពី ..... ទំព័រ ៩
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ..... ទំព័រ ១៩
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ..... ទំព័រ ២៨
សួរដោយលោក ប្រធានអង្គជំនុំ ផ្ដើមពី ..... ទំព័រ ៦២
សួរបន្តដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ..... ទំព័រ ៧៦

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៥៩:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ប្រាក់ ខន ហើយនិងអាចនឹងផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលបម្រុងមួយរូប ប្រសិនបើពេលវេលាមានអំណោយផល។

ហើយក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមានអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ ដោយលោក ស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោក ប្រាក់ ខន។ លោក និងមេធាវីប្រឹក្សា លោក ម៉ក វិទ្ធា មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការ។ ហើយនៅថ្ងៃនេះ មិនមានសាក្សីបម្រុងនោះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន និងមិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខ ឱ្យ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ នៅថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាព ជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺខ្នង ឈឺចង្កេះរុំារ៉ៃ អង្គុយយូរមិនបាន និងវិលមុខ និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ស្ថិតនៅក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន ៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០២:២២]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការនៅក្នុងអំឡុងពេលកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ ដូចដែលបានសន្យាកាលពីម្សិលមិញ ខ្ញុំនឹងសួរសំណួរក្នុងរយៈពេល១៥នាទីទៀត។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរលោកសាក្សី កាលពីម្សិលមិញ មុនពេលឈប់សម្រាកយើងនិយាយអំពីអ្នកទោសវៀតណាម <គឺអ្នកទោសដែលបាននៅស-២១>នៅឆ្នាំ៧៧, ៧៨<>។ លោក<បាន>និយាយថា គេមានរៀបចំកំណត់ត្រាមួយ ហើយកំណត់ត្រានេះ ត្រូវបាន<អាន។ ខ្ញុំមិនដឹងថា តើគេត្រូវ>ឲ្យអ្នក

ទោសវៀតណាមអាន<ឬយ៉ាងណានោះទេ>។ ខ្ញុំដូចជាយល់មិនសូវច្បាស់ដែរកាលពីម្សិលមិញហ្នឹង។ ដូច្នេះ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចអំពី<បញ្ហានេះបានទេ ហើយសូមប្រាប់មើល តើអ្វីជា> គោលបំណងនៃការសួរចម្លើយអ្នកទោសវៀតណាម? ហេតុអីបានជាគេសួរចម្លើយអ្នកទោសវៀតណាម ហើយគេចង់បានអ្វីពីអ្នកទោសវៀតណាមនោះ បានជាគេសួរចម្លើយអីចឹង?

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ អ្នកទោសវៀតណាមដែលគេចង់បានចម្លើយពេលនោះ គឺឲ្យឆ្លើយទៅតាមការរៀបរាប់និងប្រាប់តាមរបស់ ចាន់ ហៅ ម៉ម ណៃ ហៅ ចាន់។ គាត់មានការព្រៀងទុកមួយដើម្បីឲ្យអ្នកទោសហ្នឹងនិយាយតាមការព្រៀងទុករបស់គាត់ ដែលពាក្យសារភាពបានចូលមកទឹកដីខ្មែរដោយស៊ើបការណ៍មួយក៏ដោយមានបំណងយ៉ាងម៉េចៗ គាត់នឹងផ្សាយទៅឲ្យខាងប្រទេសវៀតណាមហ្នឹងឮវិញ ថាបានកងទ័ពកម្ពុជាប្រជាធិបតេយ្យចាប់បាននៅថ្ងៃណា ខែណា ឆ្នាំណា ឥឡូវហ្នឹងបានចូលមកសារភាពនៅរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹងគោលបំណងរបស់ ចាន់ និង ឌុច កាលហ្នឹង គឺចង់ឲ្យខាងកង -- ខាងប្រទេសវៀតណាមហ្នឹងស្ដាប់ឮសំឡេងដែលសារភាពវិញ។

**ស៖** នៅក្នុងចម្លើយសារភាពដែលរៀបចំដោយ ចាន់ <និង> ឌុច នេះ តើឈ្មោះ និងមុខងាររបស់អ្នកទោសវៀតណាមទាំងអស់ហ្នឹងមានភាពត្រឹមត្រូវទេ?

[០៩:០៥:៣៣]

**ឆ៖** បាទ ឈ្មោះ គឺត្រឹមត្រូវតាមការសារភាពរបស់អ្នកទោស ហើយមុខងារហ្នឹងខ្លះក៏ជាកងទ័ព ខ្លះជាក៏ជាប្រជាជន។ អាហ្នឹងតាមជាក់ស្ដែងនីមួយៗ គឺរៀបរាប់តាមហ្នឹង។

**ស៖** ចុះខ្លួនលោកផ្ទាល់ លោកបានស្ដាប់ឮការផ្សាយចម្លើយសារភាពហ្នឹងទេ គឺចម្លើយសារភាពដែលបានមកពី<ពួក>អ្នកទោសវៀតណាម<នៅស-២១>នោះ? ពេលដែលគេផ្សាយ<ចម្លើយសារភាពទាំងនោះ>តាមវិទ្យុហ្នឹង លោកបានស្ដាប់ឮដោយខ្លួនឯងផ្ទាល់ទេ?

**ឆ៖** បាទ ពាក្យសារភាពហ្នឹងគឺនៅវេលាម៉ោងប្រាំពីរព្រឹក តែងតែចាក់ផ្សាយរាល់ថ្ងៃនៅតាមវិទ្យុ ហើយនិងផ្សាយជាភាសាវៀតណាមហើយបកប្រែជាភាសាខ្មែរថែមទៀត។

**ស៖** តើ ចាន់ និង ឌុច ធ្វើយ៉ាងម៉េចដើម្បីឲ្យអ្នកទោសវៀតណាមហ្នឹងយល់ព្រមអានចម្លើយសារភាពនោះ? គាត់ប្រើល្បិចបោកបញ្ឆោត ឬក៏ប្រើអំពើហិង្សា ឬមួយក៏បញ្ចុះបញ្ចូល?

**ឆ៖** កន្លងមកឃើញគាត់ប្រើវិធីបញ្ចុះបញ្ចូល និងបោកបញ្ឆោតរួមផ្សំ ដើម្បីឲ្យអ្នកទោសហ្នឹង

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ព្រមនិយាយ ព្រមអានទៅតាមការរៀបរៀងរបស់គាត់។

**ស៖** កាលពីម្សិលមិញ លោកនិយាយថាបើពួកហ្នឹងសារភាព <> គេសន្យាថានឹងដោះលែង។ ខ្ញុំស្តាប់អ៊ីចឹងត្រឹមត្រូវទេកាលពីម្សិលមិញនោះ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** លោកថាអម្បាញ់មិញមានអ្នកទោសវៀតណាមនោះ អ្នកខ្លះជាជនស៊ីវិល អ្នកខ្លះជាទាហាន ដូច្នេះក្នុងចំណោមអ្នកទាំងអស់ហ្នឹង តើ<ក្នុងចំណោមអ្នកទាំងនោះ មានអ្នក>ដែលរត់គេច<ចេញពីប្រទេសរបស់ពួកគេ ហើយធ្វើជាជនភៀសខ្លួនតាម>ទូកនៅ<ក្នុងដែន>សមុទ្រ<កម្ពុជា នៅតាមឆ្នេរក្នុងដែនទឹកកម្ពុជា> ហើយត្រូវបានចាប់ខ្លួន<ដោយសារការបើកនាវា>ចូលមកដែនទឹកកម្ពុជា<ទេ?> តើមានករណីហ្នឹងទេ?

**ឆ៖** បាទ ករណីជនភៀសខ្លួន គឺមិនដែលឃើញមានទេ មានតែអ្នកមកនេសាទ មកអីចាប់បានមកហ្នឹង។

[០៩:០៨:៤១]

**ស៖** លោកបាននិយាយជាច្រើនលើកច្រើនសាអំពីហេតុការណ៍ជាក់លាក់មួយចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺនិយាយអំពីកូនង៉ែតវៀតណាមដែលត្រូវបានទម្លាក់ពីលើ<ដំបូល>អគារ។ តើលោកអាចជម្រាបឲ្យបានច្បាស់លាស់បន្តិចបានទេ ថាតើហេតុការណ៍ហ្នឹងវាកើតឡើងយ៉ាងម៉េច ហើយនៅកន្លែងណាឲ្យបានជាក់លាក់?

**ឆ៖** រឿងហេតុនេះ ខ្ញុំសូមបង្ហាញថយក្រោយវិញ នៅសម័យដែលខ្ញុំនៅការពារខាងក្រៅ។ នៅអាផ្លូវខាងលិចឡានទឹកហ្នឹង កាលហ្នឹងមានគេហៅថាកាស៊ីនបាយមួយដែលជំនាន់ ប៉ុល ពត មកនៅសេសសល់នៅហ្នឹង ហើយមានដើមអំពិលទឹកបារាំងមួយនៅកាច់ជ្រុងអាផ្លូវកែងខាងត្បូង -- ខាងលិចឡានពេទ្យ -- ឡានទឹកសព្វថ្ងៃហ្នឹង។ អ៊ីចឹងផ្ទះកន្លែងហ្នឹងមានផ្ទះមួយមានពីរជាន់ ពេលហ្នឹងគេដាក់ការិយាល័យគេនៅកន្លែងហ្នឹងមួយសម្រាប់ទទួលអ្នកទោស ពេលមកដល់ហ្នឹង ខ្ញុំក៏នៅខាងក្រោមនៅយាមការពារហ្នឹង ដល់ពេលយកអ្នកទោសមក គឺអ្នកទោសវៀតណាមមកទាំងប្តីទាំងប្រពន្ធ ទាំងកូនស្រីមួយអាយុប្រហែលជាជាងមួយខួប ចេះដើរតិចតួច។ ដល់ពេលយកទៅកូនហ្នឹងវាទៅតាមម៉ែ តាមឪវាហ្នឹង ដល់អ៊ីចឹង ឈ្មោះ ដែក ប៊ូ ហើយនិង អី-- ដូច ទុយ ក៏បានទាញកូនហ្នឹងចេញពីម្តាយឪពុកហ្នឹង នាំម្តាយឪពុកចូលទៅក្នុងប៊ុយរ៉ូ ក្នុងការិយាល័យដែលសម្រាប់កត់ឈ្មោះហ្នឹង ទាញចេញមកក្រៅ ហើយ

បិទទ្វារជិតទៅក៏ចេញមកខាងក្រៅ មកយ៉មុខបង្កាន់ដៃមុខហ្នឹង ទម្លាក់កូនហ្នឹងមកដី ខ្ញុំនៅពីក្រោមហ្នឹងក៏ឃើញធ្លាក់មកក៏ស្លាប់ទៅ។ ហើយបញ្ជាឲ្យខ្ញុំ បកដៃឲ្យខ្ញុំយកទៅកប់ចោលនៅខាងត្បូងហ្នឹងទៅ។ ហ្នឹងមានឃើញជាក់ស្តែង។

**សៈ** ខ្ញុំមានសំណួរមួយជាលក្ខណៈទូទៅ ពាក់ព័ន្ធទៅនឹងគោលនយោបាយនៃរបបខ្មែរក្រហមចំពោះជនជាតិវៀតណាម។ ក្នុងពេលប្រជុំដែលលោកបានចូលរួមជាមួយ ឌុច ជាពិសេសគឺពេលប្រជុំដែល សុន សេន បានបង្រៀនលោកអំពីគោលនយោបាយ។ តើគេមាននិយាយអំពីគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យចំពោះជនជាតិវៀតណាមដែរឬទេ? ជាពិសេស តើ ឌុច និង សុន សេន បាននិយាយប្រាប់លោកដែរឬទេ ថាជនជាតិវៀតណាមត្រូវចាត់ទុកជាខ្មាំង?

[០៩:១២:០៩]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! អញ្ជើញលោកមេធាវី វិុកទ័រ កូប៉េ!

**លោក វិុចទ័រ កូប៉េ៖**

លោកប្រធានខ្ញុំសូមជំទាស់ទៅនឹងការរៀបចំជាសំណួរបែបនេះ។ គួរតែ<>ច្បាស់<ថាតើសហព្រះរាជអាជ្ញាចង់សួរពីអ្វីនោះ។ តើ>គាត់<និយាយពី>វៀតណាម<>សំដៅទៅលើប្រទេសតែម្តង ឬក៏<គាត់សំដៅទៅលើ>គោលនយោបាយវៀតណាម? <តើគាត់និយាយពីប្រជាជន>វៀតណាម<នៅក្នុងប្រទេសវៀតណាមឬ? តើគាត់និយាយអំពីជនជាតិវៀតណាមរស់នៅ>ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? ដូច្នេះ <តើគាត់ចង់សំដៅទៅលើអ្វីឲ្យពិតប្រាកដ នៅពេលគាត់និយាយ>ថា <ជនជាតិ>វៀតណាម <នៅក្នុងសំណួររបស់គាត់នោះ>?

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**សៈ** <>ខ្ញុំនឹងបញ្ជាក់អំពីរយៈកាល គឺខ្ញុំនិយាយពីឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ដែលលោកថាមានឃើញ<អ្នកទោស>ជនជាតិវៀតណាម<>មកច្រើននៅស-២១។ ដូច្នេះ ខ្ញុំចង់ដឹងថានៅពេលនោះ តើ ឌុច និង សុន សេន មានបានប្រាប់លោកទេថា ជនជាតិវៀតណាមទាំងអស់ទោះជាអ្នកណាក៏ដោយត្រូវតែចាត់ទុកថាជាខ្មាំងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ តើគាត់មានបាននិយាយបែបហ្នឹងប្រាប់លោកទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ នៅសម័យ៧៧, ៧៨ ហ្នឹងគឺ ខ្ញុំសូមវង់ក្រចកបន្តិច ពីព្រោះជនជាតិភាគតិច គឺជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជាគឺអត់មានទេ។ គឺអ្នកមានមុនៗមក អ្នកណារត់ទៅស្រុកទាន់ក៏ទាន់ អ្នកណារត់មិនទាន់គឺសម្លាប់ចោលអស់ហើយ។ តាំងពីសម័យ៧៥មក ប៉ុន្តែនៅសម័យ១៩៧៧, ១៩៧៨ នេះគឺ ដោយខ្មែរនិយាយអំពីរឿងពេលកំពុងធ្វើសង្គ្រាមជាមួយវៀតណាម។ អ៊ីចឹងវៀតណាមពេលហ្នឹងគេបានប្រកាស និងណែនាំពួកខ្ញុំជាបុគ្គលិកនៅស-២១ ថាវៀតណាមជាសត្រូវស្លូវពូជរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយនិងទិសដៅវ៉ៃយកដីកូសាំងស៊ីន ដីកម្ពុជាក្រោមយកមកវិញទាល់តែបាន។ ហ្នឹងជាទ្រឹស្តីរបស់ សុន សេន និង នួន ជា ដែលបានបង្រៀន និងជម្រាបបុគ្គលិកស-២១ ទាំងអស់នៅពេលមកបង្រៀននយោបាយហ្នឹង។

**ស៖** ខ្ញុំចង់ត្រឡប់មកនិយាយអ្វីដែលលោកទើបតែឆ្លើយ។ លោកថាមិនមានជនជាតិវៀតណាមរស់នៅប្រទេសកម្ពុជាទេ ក្រោយឆ្នាំ៧៥, ៧៦ ពីព្រោះថាពួកគេទៅវៀតណាមអស់ ឬក៏ត្រូវបានសម្លាប់ចោល។ ដូច្នេះ ខ្ញុំសូមអានន្ទូវសម្រង់ពីរ ចេញពីកំណត់ត្រាអ្នកស្នួរចម្លើយនៅស-២១ គឺ ឯកសារ E3/833 សម្រង់ទី១ គឺនៅទំព័រ៦៩ ជាភាសាបារាំង ERN គឺ 00282536 មិនមានការបកប្រែជាភាសាអង់គ្លេសទេ ជាភាសាខ្មែរ គឺ 00077729។ ខ្ញុំសូមដកស្រង់៖ "នៅក្នុងឆ្នាំ១៩៧០ ជនជាតិវៀតណាមនៅកម្ពុជាគឺមានចំនួន ៥០០.០០០ នាក់ រួមទាំង<>ទាហានវៀតណាមបីកងពល និងកម្មាភិបាលមកពីហាណូយ គឺមានជាង ១.០០០ នាក់។ (បន្ទាប់មកទៀត) នៅឆ្នាំ<១៩៧៦> មិនមានជនជាតិវៀតណាមទៀតទេ នៅក្នុងទឹកដីកម្ពុជា។"

[០៩:១៦:១៨]

នៅក្នុងឃ្លាមួយទៀតក៏មានលក្ខណៈខុសប្លែកពីនេះ បន្តិចគឺនៅទំព័រ៨០ ជាភាសាបារាំង គឺ 00282547, ជាភាសាខ្មែរគឺ 00077740 ខ្ញុំសូមដកស្រង់៖ "ស្ថានភាពជនជាតិវៀតណាម ១ជាសត្រូវរបស់ពួកយើង។ ពួកវាមានគោលបំណងលេបទឹកដីរបស់យើង ហើយយកទៅធ្វើជាទឹកដីរបស់ពួកវា នៅតែមានកម្លាំងវៀតណាមនៅកម្ពុជា។ នៅមានវៀតណាមនៅកម្ពុជា ហើយពួកហ្នឹង គឺត្រូវស្ថិតនៅក្នុងពួកក្រុមដែលត្រូវបានបញ្ជូនទៅប្រទេសវិញនៅឆ្នាំ<១៩៧៣> <ដោយសារតែ>ពួកអាក្បត់បានលាក់<ពួកគេ>។" ដូច្នេះ<យើងឃើញថា ក្នុងឃ្លានេះ យើងកំពុងនិយាយពីស្ថានការណ៍នៅក្នុងឆ្នាំ១៩៧៣ ហើយលោកបាននិយាយថា ពួកគេបានចាកចេញទៅនៅក្នុងឆ្នាំ១៩៧៥។> ខ្ញុំសួរលោក ថាតើ

លោកមានធ្លាប់ស្តាប់ឮតាមរយៈ ឌុច ឬ សុន សេន ថា តាមពិតទៅមាននៅសល់ជនជាតិវៀតណាមនៅកម្ពុជានៅឆ្នាំ១៩៧៧ និង ៧៨ នោះ ពីព្រោះថាពួកជនក្បត់ហ្នឹងបាននាំគ្នាលាក់ជនជាតិវៀតណាមនៅក្នុងប្រទេស។ តើលោកធ្លាប់ឮ សុន សេន ឬក៏ឌុច និយាយបែបហ្នឹងទេ?

**ផ៖** បាទ ពាក្យនេះ ខ្ញុំមិនដែលបានឮទេ។

**ស៖** ខ្ញុំនៅសល់សំណួរពីរទៀត។ ពាក់ព័ន្ធនឹងពេលដែលលោកចាកចេញពីស-២១ នៅដើមខែមករា ឆ្នាំ១៩៧៩ គឺនៅពេលដែលវៀតណាមបុកចូលមកប្រទេសកម្ពុជា។ កាលពីម្សិលមិញ គឺខ្ញុំបានបង្ហាញនូវចម្លើយសារភាពមួយ <ដែលធ្វើនៅថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៧៩។> ដូច្នេះខ្ញុំចង់សួរលោកថា នៅពេលណាដែលលោកឈប់ធ្វើជាអ្នកសួរចម្លើយ ហើយតើមុនពេលវៀតណាមវាយចូលប៉ុន្មានថ្ងៃនោះ ហើយនិងមុនពេលដែលលោករត់គេចចេញពីស-២១នោះ តើពេលហ្នឹងមានហេតុការណ៍អ្វីខ្លះកើតឡើង?

**ផ៖** បាទ នៅក្នុងឆ្នាំ១៩៧៩ ដើមឆ្នាំ និងចុង១៩៧៨ហ្នឹង នៅសភាពការណ៍ពេលនោះ គឺកងទ័ពកម្ពុជាប្រជាធិបតេយ្យហ្នឹងវាយសម្រុកចូលទៅប្រទេសវៀតណាម អ៊ីចឹងកាំភ្លើងឮសូរមកដល់ នៅស-២១ ឮសូរកាំភ្លើងដល់ កាំភ្លើងធំ។ ពេលហ្នឹងនៅចន្លោះ ចុងឆ្នាំ១៩៧៨ ប្រហែលជាមួយខែ ឬជិតមួយខែហ្នឹងនៅចុងឆ្នាំហ្នឹង។ អ៊ីចឹងការងារនៅស-២១ គឺផ្អាកយកមនុស្សសួរ ហើយនិងឃើញសកម្មភាពដឹកជញ្ជូនអ្នកទោសចេញជាបន្តបន្ទាប់ រហូតទល់ថ្ងៃ០២ ថ្ងៃ០៣ មករា អាហ្នឹងបានអស់មានការដឹកជញ្ជូនអ្នកទោសចេញយកទៅសម្លាប់ចោល។ អ៊ីចឹងសកម្មភាពហ្នឹង និងអ្នកទោសយកចូលអត់មានទេ មានតែយកចេញ។ ហើយពេលនៅថ្ងៃ០៧ មករា ហ្នឹង ពេលហ្នឹង ខ្ញុំនៅក្នុងស-២១ គេឲ្យ គេយកកាំភ្លើងបំពាក់ឲ្យគ្រប់ៗគ្នា កាន់គ្រាប់ៗដៃ ដើម្បីការពារកងទ័ពយួន ប៉ុន្តែពេលហ្នឹង កម្លាំងកងទ័ពយួន អត់មានកម្លាំងមកច្រើនតែ មានរថក្រោះអឹមសង់ត្រីបីគ្រឿង ចូលមកតាមស្ពានច្បារអំពៅ បើកមកតាមផ្លូវមុនីវង្សផ្តោះទៅកន្លែងអគ្គសេនាធិការនិងទៅពោធិ៍ចិនតុង។ ហើយក្រៅពីហ្នឹង កម្លាំងនៅភ្នំពេញហ្នឹង ជាកម្លាំងរបស់ ប៉ុល ពត ហ្នឹង រត់រប៉ាត់រប៉ាយចូលមកក្នុងហ្នឹង ស-២១ មានខាងៗឃោសនាការ ខាងក្រសួងមន្ទីរអី មកច្របូកច្របល់គ្នាពេញទាំងអស់ ព្រោះមកតាមល្ងទឹកស្អុយ ដល់អ៊ីចឹងកម្លាំងពេលហ្នឹងច្របូកច្របល់ មិនដឹងជាអ្នកណាគ្រប់គ្រងអ្នកណាទេ។

[០៩:២១:០៩]

**ស៖** អម្បាញ់មិញនេះ លោកថា អ្នកទោសត្រូវបានដឹកចេញទៅក្រៅជាច្រើន។ តើពេលគេដឹកចេញហ្នឹង គេយកអ្នកទោសទាំងអស់ហ្នឹង យកទៅធ្វើអីដែរ?

**ឆ៖** បាទ អ្នកទោសហ្នឹង ខ្ញុំឃើញគេដឹកចេញហ្នឹង ប្រហែលជាយកទៅសម្លាប់ហើយ ព្រោះខ្ញុំអត់បានឃើញ អត់បានទៅជាមួយគេ ខ្ញុំឃើញតែនៅក្នុងកន្លែងស-២១ហ្នឹង ឃើញគេដាក់ឡានអាកាត់ៗ ចិនហ្នឹងបីបួនគ្រឿង សុទ្ធតែហ៊ុមតង់ជិតៗ ហើយនិងឃើញយកអ្នកទោសហ្នឹង អូសឡើងឡាន ខ្លះលើកបោះ ខ្លះរុញច្រានឡើងគ្នាទុរន់ទុរា ខ្លះស្គមរីងរៃ។ ឡើងឡានមិនរួច លើកបោះ។ ក្នុងមួយៗឡាន សាមសែសិបនាក់ ហើយចងតង់ជិតៗឈឹង យកទៅក្រៅហ្នឹង ប៉ុន្តែប្រហែលជាទិសដៅ យកទៅជើងឯកហើយ ព្រោះខ្ញុំមិនបានដឹងដល់ខាងក្រៅទេ ដឹងថា ឃើញពីក្នុង។

**ស៖** នៅថ្ងៃដែលលោករត់ចេញ តើបុគ្គលិកស-២១ មានបាននាំអ្នកទោសទៅជាមួយខ្លួនទេ ឧទាហរណ៍ដូចជា អ្នកទោសដែលធ្វើការនៅក្នុងរោងជាង កន្លែងគូរគំនូរ ឬផ្នែកគ្រឿងយន្ត ឬក៏អ្នកដែលបោសសម្អាតអីហ្នឹង តើបុគ្គលិកមាននាំអ្នកទោសដែលធ្វើការទាំងអស់ហ្នឹងទៅជាមួយទេ?

**ឆ៖** បាទ ពេលខ្ញុំចេញទៅថ្ងៃ០៧ មករាហ្នឹង ប្រហែលជាម៉ោងបីរសៀល ចេញពីស-២១ហ្នឹង ឃើញមានអ្នកទោសដែលបានដោះលែងឲ្យធ្វើការនៅក្នុងស-២១ហ្នឹង ដូចជា តាចាន់, តាម៉ី, តាវ៉ាន់ណាត ហើយនិងអ្នកដទៃច្រើនទៀតដែលខ្ញុំមិនចាំឈ្មោះ ទៅជាមួយគ្នាទាំងអស់ រត់ទៅរហូតទៅអមលាំង ត្រពាំងជ្រៃ ខាងកំពង់ស្ពឺ។

**ស៖** តើលោកធ្លាប់ឮពី ឌុច <មិនថា>នៅថ្ងៃទី០៧ មករា ឬក៏នៅថ្ងៃក្រោយមកទៀត<ទេ> ថាហេតុអីបានជា ឌុច មិនចេញបញ្ជាឲ្យសម្លាប់អ្នកទោសដែលគេឲ្យធ្វើការនៅស-២១? តើគាត់<ធ្លាប់និយាយពីការពិតជាក់ស្តែងដែលអ្នកទាំងនោះមិនត្រូវបានគេសម្លាប់>ទេ? <ហើយតើ>គាត់<ធ្លាប់និយាយពីមូលហេតុដែលពួកគេមិនត្រូវបាន>សម្លាប់<ដែរទេ>?

[០៩:២៤:០៧]

**ឆ៖** បាទ ពេលហ្នឹង ខ្ញុំមិនបានឮគេនិយាយអ្វីទេ ព្រោះកាលរត់ទៅ សភាពការណ៍ពេលហ្នឹង គឺសុទ្ធតែស្លន់ស្លោទាំងអស់គ្នា អ៊ីចឹងសភាពការណ៍នេះអត់មានការរៀបចំបានទេ។ រត់ចេញទៅព្រុលរកតែផ្លូវដើរមិនចង់ឃើញផង។ អ៊ីចឹងមិនបានរៀបចំផែនការសម្លាប់អ្នកទោសទេ ចេញទៅដល់ខាងក្រៅហ្នឹងគឺ ឌុច និង ហ៊ី មិនបានគ្រប់គ្រងកម្លាំងហ្នឹងទេ។ ទាំងគេ ទាំងខ្ញុំ រត់យកតែអាយុ ទៅតាមផ្លូវទៅ ក៏តាមវាស្រែខែស្រូវទុំហ្នឹង ជាន់ទៅស្រែមួយៗហ្នឹង រាបដូចកន្ទេល ដូចយករនាស់រាស់ឲ្យរាបអ៊ីចឹងជាន់ដើរទៅ។ ហើយដល់ឆ្លងផ្លូវជាតិលេខ៣ ម្ដុំភ្លើងឆេះរទេះ ប្រហែលជាម៉ោងបួនជិតភ្លឺហ្នឹង គ្រាន់តែឆ្លងទៅបានពាក់កណ្ដាលហ្នឹង រថក្រោះអឺមសង់ត្រឺពីរបីគ្រឿងឡើង ចុះមកពីខាងជើង ដេញដាច់ហ្វូង

ហ្នឹង មួយកំណាត់មកក្រោយ មួយកំណាត់ទៅមុខ ខ្ញុំទៅមុខទៅ មួយកំណាត់ហ្នឹង នៅក្រោយ មិនដឹងជាទៅណា មកណាទេ។ ខ្ញុំដឹងតែនៅមុខ នៅមុខហ្នឹង ទៅតរហូតទៅដល់អមលាំង ត្រពាំងជ្រៃហ្នឹង។ ដល់ពេលនោះ អ្នកទោស ក៏ដូចជាខ្ញុំដែរ គឺរកផ្លូវរៀងៗខ្លួន បែងចែកពេលហ្នឹងទាំងអស់គ្នា។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

សូមអរគុណច្រើនលោកសាក្សី ដែលបានឆ្លើយទៅនឹងសំណួរទាំងអស់របស់ខ្ញុំ។

លោកប្រធាន ខ្ញុំអស់សំណួរហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសសួរដេញដោលសាក្សី។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សូមលោកប្រធានអនុញ្ញាតឱ្យលោកស្រី ជេត វណ្ណលី សួរសំណួរទៅសាក្សីរូបនេះ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ត្រឹមម៉ោងដប់ណ៎ះ! ពេលវេលា។

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំឈ្មោះ ជេត វណ្ណលី មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ជម្រាបសួរលោកសាក្សី ម្សិលមិញលោកបានឆ្លើយនៅចំពោះមុខអង្គសវនាការពីការបួមឈាម។ ឥឡូវហ្នឹង ខ្ញុំចង់ឱ្យលោកបញ្ជាក់នូវចំណុចមួយចំនួន ដែលទាក់ទងនឹងបញ្ហានេះ។ ខ្ញុំចង់ឱ្យលោកបញ្ជាក់ថា តើការបួមឈាមនេះធ្វើនៅឆ្នាំណា?

[០៩:២៦:៥៨]

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ ការបួមឈាមនេះ ខ្ញុំមិនច្បាស់ជាឆ្នាំណាទេ ប៉ុន្តែប្រហែលជាក្នុងឆ្នាំ

១៩៧៧, ៧៨ហ្នឹង។

**ស៖** អរគុណលោក។ តើលោកមានបានដឹងទេថា ការបូមឈាមនេះ ទទួលបញ្ជាពីអ្នកណា?

**ឆ៖** បាទ ខ្ញុំដឹងត្រឹមតែឃើញ មិនដឹងជាទទួលបញ្ជាពីនរណាទេ ព្រោះខ្ញុំគ្រាន់តែឃើញពេទ្យទ្រី គាត់បូមឈាមនៅក្នុងបន្ទប់ ដែលគាត់នៅនឹងជ្រុងមុខខ្លោងទ្វារចូលទួលស្លែងចាស់ហ្នឹង។ នៅពេលខ្ញុំយកអ្នកទោសយកទៅទុក ម៉ោងដប់មួយយប់ហើយ ខ្ញុំបកមកវិញ ខ្ញុំចូលទៅឃើញបូមឈាមហ្នឹងអាហ្នឹងបានខ្ញុំឃើញ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** អរគុណលោក។ ក្រោយ -- លោកនៅទីកន្លែងនោះ ដូច្នេះក្រោយពីការបូមឈាមហើយ លោកឃើញគេយកអ្នកទោសហ្នឹងទៅណា លោក? ហើយអ្នកទោសពេលហ្នឹង នៅក្នុងសភាពបែបណាដែរ ពេលដែលគេបូមហើយ?

**ឆ៖** បាទ ពេលគេបូមហើយ ខ្ញុំឃើញគេដកទុយោដកអីចេញហើយ គេសែងបោះទៅគៀនជញ្ជាំងគរទុកម្ដុំទៅ ហើយក្នុងហ្នឹង មានឃើញរៀបចំជារទេះរុញ សម្រាប់ដឹកយកទៅកប់ ហើយការកប់សាកសព អ្នកបូមឈាមហ្នឹង ខ្ញុំមិនបានឃើញច្បាស់ទេ ប៉ុន្តែស្នែកឡើង ពេលខ្ញុំចេញទៅខាងក្រៅផ្ទះក្រៅអី ធ្វើពលកម្មម៉ោងប្រាំ ម៉ោងប្រាំមួយល្ងាចហ្នឹង ខ្ញុំឃើញនៅខាងមុខផ្ទះខ្ញុំនៅហ្នឹង កន្លែងដីវាលម្ដុំហ្នឹង ឃើញស្នាមកប់ រណ្ដៅថ្មីៗហ្នឹង។

[០៩:២៩:០៩]

**ស៖** អរគុណលោក។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថា អ្នកទោសដែលត្រូវគេបូមឈាមហ្នឹង តើពេលដែលគេបូមឈាមរួច គាត់ស្លាប់ ឬក៏គាត់នៅរស់ដែរ?

**ឆ៖** បាទ ពេលគេបូមឈាមហើយ គឺដូចមិនទាន់ស្លាប់ភ្លាមទេ ឃើញនៅដកដង្ហើមតឹតតក់ៗៗ ប៉ុនគ្រាន់តែដឹងថា អស់ឈាមពីខ្លួនហើយ នៅសល់តិចតួច គឺមិនអាចនិយាយបាន មិនអាចកម្រើកដៃកម្រើកជើងបានទេ ឃើញតែដកដង្ហើមតឹតតក់ៗហ្នឹង។

**ស៖** អរគុណលោក ហើយតាមលោកដែលលោកនៅទីកន្លែងនោះស្រាប់ លោកបានឃើញថា តើអ្នកបូមឈាមអ្នកទោសហ្នឹង តើគេតម្រូវឲ្យមានការបូមឈាមប៉ុន្មានកំផ្លោកទៅ ក្នុងអ្នកទោសម្នាក់?

**ឆ៖** បាទ រឿងចំនួនកំប្លោក រឿងហ្នឹងខ្ញុំអត់ដឹងទេ ប៉ុន្តែបើតាមខ្ញុំមើលឃើញប្រហែលជាបូមទាល់ម៉ាអស់។

**ស៖** អរគុណលោក។ តើចំពោះលោកដែលឃើញទិដ្ឋភាពហ្នឹង លោកមានអារម្មណ៍យ៉ាងម៉េច

ដែរ នៅពេលហ្នឹងលោក? លោកមានអារម្មណ៍ភ័យខ្លាចទេ?

**ឆ៖** បាទ សភាពការណ៍នៅពេលហ្នឹង ខ្ញុំឃើញគេបូមអ៊ីចឹង ខ្ញុំក៏មានអារម្មណ៍មួយថា មានការតក់ស្លុតដែរ ប៉ុន្តែក្នុងចិត្តគឺមិនឲ្យ -- មិនធ្វើអាកប្បកិរិយាឲ្យគេដឹងទេ ប៉ុន្តែគ្រាន់តែនឹកក្នុងចិត្តព្រោះខ្ញុំសម័យហ្នឹង ខ្ញុំមានការគិតគូរ ចេះគិតគូរដែរ ខ្ញុំចេះបែងចែកពីអាក្រក់ និងល្អដែរ។ ប៉ុន្តែគ្រាន់ថា មិនហ៊ានហាមាត់ មិនហ៊ានថា ព្រោះក្នុងសម័យហ្នឹង គឺអ្នកណាប្រឆាំង អ្នកហ្នឹងស្លាប់។ អ៊ីចឹងខ្ញុំយកម៉ាសុខ ម៉ារួចខ្លួនខ្ញុំសិន។

[០៩:៣១:១១]

**ស៖** អរគុណលោក។ ម្សិលមិញលោកបានបញ្ជាក់ថា ពេទ្យទ្រី ជាអ្នកបូមឈាម។ ពេលដែលវៀតណាមចូល នៅថ្ងៃ០៧ មករា ៧៩ ហ្នឹង តើពេទ្យ ទ្រី ហ្នឹងនៅរស់ ឬក៏វាសនាគាត់យ៉ាងម៉េចដែរលោក?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ ពេទ្យ ទ្រី នៅក្នុងហ្នឹងគឺគាត់ជាប្រធាន ប៉ុន្តែក្នុងនោះ មានបុគ្គលិកគាត់ក្រោមៗហ្នឹង បួនប្រាំនាក់ទៀត មិនមែនជាពេទ្យ ទ្រី ម្នាក់ទេ ប៉ុន្តែគ្រាន់តែខ្ញុំមិនចាំឈ្មោះអស់។ ខ្ញុំចាំតែអ្នកប្រធាន ហ្នឹងគឺចាំ។ ប៉ុន្តែពេទ្យ ទ្រី ហ្នឹងក្រោយមកក៏ត្រូវគេចាប់យកមកដាក់គុក យកទៅសម្លាប់ចោលដដែល ដូចតែគ្នាហ្នឹង។

**ស៖** អរគុណលោក។ ឥឡូវខ្ញុំសូមឆ្លងទៅប្រធានបទមួយទៀត ដែលទាក់ទាមនឹងការរំលោភនៅស-២១។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើនៅក្នុងស-២១ ក្នុងនាមលោកជាអ្នកសួរចម្លើយ លោកដែលបានឃើញទិដ្ឋភាពនៃការរំលោភនៅក្នុងស-២១ ទេ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់សំណួរនេះ ម្តងទៀត។ រំលោភលើសិទ្ធិ ឬក៏រំលោភលើស្ត្រីភេទ?

**ស៖** រំលោភលើស្ត្រីភេទ លោក?

**ឆ៖** បាទ ផ្នែករំលោភលើស្ត្រីភេទ ខ្ញុំបានដឹង បានឃើញ មិនមែនឃើញគេរំលោភទេ ឃើញពេលគេរំលោភហើយ គេចាប់មក។ នៅខាងក្រោយផ្ទះខ្ញុំបាទដែលកំពុងសួរ នៅពេលថ្ងៃរសៀល ចន្លោះពីម៉ោងពីរ ដល់ម៉ោងប្រាំហ្នឹង នៅក្រោយផ្ទះខ្ញុំបាទ។ ឈ្មោះ ទូច ជានីរសារ ជាអង្គរក្សរបស់ ម៉ម ណៃ ហៅ ចាន់ បានយកនារីម្នាក់យកទៅសួរក្នុងបន្ទប់ជាន់ក្រោម។ ហើយកន្លែងហ្នឹងក៏វាស្ងាត់ដែរ។ ហើយបានរំលោភលើនារីដែលជាអ្នកទោស។ ក្រោយមកក៏មាននីរសារ តាចាន់ ហ្នឹងមកជួបទាន់ក៏ដឹងរឿងរ៉ាវ ចាប់ ទូច ហ្នឹងយកទៅដាក់នៅកន្លែងផ្ទះ ចាន់ នៅហ្នឹងលើជាន់ទី១លើ ដាក់ខ្នោះដៃ ហើយ ដាក់ខ្នោះដៃ

ហើយលែងចោលនៅលើឥដ្ឋហ្នឹងក៏ ទូច ហ្នឹងរត់ឡើងទៅជាន់ទី២ ខាងលើទៀតលោតទម្លាក់ពីលើអគារហ្នឹង ទើរលើខ្សែកាប ខ្សែភ្លើងបែកភ្លើងផ្ទុះសេខ្សែភ្លើងដាច់អស់ ហើយ ទូច ហ្នឹងក៏ធ្លាក់មកទើរលើគុម្ពចេកអត់ងាប់។ ក្រោយមកក៏ចាប់យកមកដាក់ខ្នោះ ដាក់ច្រវាក់បានម្តងទៀត បានចូលទៅនៅក្នុងគុក។

[០៩:៣៤:២៥]

**ស៖** អរគុណលោក។ ក្រៅពីឈ្មោះ ទូច តើមានករណីណាផ្សេងទៀតទេលោក?

**ឆ៖** ក្រៅពីឈ្មោះ ទូច ខ្ញុំមិនដែលឮទៀតទេ។

**ស៖** អរគុណលោក លោកស្គាល់ ឡាច មាន ទេលោកដែលជាអ្នកសួរចម្លើយនៅក្នុងស-២១ ដែរ?

**ឆ៖** បាទ ឡាច មាន ស្គាល់។ នៅជាមួយខ្ញុំ ព្រោះពេលកម្លាំងដែលមកពី៧០៣ គេចាប់យកទៅសម្លាប់អស់ បានបញ្ជូន ឡាច មាន ហ្នឹងមកក្រោយមកនៅជាមួយខ្ញុំហ្នឹង វាជាកម្លាំងរបស់ ឌុច យកមកពីភូមិភាគបស្ចិមជាក្មេងស្រុករក្រោយ អាយុ១៣, ១៤ឆ្នាំប៉ុណ្ណោះទេ។

**ស៖** អរគុណលោក។ នៅថ្ងៃទី២៦ ខែ៤ ឆ្នាំ២០១៦ ឡាច មាន ដែលជាសាក្សី បានមកឆ្លើយបំភ្លឺនៅចំពោះមុខតុលាការនៅវេលាម៉ោង ១១:០៣ រហូតដល់ម៉ោង ១៦:០៨។ ហើយ ឡាច មាន សាក្សីនេះ បានបញ្ជាក់ថានៅក្នុងស-២១ មានការរំលោភបីករណី។ ទី១ ឈ្មោះទូច រំលោភលើអ្នកទោសក្នុងពេលសួរចម្លើយ។ ទី២ មានឈ្មោះ តាំង ធ្វើពេទ្យរំលោភលើអ្នកទោសដែរ ហើយនិងទី៣មានឈ្មោះ សឿង ធ្វើពេទ្យដែលជានិរសារ -- និងជានិរសាររបស់ តាហ៊ី ក៏បានរំលោភលើអ្នកទោសដែរ។ តើលោកមានបានដឹងហេតុការណ៍ទាំងនេះទេ?

**ឆ៖** ឈ្មោះទាំងនេះខ្ញុំស្គាល់ ប៉ុន្តែរឿងរំលោភលើស្ត្រីភេទខ្ញុំអត់ដឹងទេ ដឹងតែឈ្មោះ ទូច ម្នាក់ព្រោះ ឡាច មាន កាលមុនគេនៅខាងកងការពារខាងក្រៅ គេដើរចុះដើរឡើងគេដឹងរឿងច្រើន។

**ស៖** អរគុណលោក។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថា តើថ្នាក់លើនៃស-២១ ដែលបានដាក់ទណ្ឌកម្មចំពោះអ្នកដែលបានប្រព្រឹត្តអំពើរំលោភលើអ្នកទោសហ្នឹងទេ?

**ឆ៖** បាទ នៅកន្លែងហ្នឹងឃើញជាក់ស្តែងដូច ទូច ហ្នឹងអ៊ីចឹងគឺកាលណាមានបទរំលោភហើយក៏គេចាប់យកមកដាក់គុក ដាក់ច្រវាក់ទល់នឹងថ្ងៃគេសម្លាប់ចោល។

[០៩:៣៧:២៩]

**ស៖** អរគុណលោក។ លោកជាអ្នកសួរចម្លើយក្នុងស-២១ តើចំពោះអ្នកទោស លោកដែលបាន

ឃើញអ្នកទោសធ្វើអត្តឃាតទេលោក?

**ឆ៖** បាទ អ្នកទោសធ្វើអត្តឃាតនៅកន្លែងខ្ញុំ មិនដែលជួបប្រទះទេ ប៉ុន្តែខាងក្រៅ ខ្ញុំឮសួរ ហ៊ី និង ឌុច និយាយប្រាប់នៅពេលលើកជារួមសម្រាប់បុគ្គលិកសួរចម្លើយទៅរៀនសូត្រហ្នឹង គឺគេលើកប្រាប់អ៊ីចឹង ដូចជាឆក់កាំភ្លើងបានបាញ់អ្នកយាម យកចង្កៀងចាក់ប្រេងកាតដុតខ្លួន យកប៊ិកចាក់ក ឬក៏លោតទម្លាក់ពីលើអគារ។ អាហ្នឹង ឌុច និង ចាន់ ហ្នឹងគាត់បានរៀបរាប់ប្រាប់ជាសាធារណៈអ៊ីចឹង។

**ស៖** អរគុណលោក។ ឥឡូវខ្ញុំសូមឆ្លងចូលទៅប្រធានបទមួយទៀត ដែលទាក់ទាមនឹងការសួរចម្លើយ។ ខ្ញុំចង់ឱ្យលោកបញ្ជាក់ដែរថា តើអ្នកទោសទាំងអស់ដែលត្រូវបញ្ចេញ -- អ្នកទោសទាំងអស់នៅក្នុងស-២១ ដែលត្រូវបានបញ្ចេញឱ្យសួរចម្លើយនោះ គឺរយៈពេលប៉ុន្មានថ្ងៃក្រោយដែលថ្ងៃចូលទៅក្នុងស-២១ ទើបបានបញ្ចេញមកសួរចម្លើយ?

**ឆ៖** បាទ ចំពោះអ្នកទោសចូលទៅគុកស-២១ គឺមិនមានការកំណត់កត់ត្រាអីទេ គឺជាក់ស្តែងឬសភាពការណ៍ណាដែលគេចង់បានគឺទៅដល់ភ្លាមឱ្យយកមកសួរភ្លាមក៏មាន ឬមួយអ្នកខ្លះទៅមួយខែកន្លះខែសួរទៅ មកជិតមួយខែហើយ អត់ទាន់មានអ្នកសួរក៏មានដែរ។ អាហ្នឹងវាអត់ទៀងទាត់។

**ស៖** អរគុណលោក។ តើបន្ទប់សួរចម្លើយរៀបចំដូចម្តេចខ្លះ? រៀបចំយ៉ាងម៉េចលោកក្នុង អាហ្នឹងបន្ទប់សួរចម្លើយណ៎ា មានតុ មានកៅអី ឬក៏របៀបយ៉ាងម៉េចដែរ ចាស?

[០៩:៤០:០៥]

**ឆ៖** បាទ នៅក្នុងបន្ទប់សួរចម្លើយហ្នឹងគឺ បន្ទប់មួយៗត្រូវមានបង្អួច មានទ្វារជិត រៀបចំតុកៅអី សម្រាប់ដាក់អ្នកទោស និងខ្នោះជើង រនងដែកហ្នឹងដាក់ចាក់ជាប់ជាមួយនឹងតុ ហើយនិងមានកន្ត្រៃ ឬក៏ជាកេសគ្រាប់ *អាកាអឺ* ១៥ សម្រាប់បត់ជើងតូច ជើងធំ។

**ស៖** តើពេលសួរចម្លើយមានដាក់ខ្នោះទេលោក ឬបិទមុខទេ?

**ឆ៖** ពេលសួរចម្លើយធម្មតាយកពីគុកធំទៅគឺ ដាក់ខ្នោះដៃ ចងមុខ ហើយបណ្តើរទៅដល់កន្លែងសួរចម្លើយ គឺត្រូវដាក់ខ្នោះជើងហើយ ដោះខ្នោះដៃស្រាយមុខ ទើបសួរ។

**ស៖** ក្នុងបន្ទប់សួរចម្លើយមានតែលោកតែម្នាក់ឯង ហើយនិងអ្នកទោស ឬមានអ្នកណាផ្សេងទៀតដែរលោក?

**ឆ៖** នៅក្នុងបន្ទប់សួរចម្លើយមានតែខ្ញុំ ហើយនិងអ្នកទោសពីរនាក់ប៉ុណ្ណោះ។

**ស៖** អរគុណលោក។ មុននឹងលោកសួរចម្លើយ តើលោកបានប្រាប់អ្នកទោសអំពីទោសកំហុស

របស់គេទេ?

**ឆ៖** មុននឹងខ្ញុំសួរចម្លើយ ខ្ញុំមិនដែលបានប្រាប់ពីទោសកំហុស ហើយក៏ថ្នាក់លើមកក៏មិនដែលប្រាប់ថាអ្នកហ្នឹងមានទោសអី មានខ្សែសង្វាក់ពីណាពីនែមកដែរ អត់មានទេ។

**ស៖** អរគុណលោក។ ជាគោលការណ៍ អ្នកទោសដែលត្រូវបញ្ជូនទៅឱ្យលោកសួរចម្លើយ តើមានចំណារពី ឌុច ឬពីអ្នកដឹកនាំណានៃស-២១ ទេ?

**ឆ៖** បាទ អ្នកទោសដែលយកទៅគឺមិនមានចំណារអីឱ្យសាកសួរទេ គឺទៅសួរព្រាវតែម្តង។

**ស៖** អរគុណលោក។ តើនៅក្នុងអ្នកទោសម្នាក់ៗលោកប្រើពេលប៉ុន្មានម៉ោងដែរ ដើម្បីសួរចម្លើយហ្នឹង ដើម្បីយកចម្លើយសារភាពរបស់អ្នកទោស?

**ឆ៖** ចំពោះអ្នកទោសម្នាក់ៗ អត់មាននិយាយរាប់ម៉ោងទេ មានតែរាប់ខែ។ ឧទាហរណ៍ជាក់ស្តែងដូច អ៊ុក ផេង ហៅ ឆុន អ៊ីចឹង ដែលខ្ញុំបានសួរ និងធ្វើឯកសារហ្នឹងប្រហែលជាពីរខែជាង។ តែក្រោយៗមកក៏មានខ្លះ ក៏ឆាប់កន្លះខែ ឬក៏បួន ដប់ថ្ងៃ អាហ្នឹងតាមជាក់ស្តែងរបស់អ្នកទោសម្នាក់ៗដែលអាចធ្វើទៅបានឆាប់។

[០៩:៤៣:៤៨]

**ស៖** អរគុណលោក។ តើចំពោះពេលម៉ោងដែលលោកសួរអ្នកទោស ជាទម្លាប់ធម្មតា លោកសួរពីម៉ោងប៉ុន្មានទៅម៉ោងប៉ុន្មាន? ហើយពេលណាទៀត ហើយពេលយប់មានសួរអ្នកទោសទេលោក?

**ឆ៖** ជាក្រឹត្យក្រមនៅក្នុងនោះគឺ អ្នកទោសត្រូវមកយកសួរម៉ោងប្រាំពីរ ដល់ម៉ោង ដប់មួយថ្ងៃ ពីម៉ោងពីរទៅម៉ោងប្រាំ ពីម៉ោងប្រាំពីរយប់ទៅម៉ោងដប់មួយយប់។

**ស៖** អរគុណលោក។ នៅពេលដែលលោកសួរអ្នកទោស តើលោកឱ្យអ្នកទោសអង្គុយលើកៅអីទល់មុខលោក ឬមួយក៏ឱ្យអង្គុយនឹងឥដ្ឋ?

**ឆ៖** បាទ អ្នកទោសពេលយកទៅ គឺឱ្យអង្គុយនៅកៅអីតទល់គ្នា។

**ស៖** លោកដែលឱ្យអ្នកទោសអង្គុយនៅនឹងឥដ្ឋទេលោក? ក្នុងករណីណាដែលអ្នកទោសនៅនឹងឥដ្ឋ?

**ឆ៖** បាទ ក្នុងករណីខ្លះមាននៅនឹងឥដ្ឋដែលព្រោះពេលវាយធ្វើទារុណកម្មអី ធ្លាក់ពីកៅអីទៅនៅអង្គុយនឹងឥដ្ឋ។

**ស៖** អរគុណលោក។ ក្នុងនាមលោកជាអ្នកសួរចម្លើយនៅស-២១ តើកន្លងមកលោកបានធ្លាប់

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សួរអ្នកទោសប្រភេទណាខ្លះ? មានសួរអ្នកទោសជាជនជាតិបរទេសទេ?

**ធ៖** បាទ ខ្ញុំសួរតែជនជាតិខ្មែរទេ បរទេសអត់ដែលទេ។

[០៩:៤៦:០៥]

**ស៖** តើនៅៗក្នុងស-២១ មានអ្នកទោសជាជនជាតិបរទេសទេ លោក តាមដែលលោកដឹង?

**ធ៖** បាទ នៅក្នុង ស-២១ មានៗ វៀតណាម មានជនជាតិអាមេរិកាំង ជនជាតិអូស្ត្រាលី ហ្នឹងដែលខ្ញុំធ្លាប់ឃើញ។

**ស៖** អរគុណលោក។ ចំពោះអ្នកទោសជាជនជាតិអាមេរិកាំង ឬជនជាតិអូស្ត្រាលី តើអ្នកណាជាអ្នកសួរចម្លើយគាត់?

**ធ៖** បាទ ជនជាតិអាមេរិកាំង និងអូស្ត្រាលី គឺមានឌុច និងចាន់ ជាអ្នកសួរ ហើយសួរជាកន្លែងសាធារណៈ នៅក្នុងគុកហ្នឹង ប៉ុនគ្រាន់តែនៅកន្លែងការិយាល័យខាងក្រៅ ជាសាធារណៈ កន្លែងណាៗកន្លែងហ្នឹងអ្នកណាដើរទៅឃើញ ចេញចូលអីឃើញទាំងអស់ ព្រោះមិនមានអ្នកស្ដាប់បានជាភាសាអង់គ្លេសទេ។ គាត់ជាអ្នកចេះភាសាបារាំង ភាសាអង់គ្លេស គាត់ជាអ្នកសួរ។

**ស៖** តាមលោកដឹង តើអ្នកទោសដែលជាជនជាតិ អាមេរិកាំង និងជនជាតិអូស្ត្រាលី ហ្នឹងមានឈ្មោះអីខ្លះ លោកមានបានដឹងទេ? ហើយនៅពេលសួរចម្លើយ ឌុច និង ចាន់ មានប្រើហិង្សាលើរូបគាត់ទេ?

**ធ៖** បាទ ជនជាតិអូស្ត្រាលី ហើយនិងជនជាតិអាមេរិកាំងម្នាក់ហ្នឹង ខ្ញុំមានម្នាក់ខ្ញុំស្គាល់ ខ្ញុំចាំដោយសារ ឃើញឈ្មោះ តេរីដ ស្កុត សរសេរឆ្លាក់ដាក់នៅនឹងលើអាវៗ អាវខូវប៊យ ហើយឡេវធំៗហ្នឹងគឺដាក់ តេរីដ ស្កុត។ ហើយដល់តែពេល ឌុច និង ចាន់ សួរទៅ ក៏ឆ្លើយឈ្មោះថា ឈ្មោះ តេរីដ ស្កុត អ៊ីចឹងខ្ញុំអានៅចាំម្នាក់ហ្នឹង។

[០៩:៤៨:២៣]

**ស៖** តើ ឌុច និង ចាន់ មានប្រើហិង្សាទេ លោក លើជនជាតិបរទេសទាំងពីររូបនេះ?

**ធ៖** បាទ ឃើញប្រើហិង្សា ទាត់ធាក់អី អត់មានឃើញវាយ ឃើញតែទាត់ ហើយធាក់។

**ស៖** តើលោកដឹងទេ ថាក្រោយពេលដែលសួរចម្លើយហើយ វាសនានៃជនជាតិអាមេរិកាំង និងជនជាតិអូស្ត្រាលីនោះទៅជាយ៉ាងម៉េចដែរ លោកមានបានដឹងទេពីបញ្ហាហ្នឹង?

**ធ៖** បាទ វាសនាអ្នកទាំងពីរហ្នឹង ខ្ញុំមិនបានឃើញផ្ទាល់នឹងភ្នែកទេ ប៉ុនគ្រាន់តែខ្ញុំដឹងតាមរយៈ

បងសឿ ជាកងការពារនៅក្នុង ស-២១ ហ្នឹងគេប្រាប់ខ្ញុំថា ជនជាតិអាមេរិកាំង និងអូស្ត្រាលីពីរនាក់ហ្នឹង គេបានយកទៅដុតនៅអាកន្លែង បេឃ្លេហ៊ឹម។ អាផ្លូវយើង ទួលទំពូងឆ្លងកាត់ទៅវត្តមហាមន្ត្រី ហើយ និងអាផ្លូវយើងឡានទឹកខាងលិចហ្នឹង អាហ្នឹងផ្លូវបំបែកហ្នឹង។ កន្លែងបេឃ្លេហ៊ឹម កន្លែងវិហារយេស៊ូមុន កាលណោះកន្លែងហ្នឹងស្ងាត់ជ្រងំអត់មានអ្នកណានៅទេ គឺមានតែកន្លែងកងការពារ អ៊ីចឹងយកអ្នកទាំងពីរនាក់ហ្នឹងយកទៅដាក់នៅកន្លែងថ្នល់ ហើយយកកង់ឡានចាស់ៗធំៗហ្នឹង យកមកស៊ក គ្របពីលើទៅ ប្រឡោះកង់ហ្នឹង ហើយចាក់សាំងដុតតែម្តងហ្នឹង។

**ស៖** អរគុណលោកសាក្សី។ ខ្ញុំឆ្លងទៅបរិបទមួយទៀត ដែលនិយាយពីការសម្លាប់អ្នកទោស។ លោកសាក្សី លោកជាអ្នកសួរចម្លើយនៅក្នុងស-២១ ហើយលោកបានរស់នៅក្នុងស-២១ ក្នុងរយៈពេលដ៏យូរដែរ ជាកងការពារ និងជាអ្នកសួរចម្លើយ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថា តើលោកធ្លាប់ដែលឃើញការសម្លាប់អ្នកទោសនៅក្នុងស-២១ទេ?

**ឆ៖** បាទ រឿងសម្លាប់ ខ្ញុំអត់ដែលបានឃើញទេ។

[០៩:៥១:១៦]

**ស៖** តើលោកដែលធ្លាប់ឮគេនិយាយប្រាប់ ឬក៏ដឹងតាមរយៈមិត្តភក្តិអីទេ មានដែលឮទេលោក?

**ឆ៖** ខ្ញុំឮសួរគេនិយាយប្រាប់ហ្នឹងដែលឮ ប៉ុន្តែបើដែលឃើញ ឃើញតែជំនាន់ជាមួយទាហានលន់នល់ ហ្នឹងមានគេសម្លាប់ គេវាយចោលហើយ ឲ្យខ្ញុំសែងដាក់ឡាន ហ្នឹងមាន។ ពីជំនាន់សង្គ្រាម។

**ស៖** អរគុណលោក។ លោកដែលធ្លាប់ឃើញគេដឹកអ្នកទោសទៅសម្លាប់នៅជើងឯកទេលោក? តើមានរូបភាពយ៉ាងម៉េចខ្លះទៅ គេដាក់ឡាន ឬក៏គេធ្វើយ៉ាងម៉េចលោក? សូមលោកបញ្ជាក់ពីបញ្ហាហ្នឹងជូនអង្គសវនាការ។

**ឆ៖** បាទរឿងការដឹកជញ្ជូនហ្នឹង ខ្ញុំធ្លាប់រៀបរាប់មកខាងមុនជាហូរជាហែ ប៉ុន្តែគ្រាន់តែបញ្ជាក់មួយសាទៀតថា ការដឹកជញ្ជូនហ្នឹង គឺមានជាការញឹកញាប់ណាស់ ពេលខ្ញុំចូលចេញពីកន្លែងគុកធំហ្នឹង ឃើញដឹកជញ្ជូនតាមឡាន ឡានកាត់ៗរបស់ចិន កង់បួនហ្នឹងដាក់តង់ជិត ហើយនិងអូសបញ្ជូនមក ខ្លះដើរអត់រួច គ្រាមក រុញឡើងលើឡាន ខ្លះគ្រវែងលើឡាន។ ណាឡើងរួចក៏ឡើង ដាក់កៅអីឲ្យឡើងនៅកន្លែងមុខគុកហ្នឹង។ ឡានមកទយដាក់ហ្នឹង ហើយបិទជិតៗចេញទៅ។ ហ្នឹងធ្លាប់ឃើញ។

**ស៖** អរគុណលោក។ តើលោកដឹងថាគេដឹកអ្នកទោសដាក់ឡានដែលបិទជិតហ្នឹង តើយកទៅកន្លែងណាដែរទេ?

**ឆ៖** បាទ កាលហ្នឹងខ្ញុំអត់បានដឹងថាយកទៅណាទេ ព្រោះខ្ញុំនៅខាងក្នុងហ្នឹង គឺមិនដែលដឹងការងារខាងក្រៅទេ ព្រោះគេអត់ឲ្យចេញចូលសុទ្ធ។ រឿងជើងឯកនេះ ខ្ញុំនិយាយឲ្យត្រង់ ទើបនឹងដឹងនៅសម័យក្រោយនេះទេ តែពេលខាងកាសែតអ្នកបរទេសហៅខ្ញុំទៅជួប ទៅសម្ភាសនៅកន្លែងបឹងជើងឯកបានខ្ញុំស្គាល់។ កាលពីមុនអត់ស្គាល់សុទ្ធ។

[០៩:៥៣:៥៩]

**ស៖** អរគុណលោក។ លោកសាក្សី តើលោកអាចប្រាប់អង្គសវនាការបានទេថា តើលោកធ្លាប់ដែលឮគេនិយាយ ឬក៏ប្រាប់ពីរបៀបនៃការសម្លាប់អ្នកទោសទេ គេប្រើអីខ្លះទៅ? គេបាញ់ ឬក៏គេវាយ ឬក៏គេអី គេធ្វើរបៀបយ៉ាងម៉េច លោកដែលឮគ្នារបស់លោកនិយាយអីទេ?

**ឆ៖** បាទ រឿងការកាប់សម្លាប់ មានៗនៅក្នុងស-២១ហ្នឹង ឈ្មោះ អាចាន់ៗ ហ្នឹង គឺមាឌធំខ្មៅ ហើយអាហ្នឹងកម្លាំងណាស់។ គេចាត់តាំងឲ្យវាជាអ្នកវាយ វាយជាដំបង វាយកញ្ចឹងក អត់បានទៅបាញ់ អត់មានទៅកាប់សម្លាប់គ្នា កាប់ចាក់អីទេ គឺវាយទម្លាក់ក្នុងរណ្ដៅ។ ហ្នឹងគេប្រាប់ខ្ញុំ ហើយគេ -- ពេលគេមកពីសម្លាប់មកអីវិញ អាហ្នឹងគេមកតែងនិយាយអួតប្រាប់ ពេលបាយទឹកអីជួបគ្នាម្ដងម្កាលហ្នឹង គឺឮសូរនិយាយ បានខ្ញុំដឹង។

**ស៖** អរគុណលោក។ តើលោកមានដែលឮគេនិយាយថា វះពោះអ្នកទោសយកថ្លើម យកប្រមាត់ ឬមួយក៏លោកធ្លាប់ដែលឮគេនិយាយប្រាប់ថា អ្នកទោសហ្នឹង គេវាយនឹងដំបង ឬនឹងដែក ឬក៏យ៉ាងម៉េចលោក លោកអាចដឹងពីបញ្ហាហ្នឹង សូមលោករៀបរាប់ជូនតុលាការ?

[០៩:៥៥:៣៨]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី គួរតែប្រើប្រាស់សំណួរជាក់លាក់ ព្រោះអង្គជំនុំជម្រះស្ដាប់ពាក្យថា “ឮ” ដែលអង្គជំនុំជម្រះបានប្រាប់ គឺឮផ្ទាល់។ ឮផ្ទាល់ ឮថា ឮសំឡេង។ មិនមែនឮគេនិយាយថាទេ អាហ្នឹងគេហៅថា ចចាមអារ៉ាម វាប្រយោល ហើយគប្បីជ្រើសរើសសំណួរណាដែលវាជាក់លាក់ ឆ្លើយតបទៅនឹងកាតព្វកិច្ចរបស់សាក្សី។ យើងស្ដាប់ទៅ វាឮ សំណួរហ្នឹង វាឮពីគេហ្នឹង វាច្រើន។ វាអត់ខ្លឹមសារ វាអត់ប្រយោជន៍ ស្វែងរកការពិតទេ។ វា -- គេហៅភស្តុតាងចម្លង ឬក៏វាពាក្យចចាមអារ៉ាម កាលណាឮកាន់តែឆ្ងាយ វាទៅជាចចាមអារ៉ាម។

**លោកស្រី ជេត វណ្ណលី៖**

អរគុណលោកប្រធាន ខ្ញុំសូមបន្តសំណួរតទៅទៀត។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ខ្ញុំឆ្លងទៅបរិបទមួយទៀត ដែលនិយាយអំពីការលក្ខខណ្ឌនៃការឃុំខ្លួន។ លោកសាក្សី ខ្ញុំចង់ឲ្យលោកបញ្ជាក់ជូនអង្គសវនាការថា តើអ្នកទោសភាគច្រើនដែលត្រូវបញ្ជូន និងដឹកចេញនោះ ភាគច្រើនពេលយប់ ឬក៏ពេលថ្ងៃ?

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ សូមបញ្ជាក់ អ្នកទោសដែលបានដឹកចូលនៅស-២១ មិនថាយប់ ថាថ្ងៃទេ ប៉ុន្តែបើដឹកចេញ ភាគច្រើនយប់។

**ស៖** អរគុណលោក។ មួយទៀត ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា ពីម្សិលមិញ លោកបាននិយាយនៅមុខអង្គ -- ចំពោះមុខអង្គសវនាការថា អ្នកទោសដែលចូលនៅក្នុងស-២១ គេស្រង់យកប្រវត្តិរូបហើយនិងថតរូប។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា ហេតុអីបានជាគេថត? ហើយការថតរូបនេះ ថតរូបអ្នកទោសដែលនៅរស់ ហើយដល់ពេលអ្នកទោសដែលស្លាប់ហើយ គេមានថតសាកសពទេ លោក? ហើយមូលហេតុអី បានជាគេធ្វើអ៊ីចឹង ចាស?

[០៩:៥៨:០៦]

**ឆ៖** បាទ អ្នកទោសដែលឃើញចូលទៅ ឃើញថតរូប វាស់កម្ពស់ និងកត់ប្រវត្តិរូប។ ប៉ុន្តែក្នុងន័យយ៉ាងណា ខ្ញុំមិនអាចដឹងបានទេ ព្រោះខ្ញុំអត់យល់ដែរ។ ហើយពេលសម្លាប់ហើយ គឺគ្មានដែលឃើញរូបថតសាកសពទេ។

**ស៖** អរគុណលោក។ លោកនៅក្នុងស-២១ តើលោកដែលឃើញគេបញ្ចេញអ្នកទោសឲ្យចេញមកធ្វើការងារទេ ធ្វើពលកម្មធ្វើអីនៅខាងក្រោមទីឃុំឃាំងទេ លោក?

**ឆ៖** បាទ អ្នកទោសនៅស-២១ហ្នឹង មានតែប៉ុន្មាននាក់ដែលគេដោះលែងឲ្យធ្វើជាង ធ្វើការងារតាមជំនាញៗហ្នឹង មាន។ ឧទាហរណ៍ ដូចជា តភ្លើង តទឹក ឬក៏ជួសជុលអ្វីផ្សេងៗ អាហ្នឹង ឃើញមានប៉ុន្មានមានកងការពារយាមកាមតាម។

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថា អ្នកកងការពារដែលយាមអ្នកទោសហ្នឹង មានកាំភ្លើងទេ លោក?

**ឆ៖** បាទ កាំភ្លើងមានគ្រប់ដៃ លើកលែងតែអ្នកនៅឃាមក្នុងគុកបានអត់មានកាន់អាវុធចូល។ អ្នកនៅក្រៅមានគ្រប់ដៃ ទាំងក្មេងអាយុ១០ឆ្នាំឡើង។

**លោកស្រី ជេត វណ្ណលី៖**

អរគុណលោក។

**ប្រធានអង្គជំនុំ៖**

អស់ពេលហើយ។ បាទ ហើយលោក លោកស្រីចៅក្រម តើលោកស្រីមានបំណងចង់សួរសាក្សីរូបនេះទេ? មានបំណងចង់សួរ សូមអញ្ជើញ ចៅក្រម ហ្វេនស៍។

បាទ អញ្ជើញចៅក្រម ហ្សង់ម៉ាក ឡាវែន៍។

[១០:០០:២៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកសាក្សី ខ្ញុំមានសំណួរមួយចំនួនសួរបន្តបន្ថែមទៅលោកកាលពីព្រឹកមិញ បើសិនជាខ្ញុំយល់មិនខុសទេ នៅពេលដែលលោកឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា លោកបានឆ្លើយថានៅឆ្នាំ១៩៧៧, ៧៨ លែងមានជនជាតិវៀតណាមនៅប្រទេសកម្ពុជាទៀតហើយៗលោកបានបន្ថែមផងដែរថា "ជួនពួកគេបានចេញពីស្រុកខ្មែរអស់ ជួនពួកគេត្រូវបានសម្លាប់"។ តើលោកពិតជាបាននិយាយអ៊ីចឹងមែនទេ លោកអាចបញ្ជាក់ចម្លើយហ្នឹងឡើងវិញបានទេ?

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ ចម្លើយហ្នឹង ខ្ញុំនិយាយអ៊ីចឹងមែន។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានដែរឬទេថា <តើ>លោកមានដឹងអំពីបទបញ្ជា<ក្នុងបំណងធ្វើឱ្យប្រាកដថា>ជនជាតិវៀតណាមចេញពីប្រទេសកម្ពុជាទៅវិញ<ទេ? តើ>លោកដឹង<>ថាមានការចេញបញ្ជា<ណាមួយពាក់ព័ន្ធនឹងរឿងនេះ>ដែរឬទេ?

**ឆ៖** បាទ នៅសម័យនោះអត់មានបទបញ្ជាឱ្យដឹកប្រជាជនវៀតណាមទៅទេ ព្រោះៗប្រជាជនវៀតណាមនៅពីសង្គមពីសម័យលន់ នល់ – សម័យលន់ នល់ បោសសម្អាតអស់។ អ៊ីចឹងដល់ពេលសម័យ ប៉ុល ពត ចូលមកកាន់អំណាចនេះគឺអស់ហើយ អស់ជនជាតិវៀតណាមហើយ។

[១០:០២:២០]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** <តាមការចងចាំរបស់លោក> តើមានគោលនយោបាយ <ឬក៏>សេចក្តីសម្រេច<ដែលបានធ្វើឡើង>ទាក់ទងនឹងជនជាតិវៀតណាមដែលនៅ<សេសសល់ក្នុង>ប្រទេសកម្ពុជា ក្រោយពេលដែលខ្មែរក្រហមឡើងកាន់អំណាចហើយ<ទេ>?

**ឆៈ** បាទ ពីបញ្ហានេះ ខ្ញុំអត់ដែលបានឮពាក្យថាឲ្យដេញកងទ័ពវៀតណាម ឬមួយក៏បញ្ជូនកងទ័ពវៀតណាមចេញពីប្រទេសកម្ពុជាគឺមិនដែលបានឮ។

**សៈ** ប្រហែលជាមានបញ្ហាបកប្រែហើយ។ ខ្ញុំមិននិយាយពីយោធាវៀតណាមទេ ខ្ញុំនិយាយអំពី<អ្នកដែលជា>ជនជាតិវៀតណាម <អ្នក>មានដើមកំណើតជាវៀតណាម ដែលរស់នៅប្រទេសកម្ពុជា ហើយបើតាមលោកដឹងនោះ តើមាន<មនុស្សបែបនោះ>នៅប្រទេសកម្ពុជាដែរឬទេពេលដែលខ្មែរក្រហមឡើងកាន់អំណាចហើយ? ហើយបើសិនជាមាននោះ តើលោកមាន<>ដឹងឮអំពីគោលនយោបាយ ឬក៏បទបញ្ជាទាក់ទងទៅនឹងជនជាតិវៀតណាមដែលបន្តរស់នៅប្រទេសកម្ពុជាដែរឬទេ ពេលដែលខ្មែរក្រហមឡើងកាន់អំណាចហើយនោះ?

**ឆៈ** បាទ ពេលខ្មែរក្រហមកាន់អំណាចហើយហ្នឹងគឺជនជាតិវៀតណាមគឺមិនមានឮសួរគោលការណ៍អីថាដេញប្រជាជនវៀតណាមទេ ព្រោះជនជាតិវៀតណាមខាងសម័យលន់ នល់ គេបោសសម្អាតអស់ហើយតាំងពីមុនមក ដល់អ៊ីចឹងក្រោយមកក៏គ្មានជនជាតិវៀតណាម អ៊ីចឹងគោលការណ៍ក៏មិនឮសួរណែនាំឲ្យបោសសម្អាតជនជាតិវៀតណាមអីដែរ។

**សៈ** តើលោកមានឮពាក្យមួយដែលគេនិយាយថា "ក្បាលយួន ខ្លួនខ្មែរ" ដែរឬទេ? បើសិនជាលោកធ្លាប់ឮពាក្យហ្នឹងនេះ តើលោកយល់ពីខ្លឹមសារនៃពាក្យហ្នឹងដែរឬទេ ក្បាលយួនខ្លួនខ្មែរហ្នឹងមានន័យយ៉ាងម៉េចដែរ?

[១០:០៥:០៣]

**ឆៈ** បាទ ពាក្យឮសួរតែ "ក្បាលយួន ខ្លួនខ្មែរ" ទើបឮសួរសម័យឥឡូវ។

**សៈ** តើពាក្យហ្នឹងមានន័យយ៉ាងម៉េចដែរលោក "ក្បាលយួន ខ្លួនខ្មែរ" ហ្នឹង?

**ឆៈ** បាទ ពាក្យហ្នឹង ឮសួរតែ "ក្បាលយួន ខ្លួនខ្មែរ" អាហ្នឹងបានន័យថា គំនិតរបស់យួន ខ្លួនរបស់ខ្មែរ។

**សៈ** តើបុគ្គលទាំងអស់នេះ បើពួកក្បាលយួនខ្លួនខ្មែរនេះ ត្រូវបានចាត់ទុកជាខ្មាំងដែរឬទេ?

**ឆៈ** បាទ អាហ្នឹងខ្ញុំមិនហ៊ានវិនិច្ឆ័យទេ។

01249444



**សៈ** តើលោកមានធ្លាប់ឮអំពីសេចក្តីណែនាំ ទាក់ទងទៅនឹងអ្នកដឹកនាំរបស់បក្សកុម្មុយនីស្ត កម្ពុជា ដែលបានទៅរៀនសូត្រ ឬក៏ទទួលការបណ្តុះបណ្តាលនៅទីក្រុងហាណូយដែរឬទេ?

**ឆៈ** បាទ កិច្ចការធំៗទាំងនេះខ្ញុំអត់ដឹងទេ។

**សៈ** តើនៅពេលដែលលោករៀនសូត្រជាមួយ ឌុច និងជាមួយ សុន សេន លោកធ្លាប់បានឮ និយាយអំពីជនជាតិចាម ដែរឬទេ?

**ឆៈ** បាទ ជនជាតិចាម គឺមិនដែលឮសួរថាចំណាប់អារម្មណ៍អីឲ្យធំដុំទេ ពីព្រោះថាជនជាតិ ចាមកាលនោះ គេអត់មានបែងចែកជាចាម ជាខ្មែរទេ។

**សៈ** តើលោកធ្លាប់សួរអ្នកទោសចាមដែរឬទេ ឬក៏លោកមានដឹងថា មានជនជាតិចាមដែលជា អ្នកទោសនៅមន្ទីរស-២១ ដែរឬទេ?

[១០:០៧:៥៥]

**ឆៈ** បាទ ធ្លាប់មាន ប៉ុនគ្រាន់តែភ្លេចអស់ហើយ មិនដឹងឈ្មោះអីៗខ្ញុំអត់ដឹងទេ អត់ចាំ។

**សៈ** អ៊ីចឹងលោកមិនដឹងថា អ្នកទោសទាំងអស់ហ្នឹងត្រូវបានគេឃុំខ្លួននៅមន្ទីរស-២១ <ដោយ- សារមូលហេតុអីទេ> ឬក៏លោកដឹងពីមូលហេតុនៃការចាប់ពួកគាត់មកឃុំខ្លួននៅមន្ទីរស-២១ ដែរ?

**ឆៈ** បាទ ខ្ញុំដឹងថាមានជនជាតិចាមមកជាប់នៅស-២១ ប៉ុនគ្រាន់តែថា ឈ្មោះណា ឈ្មោះអី នៅណាអីណាខ្ញុំភ្លេចអស់ហើយ។

**សៈ** ដើម្បីយើងយល់គ្នាឲ្យច្បាស់ តើលោកផ្ទាល់ហ្នឹងលោកធ្លាប់សួរចម្លើយអ្នកទោសចាមដែរ ឬទេ?

**ឆៈ** ដែល។

**សៈ** តើលោកមានចាំដែរឬទេ ថាហេតុអ្វីបានជាជនជាតិចាមហ្នឹងត្រូវបានចាប់ខ្លួន?

**ឆៈ** មិនចាំទេ ពេលវេលាវែងពេក។

**សៈ** តើលោកមាននៅចាំសំណួរដែលលោកសួរទៅអ្នកទោសហ្នឹង ឬក៏សេចក្តីណែនាំដែលគេ ណែនាំដល់លោក ដើម្បីឲ្យលោកសួរចម្លើយអ្នកទោសហ្នឹងដែរឬទេ?

**ឆៈ** បាទ អត់ចាំទេភ្លេចអស់។

[១០:០៩:៤៩]

**សៈ** កាលពីព្រឹកមិញ លោកបាននិយាយថា លោកបានឃើញសាកសពអតីតមន្ត្រីរដ្ឋការនៃ

01249445



របប លន់ នល់ ដែល<>ត្រូវបានសម្លាប់។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកឃើញសាកសពនេះ នៅពេលណា? តើមុនពេលបែកភ្នំពេញ <>ឬក៏ក្រោយពេល<>ដណ្តើមបានក្រុងភ្នំពេញ ឬក៏ទាំងមុន ឬក៏ទាំងក្រោយ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ រឿងការឃើញសាកសព និងជញ្ជូនសាកសព នៅពេលវាយបែកនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ក្រោយគេវាយបែកហើយ គឺត្រូវចាប់ និងប្រមូលទាហានដែលនៅសេសសល់នៅក្រុងភ្នំពេញ និងខ្សែបណ្តាញហ្នឹងយកទៅដាក់នៅសាលាដំបូងខេត្តតាខ្មៅ សាលាដំបូងតាខ្មៅ។ ហើយយកទៅសម្លាប់ចោលនៅវត្តគោករលួស ហ្នឹងឃើញ។

**ស៖** តើលោកមានចាំចំនួនទាហានដែលគេប្រមូលផ្តុំនៅទីនោះដែរឬទេ? តើលោកនៅចាំឋានន្តរសក្តិនៃទាហានទាំងអស់នោះដែរឬទេ?

**ឆ៖** ទាហានជំនាន់ហ្នឹង ខ្ញុំចាំបានថាឈ្មោះ កេត ដារ៉ា ស័ក្តិ៥ ជាទាហានលន់ នល់ មានប្រពន្ធជនជាតិបារាំង ក្រៅពីហ្នឹង ខ្ញុំអត់ចាំទៀតទេ។

**ស៖** តើលោកមានចាំដែរឬទេ ថាតើទាហានទាំងអស់នោះច្រើនឬតិច ឬក៏គ្រាន់តែពីរបីនាក់ទេ? ឬក៏ <១០>នាក់? ឬក៏លើសពី<>ហ្នឹងទៅទៀត?

**ឆ៖** ចំនួនកាលហ្នឹង ខ្ញុំមិនប្រាកដទេ ប៉ុនដាក់ដឹកទៅពីរឡាន សេ.អ៊ឹម.សេ ទាំងប្រពន្ធ ទាំងកូន ទាំងទាហាន។ អ៊ីចឹងមួយពូជៗ ចាប់បានប៉ុន្មានយកទៅប៉ុណ្ណឹង។

[១០:១២:៣១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោង ដប់កន្លះសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១២ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:៣០:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅលោក ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី មុនពេលសម្រាកអម្បាញ់មិញនេះ លោកនិយាយអំពីការសម្លាប់ទាហាននៃរបបលន់ នល់ <ហើយជាពិសេស>លោកបាននិយាយពីការសម្លាប់<>លោកស័ក្តិ៥ម្នាក់ លោកបាននិយាយផងដែរថា ប្រពន្ធគាត់ជាជនជាតិបារាំង។ តើគេសម្លាប់<>លោកស័ក្តិ៥ហ្នឹង<ជាមួយគ្រួសារគាត់ ជាមួយ>ប្រពន្ធ<>គាត់<ទេ>?

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ សម្លាប់ទាំងអស់ ទាំងប្រពន្ធ ទាំងកូន។

**ស៖** តើលោកធ្លាប់បានឮអំពីបទបញ្ជាជាក់លាក់ទាក់ទងទៅនឹងការសម្លាប់ទាហានលន់ នល់ នៅពេលនោះដែរឬទេ?

**ឆ៖** បាទ នៅក្នុងសមរភូមិ សម្លាប់ទៅ សម្លាប់មក ចាប់បានសម្លាប់តទល់។ ធម្មតាធ្វើសង្គ្រាម សម្លាប់ទៅ សម្លាប់មកហ្នឹង។

**ស៖** ក៏ប៉ុន្តែអ្វីដែលលោកកំពុងតែរៀបរាប់ប្រាប់ខ្ញុំនេះ វាកើតឡើងមុនថ្ងៃ១៧ មេសា ឬក៏ក្រោយថ្ងៃ១៧ មេសា? ចង់និយាយថា មុនសម័យសង្គ្រាម ឬក៏ក្រោយសម័យសង្គ្រាម?

**ឆ៖** បាទ នៅក្រោយសង្គ្រាម១៧ មេសា ហ្នឹង ក្រោយប៉ុន្មានថ្ងៃទេ មិនមែនក្រោយយូរទេ។ អីចឹងកំពុងនៅក្តៅគគុកទេ ក្នុងរយៈពេលជ័យជម្នះហើយមួយខែក្រោយមកហ្នឹង ក៏មាននៅផ្ទុះកាំភ្លើងនៅតាមទីក្រុងភ្នំពេញដែរ។ អីចឹងការបោសសម្អាតប្រមូលទាហានដែលលាក់ខ្លួនបង្កប់នៅតាមអគារតាមអីហ្នឹង គឺយកទៅសម្លាប់ចោលហ្នឹង។ បើយើងមិនយកទៅសម្លាប់ចោល គេបាញ់យើង។

**ស៖** នៅពេលដែលលោកឮ ឬក៏ឃើញសាកសពលោកស័ក្តិ៥ហ្នឹងនោះ តើលោកឈរជើងនៅឯណាដែរ? លោកនៅតាខ្មៅ ឬក៏លោកនៅប៉ៃហ្ស៊ី ឬលោកនៅកន្លែងណាឲ្យច្បាស់លាស់តែម្តង?

[១០:៣៣:៥៧]

**ឆ៖** បាទ កាលហ្នឹង អត់មាននៅប៉ៃហ្ស៊ី នៅអីឯណាទេ ខ្ញុំនៅតាខ្មៅ។

**ស៖** នៅពេលដែលលោកនៅតាខ្មៅនោះ តើលោកមានឮគេនិយាយ ហើយអ្នកណាអ្នកនិយាយប្រាប់លោក អំពីការសម្លាប់យោធា លន់ នល់នេះ ទាហានលន់ នល់ហ្នឹង?

**ឆ៖** បាទ អត់មានឮសួរអ្នកណាទេ គឺឃើញជាក់ស្តែងហ្នឹងហ្មង គេឲ្យខ្ញុំយាម និងជញ្ជូនដាក់ឡាន យកទៅវៃចោលនៅវត្តគោករលួស។

**ស៖** បាទ ខ្ញុំនឹងសួរសំណួរមួយឡើងវិញ។ ខ្ញុំសួរលោកថា តើការសម្លាប់នុំង ការសម្លាប់ទ្រង់ទ្រាយប៉ុនណាដែរ ១០នាក់ ២០នាក់ លោកអាចជម្រាបជូនឲ្យបានច្បាស់លាស់បន្តិចបានទេ ចំនួនមនុស្ស?

**ឆ៖** ចំនួនមនុស្សកាលហ្នឹង ប្រហែលជា៥០នាក់ចុះក្រោម។

**ស៖** ឥឡូវ ខ្ញុំចូលប្រធានបទថ្មីមួយទៀត ខ្លីទេ។ នៅពេលដែលលោកធ្វើជាអ្នកសួរចម្លើយនៅមន្ទីរស-២១ តើលោកធ្លាប់ឮគេនិយាយអំពីឈ្មោះរបស់អ្នកដឹកនាំជាន់ខ្ពស់មួយចំនួនដែរឬទេ នៅក្នុងចម្លើយសារភាពរបស់អ្នកទោស?

**ឆ៖** ក្នុងចម្លើយសារភាពរបស់អ្នកទោស កន្លងមក មានតែឆ្លើយ ឮសួរតែដាក់ឈ្មោះ ហ៊ូ នឹម, ហ៊ូ យន់ ក្រោមៗហ្នឹងទៀតមក អ៊ីចឹងក្រៅពីហ្នឹង អត់មានឮសួរអីទេ។

[១០:៣៦:៣២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកសាក្សី។ ខ្ញុំអស់សំណួរហើយ លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅក្រុមសហមេធាវីការពារក្តី ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។ ដំបូងនេះ ផ្តល់វេទិកាជូនក្រុមសហមេធាវីការពារក្តីលោក នួន ជា។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ មុននឹងខ្ញុំចាប់ផ្តើម <ខ្ញុំមានការកត់សម្គាល់បឋមពីរ> ខ្ញុំសូម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អនុញ្ញាតពីលោកប្រធាន។ ជាបឋម ខ្ញុំយល់ថា យើងមានពេលយ៉ាងហោចណាស់ រហូតដល់ព្រឹកថ្ងៃចន្ទ ម៉ោងដប់សែសិប ដើម្បីឱ្យយើងមានពេលវេលាស្មើគ្នាទៅនឹងសហព្រះរាជអាជ្ញា ហើយនិងភាគីមួយទៀត។ ហើយចំណុចមួយទៀត ដែលខ្ញុំចង់បញ្ជាក់ជូន គឺថាជាមូលដ្ឋាន<នៃ>ការផ្តល់ព័ត៌មានថ្មីៗ ដល់អង្គជំនុំជម្រះនិងភាគីដទៃទៀត។ <>យើងបានដាក់ពាក្យបណ្តឹង គឺតាមវិធាន៩២ ដែល<មានលេខ> E399 គឺជាបណ្តឹង<>របស់ នួន ជា តាមវិធាន៩២ ដើម្បីប្រើឯកសារ ស-២១។ <នៅក្នុងញត្តិនេះ> យើង<តវ៉ា>ថា តាមសក្ខីកម្មរបស់ ឌុច <>ក្នុងឱកាសមួយចំនួននោះ យើងសន្និដ្ឋានថា កុយ ធួន <នៅពេលដែល>ត្រូវបានសួរចម្លើយដោយ ឌុច ដោយផ្ទាល់ មិនមែនជាកម្មវត្ថុនៃការប្រព្រឹត្តខុសឆ្គង ឬក៏អំពើទារុណកម្មទេ ដោយមូលហេតុនេះ គឺថាយើងមានមូលហេតុសមស្រប ដើម្បីជឿថា កំណត់ហេតុទាំងអស់នោះ គឺថាមិនមែនជាផលិតផលនៃអំពើទារុណកម្មទេ។ ហើយខ្ញុំជឿថា សហព្រះរាជអាជ្ញាមានពេលដល់ថ្ងៃចន្ទ ដើម្បីឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ខ្ញុំ។

<ប៉ុន្តែយ៉ាងណាក៏ដោយ វា>អាច<>ជាឯកសារដែលយើងនឹងប្រើ យកមកប្រឈមនឹងសាក្សីដែលកំពុងវត្តមាននៅទីនេះ។ ដូច្នេះ ខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះ និងភាគីជាមុន ដូច្នេះ។

[១០:៣៩:១៤]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំក្រោកឡើងនេះ ពីព្រោះខ្ញុំយល់ឃើញថា ការពិភាក្សាអំពីខ្លឹមសារចម្លើយសារភាព <មិន>ត្រូវយកមកនិយាយនៅចំពោះមុខសាក្សីរូបនេះទេ។ អ៊ីចឹង យើងខ្ញុំសូមអនុញ្ញាតឆ្លើយទៅនឹងសំណើមួយចំនួនរបស់មេធាវី នួន ជា ពេលរសៀលនេះ។ ទាក់ទងនឹងពេលវេលាគាត់សុំនោះ ខ្ញុំគិតថាគាត់ច្រឡំហើយ គាត់មិនអាចសួរដល់ម៉ោងដប់សែសិបនាទី<នៅថ្ងៃចន្ទ>នោះទេ <ដោយមានមូលហេតុពីរ>។ ដោយថាទី១ <>កាលពីម្សិលមិញ យើងចាប់ផ្តើមសួរសាក្សីនេះ គឺម៉ោងប្រាំបួនកន្លះហើយ គឺថាកន្លះម៉ោងក្រោយពេលចាប់ផ្តើមសវនាការ ព្រោះ<មានការ>ពិភាក្សា<ផ្សេងៗ។> ហើយ<ទី២ ដោយសារ>ចៅក្រម ឡាវែន៍ បានចោទសំណួរខ្លះដែរ<ទៅកាន់សាក្សីនេះនៅម៉ោងដប់ព្រឹកមិញនេះ> ហើយចៅក្រម ឡាវែន៍ គាត់មិនមែនជាសហព្រះរាជអាជ្ញាទេ ដូច្នេះ<វាមិនសមរម្យឡើយងក្នុងការនិយាយថា> យើង<>បានប្រើពេលវេលា<របស់យើង>ដល់ម៉ោងដប់សែសិបនាទីនោះ <>។ អ៊ីចឹងយើងត្រូវដកពេលវេលាដែលលោកចៅក្រម ឡាវែន៍ ប្រើ ហើយនិងពេលវេលាដែលយើងបាត់បង់កាលពីម្សិលមិញ<ចេញ ដែលមានន័យថា> គាត់<>អាចសួរទៅដល់ស្អែកម៉ោងប្រាំបួនកន្លះ។

<នោះពិតជាមានប្រយោជន៍ច្រើនសម្រាប់យើង ដើម្បីព្យាយាមបញ្ចប់នៅថ្ងៃនេះ ទោះបីជាយើងត្រូវធ្វើលើសម៉ោងបួនក៏ដោយ។ សូមអរគុណ>លោកប្រធាន។

**<លោក វ៉ិចទ័រ កូប៉េ៖>**

<តើខ្ញុំអាចឆ្លើយតបបានទេ -- អូ!>

[១០:៤០:៥៩]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់ខ្លីមួយ ដើម្បីជម្រាបជូនថា ដើមបណ្ដឹងរដ្ឋប្បវេណីចង់ឆ្លើយតបទៅនឹងសំណើរបស់ក្រុម នួន ជា ទាក់ទងទៅនឹងមូលដ្ឋាននៃវិធាន៩២។ យើងជំទាស់ទៅនឹងការប្រើប្រាស់ចម្លើយសារភាពទាំងបីដែលបានលើកឡើងនៅក្នុងសំណើរបស់គាត់។ ចម្លើយរបស់យើងធ្វើហើយៗ ហើយកំពុងតែបកប្រែ ហើយនិងដាក់ជូនអង្គជំនុំជម្រះនៅក្នុងពេលវេលាសមស្រប គឺមុនថ្ងៃចន្ទ។ ដូច្នេះ ខ្ញុំសូមឲ្យចៅក្រមកុំអនុញ្ញាតឲ្យក្រុម នួន ជា ប្រើចម្លើយសារភាពទាំងអស់នេះដរាបណា ភាគីមិនទាន់បានដាក់ចម្លើយតបរបស់ខ្លួន។ ដូច្នេះ ខ្ញុំសូមជម្រាបតុលាការក្នុងពេលនេះតែម្ដងថា យើងបដិសេធមិនឲ្យប្រើចម្លើយសារភាពទាំងបីនេះទៀត ដោយសារថា ក្រុម នួន ជា មិនបានផ្ដល់ភស្តុតាងឲ្យគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងហានិភ័យនៃការប្រើប្រាស់ចម្លើយសារភាពនៃមន្ទីរស-២១ នេះ<ដែលថា វាមិនបានមកដោយសារការធ្វើទារុណកម្មនោះទេ> លោកប្រធាន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមអន្តរាគមន៍ទាក់ទងនឹងរយៈពេលវេលាដែលចែកឲ្យភាគី។

ខ្ញុំឃើញថារហូតដល់ពេលនេះ យើងដំណើរការលើមូលដ្ឋានពេលវេលាស្មើគ្នា ដែលៗចៅក្រមចែកឲ្យ <រវាងសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងមេធាវីការពារក្ដី។ ប៉ុន្តែការផ្ដល់ជូនបែបនោះ នៅពេលដែលក្រុម> មេធាវី ខៀវ សំផន សួរសំណួរក្រោយគេ។ អ៊ីចឹងយើងមិនមានសំណួរអ្វីទេ ហើយយើងមិនសុំពេលវេលាថែមនោះទេ។ ដូច្នេះ នៅថ្ងៃនេះមេធាវី ខៀវ សំផន យើងមានសំណួរសម្រាប់សាក្សីនេះ។ <នៅក្នុងស្ថានភាពនេះ> ការគណនាប្រហាក់ប្រហែលរបស់ព្រះរាជអាជ្ញានេះ យើងមិនអាចទទួលយកបានទេ ហើយយើង<>សុំទទួលយកពេលវេលាដែលបែងចែកឲ្យយើងតាមដែលបានគ្រោងទុករបស់អង្គជំនុំជម្រះគឺថា បួនវគ្គហ្នឹង ព្រោះថានេះមាននៅក្នុងប្រតិចារឹកកាលពីម្សិលមិញ។ <មានការ>សុំពេលវេលាបន្ថែម <ក្រៅពីពេលវេលាដែល>ព្រះរាជអាជ្ញាគាត់បាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01249450



ប្រើប្រាស់<កាលពីម្សិលមិញ>។ អ៊ីចឹង<ពេលវេលាដែលបានកំណត់ពីដំបូងសម្រាប់មេធាវីការពារក្តី គួរតែត្រូវបានប្រើប្រាស់ដោយពេញលេញដោយមេធាវីការពារក្តី។ ដូច្នេះ>ម៉ោងប្រាំបួនកន្លះហ្នឹងមិន ត្រឹមត្រូវទេលោកប្រធាន។

**<លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖>**

<សូមទោសលោកប្រធាន តាមពិតទៅ -->

[១០:៤៣:៤៨]

**ប្រធានអង្គជំនុំ៖**

យើងសម្រេចដូច្នេះថា ទី១ រឿងសំណើដរាបណាអង្គជំនុំជម្រះមិនបានទាន់បានសម្រេចក្នុង កម្រិតផ្ទាល់មាត់លើសំណើទេ សំណើនោះគឺមិនអាចយកមកប្រើប្រាស់បានទេ ទោះបីករណីណាក៏ ដោយ។ ទី២ សំណើទាំងឡាយ គឺទាល់តែយើងអនុញ្ញាតឲ្យធ្វើជាផ្ទាល់មាត់ ហើយធ្វើការដូចសព្វដង ស្តាប់នូវសារណាផ្ទាល់មាត់ភាគី រួចទើបយើងចេញសេចក្តីសម្រេចៗ បណ្តោះអាសន្ន ជាផ្ទាល់មាត់ ឬ លាយលក្ខណ៍អក្សរ គឺនិងអនុវត្តចាប់ពីពេលផ្សព្វផ្សាយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ នេះគ្រាន់ តែជាការបង្ហាញទេ មិនមែនជាការយកបញ្ហានេះមកចាត់ការទេ។ បញ្ហាមួយទៀត ប្រសិនបើឯកសារ ណា ឬក៏លើកហេតុផលណាដែលវាមិនត្រឹមត្រូវតាមនីតិវិធី ភាគីអនុវត្តដូចជាច្រើនឆ្នាំមកហើយក្នុងការ ជំទាស់ទៅលើបញ្ហាទាំងអស់នេះ ដើម្បីឲ្យអង្គជំនុំជម្រះពិចារណាសម្រេច។ ទោះបីយ៉ាងណាក៏ដោយ យើងបានកត់សម្គាល់ពីការប្រឹងប្រែង ប្រុងប្រយ័ត្នខ្ពស់ចំពោះភាពពាក់ព័ន្ធទៅនឹងការប្រើប្រាស់បណ្តា ឯកសារភស្តុតាងទាំងឡាយដែលបានមកពីការធ្វើទារុណកម្ម ទោះបីជាយើងគ្រប់គ្រងមិនបាន១០០ ភាគរយក៏ដោយ ក៏យើងមានការប្រុងប្រៀបតាំងពីមុនរហូតដល់ពេលនេះ គឺប្រឹងប្រែងគ្រប់ឱកាស និង គ្រប់ពេលវេលាទោះបីវាលេចចេញថ្មីៗក៏ដោយ ក៏យើងប្រឹងប្រែងជាបន្តទៅទៀត។

[១០:៤៥:២៤]

ដូច្នេះការបារម្ភមិនមែនដាក់បន្ទុកមកលើអង្គជំនុំជម្រះទេ ភាគីមិនមែនឲ្យអង្គុយធ្វើអីទេ ហើយ កន្លែងមកខ្លួនតែងតែជំទាស់តវ៉ាជាហូរហែ។ ដូច្នេះអនុវត្តរបៀបនេះ មិនមែនចេះតែប្រើពេលវេលាឥត ប្រយោជន៍ធ្វើឲ្យខាតពេលវេលាដូច្នេះទេ ហើយចំណែកឯពេលវេលាសម្រាប់ភាគី យើងគណនាច្បាស់ លាស់ណាស់ ម៉ោងប៉ុន្មានរំខានប៉ុន្មាន គឺយើងដកបូកច្បាស់លាស់ណាស់ លើកលែងតែភាគីប្រើប្រាស់ ពេលវេលាឥតប្រយោជន៍មិនសម្តែងឲ្យក្នុងការដេញដោលស្វែងរកការពិត នោះទើបយើងបញ្ឈប់មិនឲ្យ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដេញដោល ឬក៏ប្រើប្រាស់ពេលវេលាហួសពីពេលវេលាដែលយើងបានកំណត់ឲ្យ។ ដូច្នេះ អំមិញនេះគឺបានកំណត់ឲ្យ៣០នាទី មុនប្រាប់មុនថាដើមបណ្តឹងរដ្ឋប្បវេណីមានពេល៣០នាទី ច្បាស់លាស់ណាស់! ដូច្នេះត្រូវអនុវត្តបែបនេះ យើងប្រឹងប្រែងគ្រប់គ្រង និងកំណត់ពេលវេលានេះឲ្យបានច្បាស់លាស់ សូម្បីតែចូលរាល់ថ្ងៃនេះគឺយើងចូលច្បាស់ ហើយបើខាតបង់បន្តិចបន្តួច យើងតែងប្រើប្រាស់វិធីមួយគេហៅថា ជួសជុលឡើងវិញ។ ដូចអំមិញនេះយើងបានអូសបន្លាយពេលវេលាធ្វើមិនដឹងមិនឮរហូតដល់ប្រាំនាទីលើសពីការឈប់សម្រាកធម្មតា។

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ ឱលោកប្រធាន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងដើម្បីឲ្យច្បាស់ក្នុងកំណត់ត្រា ក្នុង<ករណីវាមិនច្បាស់ក្នុង>ភាសាអង់គ្លេស ប្រហែលជា<ភាសា>ខ្មែរច្បាស់ហើយ។ អ៊ីចឹងលោកមេធាវីកុំទាន់ប្រើឯកសារដែលលោកដាក់ក្នុងសំណើ រហូតទាល់តែមានសេចក្តីសម្រេចជាមុនសិន។ <ហើយការសម្រេចនោះនឹងធ្វើនៅថ្ងៃចន្ទ ក្រោយពេលភាគីទាំងអស់មានឱកាសបានស្តាប់រួចហើយ។>

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំនឹងធ្វើដូច្នោះ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំនឹងចាប់ផ្តើម និងសួរសំណួរបន្តពីភាគីខាងដើម បន្ទាប់ពីសម្រាកគឺទាក់ទងទៅនឹងការសម្លាប់អតីតមន្ត្រី ឬក៏ទាហានលន់ នល់។ ខ្ញុំបានឮលោកនិយាយបញ្ជាក់ពីឈ្មោះបុគ្គលម្នាក់ជាវរសេនីយនោះ ជាខ្មែរហ្នឹងមានឈ្មោះថា កេត ដារ៉ា។ សូមលោកបញ្ជាក់ឈ្មោះអានឈ្មោះម្នាក់ហ្នឹងឡើងវិញ បាទ។

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ ខ្ញុំឮសួរគេហៅថា កេត ដារ៉ា ហើយសួរទៅក៏ថាឈ្មោះ កេត ដារ៉ា ដែរ។

**ស៖** តើលោកដឹងថាអតីតមេបញ្ជាការ លន់ នល់ <>ដែលឈរជើងនៅតាខ្មៅ<>កាលនោះ

ឈ្មោះអ្វី?

[១០:៤៨:៣៥]

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ ព្រោះ កេត ដារ៉ា ហ្នឹងចាប់បានពីកន្លែងពេទ្យចិនទៅ យកទៅដាក់នៅកន្លែងសាលាដំបូងតាខ្មៅ ព្រោះខ្ញុំឈរជើងនៅសាលាដំបូងតាខ្មៅនៅយាមកាមនៅកន្លែងហ្នឹង។

**ស៖** លោកប្រធានដោយសារប្រធានបទនេះគឺថាផ្ទុះឡើងដោយមិនបានរំពឹងទុកសោះ ឯកសារដែលខ្ញុំចង់បង្ហាញ<>ជូនបង្ហាញសាក្សី គឺមិនស្ថិតនៅក្នុង*អ៊ីនធីហ្វេស* ទៀត <ប៉ុន្តែខ្ញុំគិតថាឯក-សារនេះភាគីទាំងអស់ស្គាល់ច្បាស់ណាស់។> គឺឯកសារ E3/832 គឺជាបញ្ជីដែលមាន<ឈ្មោះ> មនុស្ស១៧នាក់នៅលើនោះ <>គឺជាឈ្មោះរបស់ជនក្បត់<១៧នាក់>នៅក្នុងភូមិភាគពិសេស ឯកសារនេះចុះហត្ថលេខា ឬក៏សរសេរដោយ ពីន ជាមេបញ្ជាការកងពល៧០៣។ <ហើយនៅលើ>ឯកសារ<នោះ> ERN<ភាសាអង់គ្លេស> 00068921, ខ្មែរ 00068920។ ហើយខ្ញុំនឹងផ្តល់ជាភាសាបារាំងនៅពេលបន្តិចទៀតនេះ។ នៅ<ក្រោម>ចំណុចទី២ <មានការ>បញ្ជាក់<មួយពី>មេបញ្ជាការកងទ័ព<ស្រុក>តាខ្មៅ។ <ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំសូម>បង្ហាញសាក្សី<នូវ>ឯកសារនេះ <ហើយសួរគាត់>ថាតើគាត់ស្គាល់ឈ្មោះអ្នកណាផ្សេងទៀតនៅលើបញ្ជីនេះដែរឬទេ? ខ្ញុំសូមអនុញ្ញាតបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ជាពិសេសនៅត្រង់លេខពីរ ដូចខ្ញុំបញ្ជាក់នោះ <ខាំ ភួង> បាទ គឺជាវរសេនីយ៍<ទោ> ជាមេបញ្ជាការនៅតាខ្មៅ។ ហើយសមាជិកក្រុមគ្រួសារ<របស់គាត់ទាំងអស់>ជា<> ជនក្បត់ ហើយអ្នកនៅក្នុងក្រុមរបស់គាត់ហ្នឹង គឺសុទ្ធជាមនុស្សឃោរឃៅ គេបញ្ជាក់អ៊ីចឹង។ តើលោកធ្លាប់ឮឈ្មោះថា <ខាំ ភួង> តាមចំណុចនៅក្នុងលេខ២?

[១០:៥២:២០]

**ឆ៖** បាទ អត់ដែលឮទេ ឈ្មោះទាំងអស់នេះ។

**ប្រធានអង្គជំនុំ៖**

ខាំៗ ភួង ពាក្យខ្មែរនេះ ឈ្មោះៗ ឈ្មោះ ភួង។ ដែលឮទេ ខាំ ភួង?

**លោក ប្រាក់ ខន៖**

**ឆ៖** អត់ៗដែលឮ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដើម្បីឲ្យប្រាកដខ្លួនឯងផ្ទាល់ លោកមិនបានចូលរួមក្នុងការសម្លាប់នៅទីនោះទេ។ តើអ៊ីចឹងមែនទេលោកសាក្សី?

**ឆ៖** បាទ។

**ស៖** តើលោកស្គាល់នរណាជាអ្នកធ្វើអំពើហ្នឹងទេ?

**ឆ៖** បាទ ស្គាល់កាលហ្នឹងមានឈ្មោះ អឿន ជាមេបញ្ជាការវរសេនាតូច១៣៨ ក្នុងកងពល ៧០៣ ភូមិភាគពិសេស។

**ស៖** តើអ្នកណាជាអ្នកបញ្ជា អឿន ឲ្យធ្វើអំពើនេះ?

**ឆ៖** បាទ ខ្ញុំដឹងតែត្រឹមហ្នឹង ទៅលើទៀតអត់ដឹង។

**ស៖** តើលោកដឹងថា អឿន ប្រព្រឹត្តអំពើហ្នឹងក្នុងការជាអំពើសងសឹកដែរឬទេ?

**ឆ៖** បាទ រឿងនេះខ្ញុំមិនដឹងយ៉ាងម៉េចទេ ប៉ុន្តែគ្រាន់តែឃើញគាត់បញ្ជាឲ្យកាប់ ឲ្យសម្លាប់អ្នកល្អើយសឹក។

[១០:៥៥:០៦]

**ស៖** ខ្ញុំនឹងត្រឡប់មកបញ្ហានេះ នៅពេលក្រោយទៀត ហើយប៉ុន្តែខ្ញុំនឹងត្រឡប់ទៅសំណួរពីដំបូងខ្លួនឯងវិញ។ ដំបូងគឺថា ខ្លួនឯងលោកផ្ទាល់ហ្នឹងគឺជាសមាជិកនៃកងពល៧០៣ <ឬកងពល១២ តាមដែលគេស្គាល់នៅឆ្នាំ១៩៧៥។> លោកជាសមាជិកនៃកងវរសេនាតូចទី១៤៣ <តើត្រឹមត្រូវ>ដែរឬទេ?

**ឆ៖** បាទ ខ្ញុំជាៗយុវជន មិនមែនជាសមាជិកនៅកងពលទេ។ ជាយុវជន ជាយុទ្ធជនមួយរូបដែលនៅក្នុងកងពល៧០៣ ហ្នឹង ហើយនិងក្នុងវរសេនាតូចៗ ភ្លេចអស់ហើយ នៅវរសេនាធំ៣៨ កងកាំភ្លើងធំ។

**ស៖** នៅក្នុងសៀវភៅដែលនិយាយអំពីកងពល៧០៣ ឯកសារ E3/2117, អង់គ្លេស ERN 0008130 *(ស៊ីក)* ខ្ញុំមិនមាន<ERN>ជាភាសាខ្មែរទេ<> លោកប្រធាន ខ្ញុំនឹងផ្តល់ក្នុងពេលឆាប់ៗ។ នៅលើទំព័រនេះ លោកសាក្សី គេនិយាយថា លោកគឺជាអតីតយុទ្ធជននៅក្នុងវរសេនាតូចទី១៤៣ នៃកងពល<ទី១២>។ តើគេបញ្ជាក់អ៊ីចឹង ខ្លឹមសារហ្នឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ កងពល៧០៣ ត្រឹមត្រូវហើយ ប៉ុន្តែក្នុងវរសេនាតូច ខ្ញុំមិនចាំទេ ភ្លេចអស់ហើយ។

**ស៖** តើលោកជាសមាជិកដែលថាជាអតីតយុទ្ធជននៅក្នុងវរសេនាតូចទី១៤៣ នៃកងពល <១២> តើអាហ្នឹងត្រូវឬក៏ខុស?

**ឆ៖** បាទដូចខ្ញុំបញ្ជាក់អ៊ីចឹង លេខកងវរសេនាតូចខ្ញុំភ្លេចហើយ មិនដឹងជាលេខប៉ុន្មានទេ ប៉ុន្តែខ្ញុំនៅក្នុងកងពលហ្នឹងហើយ។

[១០:៥៧:៥៧]

**ស៖** តើលោកធ្លាប់ចូលរួមក្នុងការប្រយុទ្ធដែរឬទេ? <ខ្ញុំជឿថា កាលពី>ម្សិលមិញលោកថា <លោក>បានចូលរួមក្នុងការប្រយុទ្ធ។ <តើលោកបានចូលរួម>ក្នុងការប្រយុទ្ធយ៉ាងសកម្មជាមួយទាហានលន់ នល់ នៅក្នុងពេលរំដោះទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់ចូលប្រយុទ្ធតាំងពីឆ្នាំ១៩៧៣, ៧៤, ៧៥ រហូតទល់ពេលចូលមកដល់ទីក្រុងភ្នំពេញ។

**ស៖** នៅក្នុងពេលប្រយុទ្ធសកម្មនោះថាតើ<លោកធ្លាប់>ឃើញ<មិត្តរួម>អាវុធនៅក្នុងកងរបស់លោកហ្នឹងត្រូវរបួសឬក៏ស្លាប់នៅក្នុងពេលនោះដែរឬទេ?

**ឆ៖** បាទ ឃើញរបួសស្លាប់ជាបន្តបន្ទាប់។

**ស៖** ចុះអ្នកដែលអ្នកទទួលរងរបួសតែមិនស្លាប់ តើគេធ្វើដូចម្ដេចបន្ទាប់មកនោះ? <តើលោកមានស្គាល់ពួកគេណាម្នាក់ទេ?>

**ឆ៖** បាទ អ្នករងរបួសដែលមិនស្លាប់ គឺយកទៅមន្ទីរពេទ្យខាងក្រោយទៅ សមរភូមិក្រោយ ដល់ពេលជា ត្រឡប់មកវិញ មកខាងកងវិញដដែល។

**ស៖** តើលោកដឹងថា សមមិត្តដែលរបួសនោះទទួលបានការបញ្ចូលឈាមដែលសមមិត្តផ្សេងទៀតបរិច្ចាគនៅក្នុងមន្ទីរពេទ្យ<>នៅសមរភូមិក្រោយមកទេ?

**ឆ៖** បាទ រឿងនេះ ខ្ញុំមិនសូវដឹងច្បាស់ទេ តែប៉ុន្តែកាលនោះ ដូចគ្មានឮសួរថាការបញ្ចូលឈាមបញ្ចូលអីទេ ច្រើនការវះកាត់នៅៗនៅក្នុងសមរភូមិ វះកាត់ដោយភ្លើងពិល ភ្លើងអី ក្នុងសមរភូមិ។ អ៊ីចឹងមិនមានការវះកាត់អីធំដុំទេ។ សូម្បីតែខ្ញុំរបួសស្លឹកត្រចៀកហ្នឹង ក៏វះនៅដែរ។

**ស៖** តើរូបលោក ហើយនិងសមមិត្តរបស់លោកនៅក្នុងវរសេនាតូចទី១៤៣ហ្នឹង ធ្លាប់អង្គការឬក៏អ្នកណាប្រកាស ឬក៏សូមឱ្យផ្ដល់ ឬក៏បរិច្ចាគឈាមដែរឬទេ?

**ឆ៖** បាទ ពីបញ្ហានេះ អត់ដែលមានទេ។

**សៈ** តើលោកធ្លាប់ឮ<យុទ្ធជននៅក្នុង>កងពលទី១២<ឈ្មោះ> ម៉េង ហាក់<>ទេ?

**ឆៈ** បាទ កងពល១២ហ្នឹងហើយ ជាកងពលរបស់ខ្ញុំកាលពីមុន៧០៣ ប៉ុន្តែ ម៉េង ហាក់ ខ្ញុំអត់ដែលឮទេ។

**សៈ** តើលោកធ្លាប់ឮ<ឬទេ>ថា ឌុច ខ្លួនឯង<បាន>ពាក់ព័ន្ធនៅក្នុងការ<>ប្រយុទ្ធ<យ៉ាងសកម្មនៅក្រោយខែមេសា ឆ្នាំ១៩៧៥ នៅ>ទីក្រុងភ្នំពេញ<>?

[១១:០២:០៧]

**ឆៈ** បាទ ចំពោះ ឌុច ខ្ញុំមិនដែលឮសួរគាត់និយាយរៀបរាប់ពីការធ្វើសមរភូមិ ឬក៏អីណាអីណី គាត់និយាយតែរឿងក្រសួងមន្ទីរដែលគាត់ធ្លាប់ពាក់ព័ន្ធផ្នែកខាង ផ្នែកសន្តិបាល បើរឿងខាងវាយសមរ-ភូមិ ក៏គាត់មិនដែលឮសួរនិយាយ។

**សៈ** លោកបញ្ជាក់ថា លោកមិនដែលបានចូលរួមក្នុងការសម្លាប់មនុស្សទេ។ តើវរសេនាតូចរបស់លោក <ធ្លាប់>ពាក់ព័ន្ធនៅក្នុងការសម្លាប់ប្រជាជន<វៀតណាម>ដែរឬទេ <ឬក៏ប្រជាជន>នៅក្នុងប្រទេសកម្ពុជា<ដែល>មានប្រវត្តិជាវៀតណាម<>?

**ឆៈ** បាទ ចំពោះជនជាតិវៀតណាម ក៏ក្នុងកងវរសេនាតូចខ្ញុំ ក៏មិនដែលមានការប៉ះទង្គិចគ្នាដែរ ព្រោះនិយាយរួម មិនដែលបានសម្លាប់កង ប្រជាជនវៀតណាម ឬក៏កងទ័ពវៀតណាម។

**សៈ** ព្រឹកមិញនេះ លោកបាននិយាយអំពីការបោសសម្អាត<>ជនជាតិវៀតណាមដោយ លន់ នល់ -- ដោយ<កងកម្លាំង> លន់ នល់ មុនឆ្នាំ១៩៧៥។ តើលោកចង់និយាយដូចម្ដេច ពាក្យថា "បោសសម្អាត" នៅពេលនោះ?

**ឆៈ** បាទ ពាក្យថា "បោសសម្អាត" ពេលនោះ ព្រោះកាលពីសម័យ៧០ – ១៩៧០ លន់នល់មានគោលការណ៍បោសសម្អាតប្រជាជនវៀតណាមចេញពីទឹកដីកម្ពុជាហ្នឹង អស់ជាបន្តបន្ទាប់ហើយ។ ជាក់ស្ដែងដូចនៅខាងកោះកន្ធាយ ក្រោមអ្នកលឿងដែលជាសមរភូមិមួយដែលខ្ញុំបានចូលទៅប្រយុទ្ធនៅហ្នឹង ឃើញតែសាកសព ឃើញតែឆ្អឹងនៅ ហើយនិងផ្ទះសម្បែងដែលជនជាតិវៀតណាមធ្លាប់រស់នៅហ្នឹង ចូលទៅសម្លាប់ចោលអស់នៅហ្នឹង។ ហើយដល់សួរគេទៅថា ជាផ្ទះវៀតណាម កងទ័ពលន់នល់ចូលទៅសម្លាប់ចោល។ អ៊ីចឹងឃើញតែឆ្អឹងនៅពេញផ្ទះ ពេញសម្បែងហ្នឹង នៅផ្ទះខ្ទមតូចៗ នៅកណ្ដាលកោះ។

**សៈ** តើលោកដឹង ថាតើមានការកាប់សម្លាប់ច្រើន ឬក៏ប៉ុន្មានកន្លែង តើលោកបានឃើញការ

សម្លាប់ជនជាតិវៀតណាមហ្នឹងដោយខ្លួនឯងទេ កាលនោះ?

[១១:០៥:០៣]

**ឆ៖** បាទ ខ្ញុំមិនបានឃើញគេសម្លាប់ទេ ប៉ុន្តែឃើញជាឆ្អឹង។ ឃើញថាឆ្អឹងនៅនឹងកន្លែងផ្ទះបាក់បែកទ្រុឌទ្រោម ដែលពេលដែលខ្ញុំធ្វើសមរភូមិនៅកោះកន្ទាយក្រោមអ្នកលឿង។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅដល់រយៈពេល មុនពេលដែលគេបញ្ជូនលោកទៅធ្វើជាអ្នកយាមនៅ ស-២១។ តើនៅពេលណាមួយ លោកបានទៅធ្វើ<>ស្រែនៅព្រៃស ដែរឬទេ?

**ឆ៖** បាទ ពេលរំដោះភ្នំពេញហើយ បន្តបន្ទាប់មកហ្នឹង គេ -- ពេលថាសភាពការណ៍នៅទីក្រុងភ្នំពេញស្ងាត់ ការបាញ់បោះហើយហ្នឹង ដល់ពេលខែធ្វើស្រែហ្នឹង គេបញ្ជូនកងរបស់ខ្ញុំហ្នឹងឲ្យទៅធ្វើស្រែនៅព្រៃស នៅនឹងមុខវត្តធម្មតី។ ធ្វើថ្ងៃអ៊ីចឹងទៅ យប់មកដេកនៅភ្នំពេញវិញ។ ព្រលឹមឡើងទៅ យប់មកជារៀងរាល់ថ្ងៃ។

**ស៖** តើលោកនៅព្រៃស<រយៈពេលសរុបប៉ុន្មាន? តើលោកនៅព្រៃស>រហូតដល់ពេលគេមក<>នៅស-២១ ឬ?

**ឆ៖** បាទ នៅព្រៃសហ្នឹងនៅធ្វើស្រែទេ ប៉ុន្តែកន្លែងទីស្នាក់ការដែលនៅហ្នឹង គឺនៅឯក្បាលថ្នល់។ ដល់ក្រោយមកៗ បានមានការរើសចម្រាញ់ចេញពីកងទ័ពនោះ ចូលមកសាលាស៊ីសុវត្ថិ។ សាលាស៊ីសុវត្ថិហ្នឹង គឺមកឲ្យសម្រាកនៅ គ្នាជាច្រើន ហើយគេបានប្រាប់ថា កម្លាំងទាំងអស់ហ្នឹង គឺត្រៀមទៅដាក់ស្ថានទូតនៅតាមប្រទេសនានា ហើយនិងមួយផ្នែកទៀត ទៅខាងពីឡុត។ រីឯ គុកទួលស្លែង គឺមិនមានការប្រកាសទេ។ ដល់អ៊ីចឹង ខ្ញុំនៅរង់ចាំហ្នឹង អស់រយៈពេលជាយូរ បានមានសេចក្ដីសម្រេចឲ្យខ្ញុំចេញមកកន្លែងគុកទួលស្លែង។

**ស៖** តើរយៈពេលនោះ មានរយៈពេលប្រហែលដល់១ឆ្នាំទេ <ឬក៏យូរជាងនោះ> ពេលលោកធ្វើស្រែនៅព្រៃសនោះ?

**ឆ៖** បាទ ធ្វើស្រែនៅព្រៃសនោះ ក្នុងមួយរដូវ។ មួយរដូវហ្នឹង បានធ្វើហើយហ្នឹង ក៏កាលហ្នឹងដូចមិនបានច្រូតទេ បានតែពេលដកស្ទូង។

[១១:០៨:៣៩]

**ស៖** តើលោកធ្លាប់ដែលឃើញអតីតយុទ្ធជនដែលគេយកមកឲ្យរៀនសូត្រលត់ដំនៅព្រៃសដែរទេ?

**ឆ៖** បាទ ព្រៃស កាលខ្ញុំទៅហ្នឹង គឺអត់ទាន់មានមន្ទីរឃុំឃាំង មន្ទីរអប់រំទេ ទៅធ្វើស្រែនៅហ្នឹងនោះ ព្រោះអាហ្នឹង អត់ទាន់បង្កើតគុកទួលស្លែងផង។ អ៊ីចឹង អត់មានឃើញទេ។

**ស៖** តើលោកដឹងទេ មន្ទីរអប់រំកែប្រែព្រៃសនេះ គេចាប់ផ្ដើមបង្កើតនៅពេលណា?

**ឆ៖** ពេលខ្ញុំមកនៅស-២១ ក្រោយៗមក បានទើបឮសួរថា មានស-២៤។ នៅស្រែ មាន ហ៊ុយ ស្រែ គ្រប់គ្រង។ អាហ្នឹង ខ្ញុំឮសួរ។

**ស៖** តើមានអ្វីកើតឡើងទៅដល់សមមិត្តមកពីកងពល៧០៣ ដែលប្រព្រឹត្តអ្វីខុស ដែលត្រូវគេចាត់ទុកថា ជាគិញ្ចពាក់ព័ន្ធនៅក្នុងសកម្មភាពក្បត់? ខ្ញុំនិយាយអំពីចន្លោះពេល មុនពេលលោកមកធ្វើការនៅស-២១ តើមានអ្វីកើតឡើងទៅដល់កងទ័ពមកពីកង៧០៣ ដែលប្រព្រឹត្តកំហុសបែបនេះ?

**ឆ៖** បាទ មុនខ្ញុំមក ស-២១ កងទ័ពកងពល៧០៣ គឺមិនដែលមានសកម្មភាពអីគួរឲ្យកត់សម្គាល់ទេ ព្រោះអង្គាល់ហ្នឹងអត់ទាន់មានស-២១។

**ស៖** បាទ ខ្ញុំយល់ហើយ ប៉ុន្តែព្រឹកមិញនេះលោកបានឆ្លើយថា អ្នកណាក៏ដោយឲ្យតែប្រឆាំងនឹងអង្គការ ប្រឆាំងនឹងរបបនោះ គឺថាអាចនឹងគេយកទៅសម្លាប់ចោលហើយ។ ហើយម្សិលមិញលោកនិយាយអំពីខ្មាំងនៅពេលលោកឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាលោកបានប្រើពាក្យថា "ជោគវាសនាអាក្រក់"។ អ្នកណាក៏ដោយឲ្យតែប្រឆាំងទៅនឹងរបបនោះគឺថា ត្រូវចាត់ទុកថាជា "ខ្មាំង" ហើយបើខ្ញុំយល់មិនច្រឡំទេលោកថា នឹងត្រូវគេសម្លាប់ចោលហើយ។ ត្រង់ចំណុចនេះ ខ្ញុំមិននិយាយពីស-២១ ទេ ខ្ញុំនិយាយមុនពេលលោកទៅស-២១ តាមដែលលោកដឹង លោកកត់សម្គាល់ តើមានអ្វីកើតឡើងទៅដល់អ្នកណាដែលប្រឆាំងនឹងរបបនោះ ប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជានោះ?

[១១:១១:៣៥]

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់បន្តិច កាលពីមិនទាន់មានស-២១ សកម្មភាពហ្នឹងក៏អត់ទាន់មានដែរ មានការកាប់សម្លាប់ មានភាគច្រើននៅឆ្នាំ១៩៧៧, ៧៨ ហ្នឹង អាហ្នឹងបានមានការកាប់សម្លាប់ដោយតាមមូលដ្ឋាន ឬជាស-២១ ព្រោះកាលមិនទាន់មានស-២១ រឿងការកាប់សម្លាប់អត់មាន ហើយក៏មិនដែលឮ មិនដែលជួបដែរ។

**ស៖** ដូច្នេះ ចម្លើយរបស់លោកនៅពេលនេះ គឺថា ពេលខ្លះនៅក្នុងឆ្នាំ៧៦ ឬក៏ ៧៧ គឺអ្នកដែលត្រូវបានគេចាត់ទុកថាជាខ្មាំង ដែលត្រូវបានគេសម្លាប់ចោល ប៉ុន្តែនៅមុនរយៈពេលនោះៗគឺថា មិនមានការធ្វើបែបនេះទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ខ្ញុំសូមបង្ហាញឯកសារមួយទៅឲ្យលោកមើល លោកសាក្សី គឺឯកសារពាក់ព័ន្ធទៅនឹងវរសេនាតូច៩៦ <ក្នុងកងពល៧០៣> គឺឯកសារនេះចុះហត្ថលេខាដោយឈ្មោះ ហ៊ិន ប្រហែលជាមេបញ្ជាការវរសេនាតូច៩៦។ ខ្ញុំមានអត្ថបទនេះជាភាសាខ្មែរ ហេតុដូច្នេះសូមការអនុញ្ញាតលោកប្រធានដើម្បីបង្ហាញឯកសារនេះជូនទៅឲ្យសាក្សីមើល។ <> ក្រោយមកសឹម ខ្ញុំសួរតាមក្រោយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវីអត់ទាន់បានផ្ដល់លេខយោងទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមទោសគឺ E3/965, ERN ជាភាសាអង់គ្លេស 00316312 ហើយខ្មែរ 00068840។ ខ្ញុំមិនមាន ERN ជាភាសាបារាំងទេ នឹងផ្ដល់ជូននៅពេលក្រោយឆាប់ៗនេះ។ ឯកសារនេះមានតែពីរបីទំព័រទេ ដូច្នេះសូមការអនុញ្ញាតឲ្យសាក្សីពិនិត្យមើលលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១១:១៤:៥៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ERN ជាភាសាបារាំង 00032430 *(ស៊ីក)* ដល់ 36។ លោកសាក្សី ខ្ញុំនឹងបង្ហាញចំណុចណា <>ដែលខ្ញុំត្រូវសួរលោកនៅលើឯកសារនេះ គឺ ដែលមានចំណងជើងជាភាសាអង់គ្លេសថា "ប្រវត្តិរូបសង្ខេប<>របស់យុទ្ធជន នៅក្នុង<អនុសេនាធំ>លេខ៤៤ <ដែលត្រូវបានដោះលែង"។ នៅក្នុងឯក-សារនេះ លោកឃើញមានឈ្មោះយុទ្ធជនដែលត្រូវបានដោះលែង។> មានឈ្មោះមនុស្សប្រហែលជា៤៩នាក់នៅលើឯកសារនេះ។ អ្វីដែលខ្ញុំចង់ឲ្យលោក<ធ្វើ គឺ>ពិនិត្យមើល<>ឈ្មោះតែពីរបីនាក់បានហើយៗខ្ញុំនឹងសួរថាតើលោកនៅចាំ<ថាមានការប្រព្រឹត្តបែបនេះ>ដែរឬក៏អត់ទេ? ហើយថាតើលោកយល់យ៉ាងម៉េចដែរក្រោយការចាប់ខ្លួនទៅ តើអ្នកទាំងអស់នេះត្រូវបានគេដោះលែងដែរឬក៏អត់? ឧទាហរណ៍ សូមចាប់មើលលេខ០១ ឈ្មោះនៅត្រង់លេខរៀងទី១ ប្រហែលជាមេធាវីប្រឹក្សាអាចបង្ហាញជូន គឺលេខ១នេះគឺឈ្មោះ ថុង ង៉ែត ហើយ<វានិយាយពីមូលហេតុនៃការចាប់ខ្លួន>នៅ<កូឡោន>ចុងក្រោយនេះ ដាក់

01249459



ថា "សេពគប់ខ្មាំងដោយមិនដឹងខ្លួន អារ៉េន <>ឆ្លើយដាក់<>។ លោកសាក្សី លោកឃើញទេ<បុគ្គលលេខរៀងទី១នេះ>?

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន សូមអរគុណ។ <ការគណនាពេលវេលាដែលខ្ញុំបានផ្ដល់ឲ្យនោះ ពិតជាមិនត្រឹមត្រូវទេ ហើយវាគ្រាន់តែជាការប៉ាន់ស្មានមួយប៉ុណ្ណោះ។> មេធាវីការពារក្ដីមានពេលមួយថ្ងៃពេញ ជារឿងធម្មតាទេ ក៏ប៉ុន្តែខ្ញុំសូមធ្វើការកត់សម្គាល់ <ឬក៏ការជំទាស់ ពាក់ព័ន្ធ>ទៅលើឯកសារ<មានចំណងជើងថា>"អ្នក<ទោសដែលត្រូវបាន>ដោះលែង"។ <យើងពិតជាអាចបញ្ជូនអ្នកវិភាគម្នាក់សម្រាប់ឯកសារនេះ ប៉ុន្តែ>បើតាម<តាមទស្សនៈរបស់>យើង អ្នកដែលត្រូវបានដោះលែងនេះត្រូវបានបញ្ជូនទៅព្រៃសនៅពេលក្រោយមកទៀត ហើយបន្ទាប់មកត្រូវបានសម្លាប់។ អ៊ីចឹងមិនមែនមានន័យថាដោះលែងឲ្យមានសេរីភាពទេ។ <ខ្ញុំបានបង្ហាញចំណុចនេះចេញមក ដើម្បីឲ្យអង្គជំនុំជម្រះយល់ថា> យើងមិនមានទស្សនៈដូចគ្នា <ឬក៏ការយល់ឃើញដូចគ្នាចំពោះអង្គហេតុពាក់ព័ន្ធនឹងឯកសារនេះ>ទេ។ សូមអរគុណ។

[១១:១៧:៤៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** គាត់<កំពុងតែថ្លែងការពារខ្លួនហើយលោកប្រធាន។> ប៉ុន្តែ<គាត់>មិនបានជំទាស់ទេ។ <យើងធ្វើការខុសគ្នា ទោះបីយ៉ាងណា យើងកំពុងតែថ្លែងការពារខ្លួន។ ខ្ញុំសូមផ្ដល់ជូនអង្គជំនុំជម្រះនូវឯកសារដែលមានលេខ E3/8778 នេះហាក់ដូចជាការព្យាយាមមួយរបស់>មជ្ឈមណ្ឌលឯកសារកម្ពុជា គឺព្យាយាមរក<អ្នកទោស>ដែលត្រូវបានគេដោះលែង<> ប៉ុន្តែខ្ញុំ<សូមទុកដោយឡែកសិនសម្រាប់ថ្ងៃស្អែក>ចុះ។ លោកសាក្សី ដូចដែលខ្ញុំបានលើកឡើងមុនការកត់សម្គាល់របស់សហព្រះរាជអាជ្ញារងអន្តរជាតិហើយ ខ្ញុំឲ្យលោកមើលលេខ១១ហ្នឹងគឺ ចុង ង៉ែត អាយុ២៣ឆ្នាំ នៅ<កូឡោន>ចុងក្រោយហ្នឹង គេសរសេរថា សេពគប់ខ្មាំងដោយមិនដឹងខ្លួន ហើយអារ៉េន ឆ្លើយដាក់គាត់ថាជាខ្មាំង។ លោកឃើញទេកន្លែងហ្នឹង?

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ ឃើញឈ្មោះ អារ៉េន។

**ស៖** ខ្ញុំមិនទាន់សួរថាលោកស្គាល់មនុស្សម្នាក់នេះឬក៏អត់ទេ ខ្ញុំគិតថាលោកប្រហែលជាមិន

ស្គាល់ទេ ខ្ញុំគ្រាន់តែសួរថា<តើលោកយល់យ៉ាងណាចំពោះមូល>ហេតុ<ចាប់ខ្លួននេះ>? ពីព្រោះថាតាមបទពិសោធន៍របស់លោក និងការកត់សម្គាល់របស់លោក បើសិនណាជាមានហេតុផលបែបហ្នឹងពាក់ព័ន្ធទៅនឹងយុទ្ធជនកងពល៧០៣ ដែលត្រូវបានគេចាប់ខ្លួន ហើយថាតើមានដែលត្រូវបានគេដោះលែងដែរទេ?

[១១:១៩:៤២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោក<>មេធាវី លោកគួរតែសួរសំណួរបើកថា មានអ្វីកើតឡើងចំពោះមនុស្ស<ដូចពួកអ្នកទាំង>នេះ? <លើកលែងតែជាសំណើសុំឲ្យឆ្លើយ។>

**លោក វ៉ិចទ័រ កូប៉េ៖**

<បាទ សំណើសុំឲ្យឆ្លើយគឺចេញមកពី>ឯកសារនេះ។ <វាមានឈ្មោះថា "ប្រវត្តិរូបកងទ័ពដែលត្រូវបានដោះលែង"> ប៉ុន្តែខ្ញុំសួរដោយបើកចំហចុះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកយល់យ៉ាងដូចម្ដេចទៅលើពាក្យដែលគេសរសេរនៅ <កូឡោន> ចុងក្រោយនេះ បន្ទាត់ចុងក្រោយបំផុតនេះ?

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ តារាងបញ្ជីឈ្មោះនេះ ខ្ញុំអត់ស្គាល់ទេ។ នៅក្នុងកងពលជាមួយគ្នាពិតមែន ប៉ុន្តែនៅផ្សេងៗពីគ្នាអ៊ីចឹងអត់ស្គាល់។ ក្នុងការដោះលែងយ៉ាងម៉េចៗហ្នឹង ក៏មិនបានដឹងដែរពីដំណើររឿង ព្រោះមិនបានជួបប្រទះ។ ខ្ញុំដឹងតែរឿងណាជួបប្រទះបានខ្ញុំហ៊ាននិយាយ បើរឿងអត់ជួបប្រទះ ខ្ញុំអត់ហ៊ាននិយាយ។

**ស៖** សូមចូលទៅមើលលេខរៀងទី១៨ លោកសាក្សីមើលលេខរៀងទី១៨ នៅលើបញ្ជីឈ្មោះនេះ។ នេះជាកងទ័ពដែលមានអាយុ២១ឆ្នាំ ឈ្មោះ អ៊ា កុក ហេតុផលដែលគេចាប់ខ្លួន ដោយសាររយ៉េឡានបុកឡានបង៧០៣។ <តើ>លោក<ធ្លាប់>ដឹងរឿង<កម្មាភិបាលម្នាក់រយ៉េឡានបុកឡាន>បង៧០៣ <>ហ្នឹង<ទេ>?

**ឆ៖** បាទ អត់ដឹង។ ៧០៣ បង៧០៣ មានតែប្រធានកងពល មានតែ តាណាត។ ប៉ុនរឿងរ៉ាវនេះខ្ញុំអត់ដែលបានដឹង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:២២:០៩]

**ស៖** បាទ មកក្រោមបន្តិចមានមនុស្សម្នាក់ឈ្មោះ ហ៊ិន ជី <ជាគ្រូពេទ្យនៅកងអនុសេនាធំ> ត្រូវបាន ហេង អឿន ហ្នឹងឆ្លើយដាក់ថា គាត់ហ្នឹងបំពុលកម្មាភិបាល លោកធ្លាប់ដែលឮរឿងនេះទេ?

**ឆ៖** បាទ ឈ្មោះទី១៩នេះ ហុង ចិន ពេទ្យខ្មែរ។ ពាក់ព័ន្ធនារី សំនៀង រំលោភបីដង អត់ដឹងទេ អត់ដែលដឹង។

**ស៖** ប្រហែលជាមានបញ្ហាអ្វីរវាងភាសាទាំងពីរនេះ <ព្រោះនៅក្នុងកូឡោនរបស់ខ្ញុំ មាន មនុស្សម្នាក់ឈ្មោះ> ហ៊ិន ជី <>ត្រូវបាន ហេង អឿន <>ឆ្លើយដាក់<>ថា គាត់ហ្នឹងគឺបានបំពុល កម្មាភិបាលដទៃទៀត។ លោកធ្លាប់ឮព្រឹត្តការណ៍នេះទេ?

**ឆ៖** ២១ ហ៊ិន ជី ត្រឹមត្រូវ។ គាត់អត់ដែលបានឮ អត់ដែលស្គាល់។

**ស៖** ចុងក្រោយលោកសាក្សី គឺលេខ៣០, ៣១ និង៣២ ជាកងទ័ព<> ជាកុមារ <និងជាប្រជាជន> ហើយ<ការចោទប្រកាន់នោះគឺដើរធ្វើ>គិញ <ឬជាគិញ> និងបំផុសបំផុលប្រជាជន។ លោកឃើញទេ? គឺលេខរៀង៣០, ៣១ និង៣២?

**ឆ៖** បាទ ឃើញ។ រឿងរ៉ាវសុទ្ធតែខ្ញុំអត់ដែលជួប អត់ដឹង។

**ស៖** ហើយឈ្មោះចុងក្រោយ គឺលេខ៤៥ អាយុ២៩ឆ្នាំ ឈ្មោះ ស៊ិន អ៊ុនទី គឺពាក់ព័ន្ធគ្រួសារប្ដី <ប្រពន្ធ>ធ្វើជា សេ.អ៊ី.អា។ លោកធ្លាប់ឮឈ្មោះនេះទេ?

**ឆ៖** នៅលេខ៤១នេះ។ និយាយរួមប្រវត្តិរូបទាំងអស់នេះ ខ្ញុំអត់ដែលស្គាល់អត់បានដឹងរឿងរ៉ាវទាំងអស់នេះ។

**ស៖** ៤៥ៗ លោក សូមមើលលេខរៀងទី៤៥។

**ឆ៖** មានតែ៤១។

**ប្រធានអង្គជំនុំ៖**

នៅទំព័រមួយទៀត មាន១ទំព័រមួយទៀត។

[១១:២៦:០២]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកធ្លាប់ឮ <ធ្លាប់>ដឹងថា ទោះបីជាឆ្នាំ៧៥ក្ដី ៧៦ក្ដី នៅពេលដែលលោកនៅឯ ស-២១នោះ ថាយុទ្ធជនដែលប្រព្រឹត្តបទល្មើសបែបហ្នឹង អំពើបែបហ្នឹង ត្រូវបានគេដោះលែងដែរ

ទេ?

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ បើសិនជាមានករណីនេះ មែនគឺមិនមានការដោះលែងទេ។

**ស៖** ប៉ុន្តែឯកសារនេះបានបង្ហាញថា អ្នកដែលគេចាប់ខ្លួនមួយចំនួននោះត្រូវបានដោះលែងវិញ?

**ឆ៖** អានេះ ឯកសារមិនដឹងជាមកខាងណាខ្ញុំមិនបានដឹងច្បាស់ដែរ ប៉ុន្តែគ្រាន់ខ្ញុំធ្លាប់ដឹងថា នៅក្នុងមន្ទីរស-២១ហ្នឹង គឺអ្នកចូលក្នុងហ្នឹងហើយគឺមិនដែលឃើញចេញទេ។ អានេះប្រហែលជានៅក្រៅៗ ស-២១ ហើយក្នុងក្រដាសនេះក៏មិនមានឃើញដាក់ស-២១ ដែរ។

**ស៖** ខ្ញុំមិនដែលនិយាយថាឯកសារនេះ វាជាឯកសារនៅស-២១ ទេ។ ខ្ញុំសំដៅទៅលើគោលនយោបាយជាសំខាន់ គឺថាយុទ្ធជនដែលត្រូវបានចោទប្រព្រឹត្ត ថាបានប្រព្រឹត្តកំហុសបែបនេះៗ គឺត្រូវបានដោះលែងទៅវិញ។

**ឆ៖** បាទ រឿងហ្នឹងបើនៅក្រៅប្រហែលជាមាន ព្រោះខ្ញុំអត់ដឹង។ ប៉ុន្តែគ្រាន់ថា នៅដឹងថានៅក្នុងស-២១ គឺគ្មាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ បាទ ឥឡូវនេះដល់ពេលសម្រាក -- យ៉ាងម៉េចទៅសហព្រះរាជអាជ្ញារងអន្តរជាតិ?

[១១:២៨:៣៥]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ បន្ទាប់ពីការពិនិត្យផ្ទៀងផ្ទាត់មក ខ្ញុំសូមជម្រាបថា លេខរៀងទី១ ចុង ង៉េត នេះស្ថិតនៅក្នុងបញ្ជីស-២១ របស់ការិយាល័យសហ<ចៅក្រមស៊ើបអង្កេត>គឺ លេខ <១៣២២៦> <ហើយនៅក្នុងបញ្ជីរបស់ការិយាល័យសហព្រះរាជអាជ្ញា គឺ E3/432> នៅក្នុងលេខរៀង១០៦៦១ ដែលចូលស-២១ នៅ<ថ្ងៃទី២២ ខែមេសា> ឆ្នាំ១៩៧៧។ <បន្ថែមពីលើនោះ ព័ត៌មាននៅលើឯកសារនេះ ហើយនិង>តាមរយៈការវិភាគដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ពាក់ព័ន្ធនឹងឯកសារហ្នឹង គឺមាននៅឯកសារ E3/8778 ដែលមានទំព័រជាភាសាអង់គ្លេស 00989320 ទៅដល់ 21 ដែលបញ្ជាក់ថា មនុស្សមួយចំនួន<ក្នុងបញ្ជីនេះ>ត្រូវបានចាប់ខ្លួនឡើងវិញម្តងទៀត ហើយក្រោយមកសម្លាប់ចោល។ សូមអរគុណលោកប្រធាន។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាបញ្ជីនេះជាបញ្ជីមិនត្រឹមត្រូវទេ។ <វាជាផ្ទាំង*អ៊ិចសែល-ស៊ីត* របស់លោកដោយផ្ទាល់លោកសហព្រះរាជអាជ្ញា។> តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំនឹងបង្ហាញជូនឲ្យបានច្បាស់លាស់ក្រោយពេលយើងចូលមកវិញថ្ងៃរសៀលនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រាកថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយ កន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយ និងសាមសិបនាទីរសៀល។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅ ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោង១មួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣០ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣១:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ដើម្បីការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី យើងបាននិយាយគ្នាអំពីកម្មាភិបាលកងពល៧០៣ ដែលត្រូវបានគេចាប់ខ្លួន ហើយនិងមនុស្សមួយចំនួនដែលខ្ញុំនឹងបង្ហាញតាមបញ្ជីលោកហ្នឹងថា គេបានដោះលែងអ្នកទាំង

នោះ។ ខ្ញុំចង់ឲ្យលោកចាប់អារម្មណ៍ទៅលើឯកសារមួយ ដែលឯកសារនោះ សុន សេន ដែលលោកស្គាល់ច្បាស់ណាស់។ សុន សេន នេះ គាត់បាននិយាយអំពីប្រភេទមួយចំនួននៃខ្មាំង ដែលថាជាការនិយាយអំពី --សូមកែសំឡេង គឺថាអំពីសុន្ទរកថា នៅថ្ងៃទី០៩ តុលា ឆ្នាំ១៩៧៦ ជាមួយនឹងលេខា និងអនុលេខាកងពលទាំងអស់។ ហើយខ្ញុំនឹងអានឲ្យលោកស្ដាប់ សេចក្ដីដកស្រង់ជាក់លាក់មួយចំនួន ហើយសូមឲ្យលោកផ្ដល់ប្រតិកម្មជាមតិ ហើយដូចជាថា អ្នកណាខ្លះដែលគេជាក្រុមខ្មាំងជាដើម។ អ៊ីចឹងនឹង ខ្ញុំដកស្រង់ជាភាសាខ្មែរចេញពីឯកសារនោះ។

លោកប្រធាន ខ្ញុំយោងទៅរកឯកសារ E3/13។ ខ្ញុំនឹងបង្ហាញទៅសាក្សី ទំព័រខ្មែរ 00052414, ហើយអង់គ្លេសគឺ ERN 00940354 ហើយនិងដល់ 55, បារាំង 00344983។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១៣:៣៤:០៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** គឺផ្នែកមួយដែលខ្ញុំគូសជាសញ្ញាពណ៌ទឹកក្រូច លោកសាក្សី។ ខ្ញុំនឹងអានជាភាសាអង់គ្លេស៖ "វិធីប្រតិបត្តិការមួយ បន្តការអប់រំ គឺជាកាតព្វកិច្ចដាច់ខាត។ ពីរ ជាដាច់ខាត ត្រូវបោសសម្អាតសមាភាពមិនល្អ ហើយក្នុងន័យតស៊ូវណ្ណៈដាច់ខាត។ បាទ <ការ>សម្រិតសម្រាំង ត្រូវលើកជាគោល-ការណ៍បីយ៉ាង។ ប្រភេទទី១ ប្រភេទអន្តរាយ ត្រូវតែសម្រិតសម្រាំងជាដាច់ខាត។ ប្រភេទទី២ ប្រភេទសេរីធម្មតា ត្រូវអប់រំជាបន្តបន្ទាប់ក្នុងសាលាអប់រំរបស់យើង។ ប្រភេទទី៣ ប្រភេទពួកទើបតែខ្មាំងញុះញង់ ទើបតែជឿគេញុះញង់ជាជំហានដំបូង ត្រូវអប់រំកសាងគេ កុំឲ្យជឿខ្មាំងតទៅទៀត។" ចប់សេចក្ដីដកស្រង់។

លោកសាក្សី ការបែងចែកទៅជាប្រភេទបីនេះ តើទាំងអស់នេះជាអ្វីដែលលោកបានឮពី សុន សេន, ពី ឌុច ឬក៏ពីកម្មាភិបាលថ្នាក់ខ្ពស់ណាផ្សេងទៀត ដែលធ្លាប់និយាយពីរឿងនេះនៅស-២១ ដែរឬទេ គឺប្រភេទទី១, ទី២ និងទី៣ នេះ?

**ឆ៖** បាទ សំណួរទាំងនេះ គឺខ្ញុំធ្លាប់បានឮការអប់រំរបស់ សុន សេន ហើយនិង ឌុច។ ព្រោះនៅឆ្នាំ ក្នុងចុង៧៧, ៧៨ នេះ គឺពេលហ្នឹង ហៅថា ការចាប់ចងនិងការអប់រំ គឺមានច្រើន។ ដល់អ៊ីចឹង ត្រូវការប្រុងប្រយ័ត្ន ប៉ុន្តែក្នុងការប្រុងប្រយ័ត្នហ្នឹង ក៏វាមានប៉ះពាល់ទាំងអស់ហ្នឹងដែរ។ អ៊ីចឹង ជាការអប់រំ

របស់គេមានជារឿយៗ ជាបន្តបន្ទាប់។

[១៣:៣៦:៥១]

**ស៖** ដើម្បីឱ្យប្រាកដ លោកសាក្សី តើការបែងចែកទៅជាប្រភេទបីក្រុមនៃខ្មាំងហ្នឹង គឺតើគេបាននិយាយឱ្យលោកយល់ ឬក៏លោកបានដឹងដោយខ្លួនឯង<នៅពេលនោះ> ឬក៏វាជាគោលនយោបាយដែលគេអនុវត្តនៅក្នុងកងវរសេនាធំ<២១> -- នៅក្នុងមន្ទីរស-២១ ទាំងស្រុងដែរឬទេ?

**ឆ៖** បាទ នេះជាទ្រឹស្តី ជាគោលការណ៍របស់ខាងលើទេ មិនមែនជាតួនាទីរបស់ខ្ញុំទេ។

**ស៖** តើលោកចង់មានអត្ថន័យដូចម្តេច?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

គឺថាសំណួរសួរម្តងមួយ លោកមេធាវី <កុំ>សួរបីសំណួរតែម្តងអ៊ីចឹង <ធ្វើឱ្យវាងាយស្រួលជាងនេះ។ លោកបានចាប់ផ្តើមសំណួរដោយ "តើលោកធ្លាប់បានឮរឿងនោះទេ? ហើយបន្ទាប់មកលោកបន្ថែមបួនសំណួរទៀត>។ គឺថាសួរម្តងមួយៗ ល្អជាង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ខ្ញុំនឹងសួរម្តងទៀត លោកសាក្សី។ ការបែងចែកខ្មាំងទៅជាបីក្រុមខុសៗគ្នា តើការបែងចែកនេះ ជាអ្វីដែលលោកដឹងថា គេយកមកអនុវត្តនៅក្នុងបណ្តាញ ឬក្នុងប្រព័ន្ធស-២១ ទាំងមូលដែរឬទេ?

**ឆ៖** បាទ ទ្រឹស្តីហ្នឹង គឺគេឱ្យយកមកអនុវត្តនៅក្នុងស-២១ ឬក៏ខាងក្រៅហ្នឹង មាន។ ទ្រឹស្តីហ្នឹងមានជាបន្តបន្ទាប់ ឱ្យបែងចែកគ្រប់ស្រទាប់ គ្រប់វណ្ណៈ ឱ្យចែកដាច់ស្រឡះ ដើម្បីចាប់ រកអ្នកប្រឆាំង អ្នកក្បត់បដិវត្តន៍ហ្នឹងឱ្យចំ។

**ស៖** តើលោកដឹងដែរឬទេ ថាតើ<>ប្រភេទខ្មាំងណាមួយដែលគេត្រូវឱ្យទៅព្រៃស? តើ<ខ្មាំង>ប្រភេទណាដែលត្រូវគេបញ្ជូនទៅក្នុងបរិវេណស-២១ ដែលគេហៅថា ជាប្រភេទអ្នកទោស ស-២១ នោះ?

**ឆ៖** បាទ ប្រភេទទាំងពីរបីជំពូកនេះ គឺមានប្រភេទណាដែលស្រាលជាងគេ គឺគេអាចនឹងអប់រំឱ្យទៅនៅខាងព្រៃស។ ប្រភេទដែលប្រឆាំងនឹងបដិវត្តន៍ធ្ងន់ធ្ងរ អាហ្នឹងគេបញ្ចូលក្នុងស-២១។

[១៣:៤០:២៤]

**ស៖** <តើលោកដឹងទេថា នរណាជាអ្នកសម្រេចថា អ្នកណាម្នាក់>ត្រូវបញ្ជូននៅព្រៃស

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយអ្នកផ្សេងក៏គេបញ្ជូនទៅស-២១?

**ឆ៖** បាទ អាការសម្រេច ខ្ញុំមិនដឹងទេ ព្រោះមិនមែនជាតួនាទីរបស់ខ្ញុំ។

**ស៖** តើលោកដឹងទេថា <ការ>សម្រេចពីបញ្ហានេះ គេសម្រេចនៅកន្លែងណា? ទីកន្លែងណាដែលគេសម្រេចពីបញ្ហានេះ?

**ឆ៖** បាទ អត់ដឹង។

**ស៖** តើលោកដឹងឬទេថា តើមនុស្សដែលគេដាក់នៅលើឡាន ដែលបញ្ជូនមកដល់ៗកន្លែងវិទ្យុសំបុកឃ្មុំនោះ តើគេបញ្ជូនយកទៅថតរូប ហើយគេយកទៅស-២១ <> ឬក៏ត្រូវបញ្ជូនត្រឡប់មកវិញបញ្ជូនទៅស-២៤? តើលោកអាចពន្យល់ ឬក៏ដឹងអំពីដំណើរការដែលគេបញ្ជូនអ្នកទោសមកដល់ បន្ទាប់មកគេយកទៅថតរូប បន្ទាប់មក<តើមានអ្វីកើតឡើងចំពោះពួកគេ>? តើលោកអាចពន្យល់តុលាការអំពីដំណើរការនេះបានដែរឬទេ?

**ឆ៖** បាទ រឿងនេះ ខ្ញុំមិនអាចដឹងបានទេ ព្រោះខ្ញុំមិនបានអនុវត្ត។ អ៊ីចឹងខ្ញុំមិនអាចថា មិនអាចស្មានបាន។

**ស៖** ខ្ញុំនឹងអានជូនលោកស្តាប់នូវសេចក្តីដកស្រង់មួយ ចេញអំពីបុគ្គលម្នាក់ដែលបានចូលរួមនៅក្នុងដំណើរការ<នោះទាំងមូល> ហើយ<បន្ទាប់មក>ខ្ញុំ<នឹង>សួរលោកថា តើលោកមានមតិដូចម្តេចទៅលើចម្លើយនោះ។ ហើយខ្ញុំយោងទៅរកកំណត់ហេតុស្តាប់ចម្លើយរបស់ប្រធានក្រុមថតរូប គឺឯកសារ E3/7639។ ជាពិសេស គឺនិយាយអំពីអង់គ្លេស ERN 00162736, ខ្មែរ 00162713, បារាំង 00338079។ ដូចដែលខ្ញុំនិយាយអ៊ីចឹងលោកសាក្សី ប្រធានក្រុមថតរូបឈ្មោះ <នឹម> គឹមស្រ៊ាង។ គាត់និយាយដូចខាងក្រោមនេះ "សំណួរ៖ បន្ទាប់ពីថតរូបហើយ តើគេបញ្ជូនអ្នកទោសទៅណា? គាត់ឆ្លើយថា៖ ភាគច្រើននៃអ្នកទោសទាំងអស់នោះដែលត្រូវបានថតរូបរួចហើយ គេបញ្ជូនទៅធ្វើស្រែ ប៉ុន្តែក្រៅពីហ្នឹងខ្ញុំមិនដឹងទេ។ អ្នកទោសដែលគេបញ្ជូនទៅធ្វើស្រែនោះ គឺជាមនុស្សតូចតាចទេ ខ្ញុំបានទៅទីនោះ ហើយថតរូបពួកគេ ហើយខ្ញុំបានឃើញថាពួកគេធ្វើស្រែ។" បាទ នៅខាងដើមហ្នឹងបន្តិច <ដើម្បីឱ្យបានពេញលេញនោះ គឺនៅក្នុងកំណត់ហេតុស្តាប់ចម្លើយដដែល> អង់គ្លេស ERN 00162733 ដល់ 34, ខ្មែរ 00162710 ហើយបារាំង 00338076។ អ្នកថតរូបដដែលហ្នឹង គាត់ជាប្រធានថតរូបហ្នឹង គាត់និយាយពីហេតុការណ៍ជាមួយ ឌុច គាត់និយាយថា៖ "ថ្ងៃមួយ នៅពេលដែលខ្ញុំផ្តិតរូប រូបថតនោះវាខូច ពេលដែលខ្ញុំសូមថតម្តងឡើងវិញ ហើយខ្ញុំរកឃើញតែពីរនាក់ទេ ហើយខ្ញុំសួរ ឌុច៖ បង! អ្នកទោស

01249467



ដែលគេយកមកម្សិលមិញ តើគេយកទៅណាអស់ហើយ? គាត់និយាយថា។ គេបញ្ជូនទៅវាលស្រែអស់ហើយ អ្នកឯងទៅថតនៅឯស្រែនោះទៅ។” ចប់សេចក្ដីដកស្រង់។

តើលោកសាក្សីអាចផ្ដល់មតិពាក់ព័ន្ធទៅនឹងអ្វីដែលអ្នកថតរូបនោះ និយាយពីរឿងនេះ តើលោកដឹងអ្វីខ្លះពីរឿងនេះ កាលពីសម័យនោះ?

[១៣:៤៥:៣០]

**ឆ៖** បាទ រឿងអ្នកថតរូបខ្ញុំអត់ដឹងទេ ព្រោះរឿងការងារគេផ្សេង។ ខ្ញុំដឹងតែការងាររបស់ខ្ញុំ ធ្វើនៅក្នុងហ្នឹង។

**ស៖** ខ្ញុំយល់ហើយ ហើយខ្ញុំ<>ទុកការថតរូបហ្នឹងមួយឡែកសិន។ តើលោកធ្លាប់ឮពីអ្នកណាម្នាក់ទេ នៅពេលដែលលោកធ្វើការនៅស-២១ <ថា>មនុស្សដែលគេបញ្ជូនទៅព្រៃស ត្រូវបានគេចុះបញ្ជី ហើយថតរូបនៅក្នុងស-២១ ដែរឬទេ?

**ឆ៖** បាទ ការងារនៅខាងព្រៃស ខ្ញុំអត់ដឹង។

**ស៖** តើលោកដឹងឬទេ ថាតើនៅពេលដែលលោកធ្វើការជាអ្នកយាម តើលោកអាច<>ប្រាប់ទេថា ឡានដែលចាកចេញពីស-២១ អាចទៅជើងឯក ឬក៏អាចទៅព្រៃស ឬក៏អាចទៅទីកន្លែងទីដៅណាទី៣ បានឬទេ?

**ឆ៖** បាទ កាលសម័យដែលខ្ញុំយាម គឺកាលនោះ ដូចមិនទាន់មានកន្លែងអប់រំនៅព្រៃសទេ ព្រោះជាដំបូងនៃការរៀបចំនៅទួលស្លែង។ អ៊ីចឹងព្រៃស ត្រង់មាន មិនមានខ្ញុំអត់ដឹង។ មិនដឹងជាឡានគេបញ្ជូនទៅណា។ ខ្ញុំអត់ដឹង។

**ស៖** តើលោកដឹង ថាតើនៅពេលណាមួយអ្នកទោសដែលលោកសួរចម្លើយនោះ ត្រូវបានគេបញ្ជូនទៅព្រៃសដែរឬទេ?

**ឆ៖** បាទ អ្នកទោសខ្ញុំសួរចម្លើយ កន្លងមក ខ្ញុំមិនដែលដឹង ហើយក៏មិនដែលឃើញដែរ ប៉ុន្តែជាគោលការណ៍នៅក្នុងស-២១ គឺគ្មានសួរចម្លើយហើយ បញ្ជូនទៅស្រែដោះលែងទេ គឺគ្មាន។

**ស៖** ប្រហែលជា មិនគេដោះលែងឲ្យរួចមានសេរីភាពទេ ប្រហែលគេបញ្ជូនទៅអប់រំនៅស-២៤ ហៅថាព្រៃស។<> តើលោកដឹងថា ក្នុងចំណោមមនុស្សដែលលោកសួរចម្លើយហ្នឹង ធ្លាប់បានអ្នកណាមួយ ឬក៏ប៉ុន្មានគេបញ្ជូនទៅព្រៃសដើម្បីអប់រំទេ អប់រំកែប្រែ?

**ឆ៖** បាទ អត់ដឹងទេ។

01249468



[១៣:៤៩:០៨]

**ស៖** អ៊ីចឹង តើត្រឹមត្រូវដែរឬទេ លោកនិយាយជាទូទៅលោកមិនដឹងថា នឹងមានរឿងអ្វីកើតឡើង ចំពោះអ្នកទោសដែលលោកបានសួរចម្លើយទេ។ តើមតិនេះយ៉ាងម៉េចដែរចំពោះលោក?

**ឆ៖** បាទ បានជាខ្ញុំនិយាយអត់ដឹង ព្រោះខ្ញុំអត់ដឹង បើខ្ញុំអត់ដឹង ឲ្យខ្ញុំនិយាយថាដឹង ដូចអត់កើត។ ខ្ញុំនិយាយត្រឹមខ្ញុំដឹង ខ្ញុំឃើញ ខ្ញុំឮ។ បើកាលណា ខ្ញុំឃើញ ខ្ញុំឮ ខ្ញុំដឹង ខ្ញុំថា ខ្ញុំនិយាយ។

**ស៖** បាទ អរគុណហើយលោកសាក្សី។ ល្អណាស់ នេះឯងជាចំណុចដែលខ្ញុំចង់បាន។ ឥឡូវនេះ ខ្ញុំនឹងបន្តទៅបញ្ហាពីរបីទៀត មុនពេលដែលខ្ញុំនិយាយពីការសួរចម្លើយ។ លោកបាននិយាយដោយសង្ខេបពីព្រឹកមិញ ដោយឆ្លើយទៅនឹងសំណួរមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី<> អំពី<ផ្ទះ>ដែលលោកសួរចម្លើយអ្នកទោស។ តើមានផ្ទះសួរចម្លើយ ឬក៏កន្លែងសួរចម្លើយហ្នឹងប៉ុន្មាននៅក្នុងបរិវេណនៃស-២១?<> ហើយនិងខាងក្រៅបរិវេណ មានប៉ុន្មានសរុបទាំងអស់?

**ឆ៖** បាទ ផ្ទះសួរចម្លើយហ្នឹង គឺមិនប្រាកដប្រជាថាប៉ុន្មានទេ គឺថាផ្ទះណាអាចមើលទៅទំនងថាដាក់បាន ធ្វើកើត គឺបោសសម្អាតដាក់តែម្ដង។ អ៊ីចឹងមិនប្រាកដាថាជាប៉ុន្មានៗទេ។ ហើយនៅខាងក្រៅបរិវេណគុក គឺនៅខាងលីងក្រៅ ប៉ុនមិនមែនដល់លីងក្រៅទេ គឺខាងចេញពីរបងគុកមក គឺនៅខាងក្រៅហ្នឹង ហើយមានរបងស័ង្កសីមួយជាន់ទៀតនៅពីក្រៅ។

**ស៖** តើត្រឹមត្រូវដែរឬទេ ប្រហែលជាមានផ្ទះប្រាំពីរដែលគេប្រើធ្វើសម្រាប់សួរចម្លើយ?

**ឆ៖** បាទ មើលៗ -- ផ្ទះប្រាំពីរ ឬក៏លើសពីហ្នឹងក៏មានដែរ។

**ស៖** តើលោកដឹងឬទេ ថាតើ<>ផ្ទះខ្លះនៅប្រហែលជា ៥០ម៉ែត្រពីគ្នា ផ្ទះខ្លះនៅចម្ងាយពីគ្នា ១០០ម៉ែត្រ ឬ១៥០ម៉ែត្រ។ សូមលោកបញ្ជាក់ប្រាប់តុលាការពីទីតាំងនៃផ្ទះសួរចម្លើយទាំងអស់ហ្នឹងឲ្យបានជាក់លាក់បន្តិច?

**ឆ៖** បាទ ផ្ទះសួរចម្លើយហ្នឹងនៅចំពីខាងកើត ខ្លោងទ្វារចូលទួលស្លែងហ្នឹងតែម្ដង គឺកន្លែងខ្លោងទ្វារចាស់ពីដើមមកហ្នឹង មិនមែនខ្លោងទ្វារថ្មីបច្ចុប្បន្ននេះទេ។ គឺទៅកើត ងាកខាងជើងខ្លោងទ្វារដីប្រហែលជា១០ម៉ែត្រជាងប៉ុណ្ណោះ។ ហើយទៅកើតត្រង់ៗ ឆ្លងលូទឹកស្អុយទៅកើតទៀត ក៏នៅក្នុងបរិវេណស-២១ ទៅទល់រហូតផ្ទះ កាំង ហ្កេកអ៊ាវ ហៅ ឌុច នៅខាងលិចជាប់ផ្លូវមុនីវង្ស។ អ៊ីចឹងបរិវេណផ្លូវអស់ហ្នឹង គឺមានល្វែងផ្ទះថ្មមួយជួរខាងឆ្វេងដៃ និងស្ដាំដៃ បើដើរពីគុកទៅ។ អ៊ីចឹងផ្ទះថ្មល្វែង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទាំងអស់ហ្នឹងសម្រាប់សួរចម្លើយ ជួរមុខ និងមានជួរក្រោយខាងក្រោយទៀត ដែលជាកន្លែងទីតាំងតូច រំលោភស្ត្រីអ្នកទោសហ្នឹង។

[១៣:៥៣:៣០]

**ស៖** អ៊ីចឹងខ្ញុំផ្តោតអារម្មណ៍ៗទៅលើផ្ទះមួយដែលលោកសួរចម្លើយ<អ្នកទោស>។ តើលោកតែងតែប្រើផ្ទះដដែលហ្នឹងគ្រប់ពេលសួរចម្លើយឬយ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំប្រើផ្ទះមួយដដែលហ្នឹងរហូតទល់ខ្ញុំចេញពីហ្នឹងមក។

**ស៖** តើលោកដឹងទេថាអាចទៅរួចទេថាៗ អ្នកទោសដែលនៅក្នុងបរិវេណស-២១ អាចស្តាប់ឮសំឡេងរបស់លោក ឬក៏សំឡេងរបស់អ្នកទោសដែលឆ្លើយពេលដែល<>លោកកំពុងសួរចម្លើយនោះណា?

**ឆ៖** បាទ រឿងសំឡេងស្រែកខ្លាំងៗ ប្រហែលជាអាចឮដល់ ព្រោះវានៅមិនបាន ១០០ម៉ែត្រទេ ប្រហែលជា៥០ម៉ែត្រ ពីគុកតែប៉ុណ្ណោះ។

**ស៖** ខ្ញុំនឹងត្រឡប់មកបញ្ហានេះឡើងវិញ ខ្ញុំនឹងសួរសំណួរទូទៅជាមុនសិន អំពីលោកដែលលោកធ្វើជាអ្នកសួរចម្លើយ។ តើលោកនៅចាំដែរឬទេ <>លោកសួរចម្លើយដំបូងហ្នឹង<>នៅ<ពេល>ណា?

**ឆ៖** បាទ ខ្ញុំសួរចម្លើយដំបូងហ្នឹង គឺសួរនៅផ្លូវខាងៗត្បូងច្រកចូលគុកទួលស្លែងហ្នឹង អាផ្លូវខឿងហែមមួយផ្សេង។ អ៊ីចឹងអាហ្នឹងជាជំហានដំបូងដែលខ្ញុំចូលទៅ គេឱ្យទៅសួរជាមួយអ្នកបងៗមុនហ្នឹង ឱ្យរៀនសូត្រតាមគេ គឺនៅក្នុងច្រកផ្លូវខឿងហែមមួយដែលខាងត្បូងខ្លោងទ្វារចូលហ្នឹង។

**ស៖** តើលោកចាំទេ ពេលដែលចាប់ផ្តើមសួរចម្លើយដំបូងហ្នឹងនៅពេលណា ចង់សួរពេលវេលាបាទ?

**ឆ៖** បាទ សុំបញ្ជាក់ម្តងទៀត ពេលណាៗហ្នឹង ពេលវេលាធ្វើការ ឬមួយក៏ពេលសួរនៅឆ្នាំណាខែណា?

**ស៖** ខ្ញុំសួរឱ្យលោកប្រាប់ខ្ញុំ។ ខ្ញុំសួរៗថា តើលោកនៅចាំទេ ពេលដំបូងដែល<>លោកសួរចម្លើយអ្នកទោសនោះ ពេលណា? បានន័យថាខែឆ្នាំណា?

**ឆ៖** បាទ អរគុណ។ ខ្ញុំសួរ -- ខ្ញុំខែឆ្នាំ ខ្ញុំមិនចាំទេ ព្រោះកាលនោះ ខ្ញុំអារម្មណ៍និយាយត្រង់មិនបានគិតគូរពីរឿងខែឆ្នាំ ចាំទុកក្នុងខួរក្បាលទេ គឺគិតឱ្យតែធ្វើ ឱ្យតែបានធ្វើឱ្យតែហើយ។ អ៊ីចឹងបានថាខ្ញុំមិនប្រាកដប្រជារឿងឆ្នាំ ក្នុងប្រហែលជាអំឡុងចុងឆ្នាំ៧៦ ឬក៏ពាក់កណ្តាលឆ្នាំ៧៦ អីហ្នឹង ប្រហែល។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

[១៣:៥៧:១១]

**ស៖** ម្សិលមិញលោកបានបញ្ជាក់ថា លោកបានចុះហត្ថលេខាលើចម្លើយសារភាពរបស់ អេង ម៉េង ប៉ាង ហៅ ឆុន E3/1549។ ចម្លើយសារភាពហើយនិងហត្ថលេខារបស់លោក ប្រហែលជានៅខែកុម្ភៈ -- ២៤ កុម្ភៈ ឆ្នាំ១៩៧៧។ តើលោកនៅចាំទេ ម្នាក់នេះគឺជាអ្នកទោសក្នុងចំណោមអ្នកទោសដំបូង<គេដែលលោកសួរចម្លើយ ឬក៏លេខរៀងទី> ១០<>ឬ<១៥ ឬ> ២០ <តើលោកនៅចាំ>ទេ?

**ឆ៖** បាទ ហ្នឹងហើយដែលជាអ្នកទោសដែលខ្ញុំបានយកទៅសួរនៅជំហានដំបូងខ្លួនឯង តែអ្នកមុនៗហ្នឹង គឺមិនមែនក្នុងខែហ្នឹងឆ្នាំហ្នឹងទេ វាមាន វាមុនហ្នឹង ប៉ុនមិនដឹងជាថ្ងៃណា ខែណា ខ្ញុំចាំមិនច្បាស់។

**ស៖** តើលោកចង់ប្រាប់តុលាការថា គាត់គឺជាមនុស្សទី១<>ដែលលោកសួរដំបូងគេ ឬក៏<ថាមុននឹង>លោក<>សួរចម្លើយ<អ្នកទោស>ផ្សេង <-- ជាមួយ>អ្នកផ្សេង<>? សូមលោកបញ្ជាក់ឲ្យច្បាស់។

**ឆ៖** បាទ អេង ម៉េង ឆុន ហ្នឹង គឺជាអ្នកទោសដែលខ្ញុំបានសួរខ្លួនឯងជំហានដំបូង ប៉ុន្តែមុនហ្នឹងគឺខ្ញុំធ្វើជាមួយគេ។ អ៊ីចឹងគេអ្នកសួរ ខ្ញុំនៅជាមួយគេ ឯកសារគេធ្វើគេដាក់ឈ្មោះគេទាំងអស់ ខ្ញុំគ្រាន់តែនៅជាមួយគេ រៀនសូត្រតាមគេ មើលគេ។

**ស៖** យើងក៏បានពិភាក្សាពីម្សិលមិញដែរអំពីការសួរចុងក្រោយរបស់លោក គឺថា នៅថ្ងៃទី០៤ មករា ឆ្នាំ១៩៧៩។ បាទ អ៊ីចឹងសូមលោកបញ្ជាក់មើលថាតើលោកសួរចម្លើយមនុស្សបានប៉ុន្មាននាក់តាំងពីឆ្នាំ១៩៧៧ ខែកុម្ភៈ រហូតមកដល់ ឆ្នាំ១៩៧៩ ខែមករានោះ?

**ឆ៖** បាទ ខ្ញុំចាំមិនច្បាស់ ក៏ចាំមិនអស់ដែរ ប្រហែលជា ២០នាក់ជាងប៉ុណ្ណោះ ដែលចងចាំបាន ប៉ុន្តែត្រង់ថា ឲ្យច្បាស់ប្រាកដប្រជា អត់ៗច្បាស់ទេ។

**ស៖** គឺថាមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការវិភាគឯកសារនៅស-២១ <ហើយគេរកឃើញថា មាន>ចម្លើយ<សារភាពចំនួន៥៣>ដែលមាន<ឈ្មោះ>របស់លោក<នៅលើនោះ>។ តើលោកអាចបញ្ជាក់ដូចម្ដេចបាន ចំនួនសរុបពីអ្នកទោសដែលលោកសួរចម្លើយនោះ?

[១៤:០០:៤៧]

**ឆ៖** បាទ ខ្ញុំមិនៗចាំ ព្រោះរឿងវាយូរពេក ខ្ញុំអត់ចាំ។ ទទួលស្គាល់ថា មិនចាំតែម្ដង។ រឿងប៉ុន្មានៗ ខ្ញុំអត់ដឹង ប៉ុន្តែគ្រាន់ខ្ញុំស្មានក្នុងចិត្តខ្ញុំប្រហែលជាជាង២០នាក់ប៉ុណ្ណឹង ព្រោះឯកសារខ្លះ ឃើញ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស៊ីញេខុសពីខ្ញុំ ហើយដាក់ឈ្មោះខ្ញុំក៏មាន មិនអ៊ីចឹង ខ្ញុំមិនដឹងជាឯកសារអីៗទេ ច្រើនចម្លងសរសេរដាក់ឈ្មោះខ្ញុំ ហើយជាអក្សរដើម អក្សរអី គឺមិនមែនអក្សរខ្ញុំ។

**ស៖** តើលោកដឹងទេថា លោកស្ថិតនៅក្នុងក្រុមអ្នកសួរចម្លើយណាមួយ ខ្ញុំមិននិយាយពីក្រុមសួរអង្អៀម ឬក៏ក្រុមក្ដៅ ឬក្រុម<ត្រជាក់>ទេ គឺខ្ញុំនិយាយពី<លេខ>វិញ។ តើលោកស្ថិតនៅក្នុងក្រុមទី១ ទី២ ឬក៏ទី៣ ក្រុមអ្នកសួរចម្លើយ?

**ឆ៖** បាទ ខ្ញុំនៅក្នុងក្រុមទី៣។

**ស៖** បាទ ខ្ញុំមានចំពោះមុខខ្ញុំនេះ ចម្លើយសារភាព E3/4260 ចម្លើយសារភាពដែលលោកចុះហត្ថលេខានៅថ្ងៃទី០៣ ឧសភា ឆ្នាំ១៩៧៧ គឺ<ERN ភាសាអង់គ្លេស 00782984>, ខ្មែរ <00257995>។ ខ្ញុំមិនមានលេខ ERN<ភាសាបារាំង>ទេ នៅពេលនេះ លោកប្រធាន ខ្ញុំសូមអភ័យទោស ប៉ុន្តែនៅទីនេះ គឺនិយាយថា លោកស្ថិតនៅក្នុងក្រុម២។ ចម្លើយសារភាពដែលខ្ញុំនិយាយអំពីនោះគឺបញ្ជាក់ថា លោកស្ថិតនៅក្នុងក្រុមទី១២ E3/1549, អង់គ្លេស 00769710, ខ្មែរ 00174428។ តើលោកនៅក្នុងក្រុម២ ក្រុម៣ ឬក៏ក្រុម១២ ឥឡូវសូមលោកនឹកមើលបន្តិចមើល ណាមួយ?

[១៤:០៣:៣០]

**ឆ៖** បាទ រឿងក្រុមហ្នឹង វាមិនប្រាកដដែរ ព្រោះខ្ញុំយូរណាស់ ភ្លេចអស់ដែរ ប៉ុនគ្រាន់ថា ដឹងក្រុមទី១ ក្រុមក្ដៅ, ក្រុមទី២ ក្រុមត្រជាក់, ក្រុមទី៣ ក្រុមអង្អៀម អ៊ីចឹងទៅ។ ប៉ុនថាឲ្យពិតប្រាកដ ខ្ញុំមិនប្រាកដក្នុងចិត្តដែរទេ ព្រោះវាយូរហើយ ភ្លេចភ្លាំងអស់ដែរ។

**ស៖** មូលហេតុដែលខ្ញុំសួរលោក គឺថា ឌុច នៅពេលដែលគេសួរគាត់ គាត់បញ្ជាក់ថា មានវិធីសាស្ត្របីយ៉ាង គឺថាវិធីសួរចម្លើយមានក្ដៅ មានត្រជាក់ ឬមានអង្អៀម។ <ប៉ុន្តែអត់មានក្រុម៣ ដូចលោកនិយាយទេ។> អ៊ីចឹងគឺថាអ្វីដែល ឌុច និយាយនេះ ខ្ញុំប្រាប់ឲ្យលោកដឹង គឺថា E3/1570។ ខ្ញុំមានតែអត្ថបទឯកសារអង់គ្លេសទេគឺ <00154192>។ គាត់និយាយថា៖ “ខ្ញុំសូមបញ្ជាក់ថា មានៗវិធីសាស្ត្របីយ៉ាងនៃការសួរចម្លើយ ប៉ុន្តែខ្ញុំមិនមែនជាអ្នកបែងចែក អ្នកសួរចម្លើយឲ្យទៅជាបីក្រុមទេ។ ខ្ញុំមិនបានដឹងថាមានការបែងចែកនេះទេ ប៉ុនការបែងចែកនេះ តាំងពី ណាត មក។ ហើយក៏វិធីនៃការសួរចម្លើយនេះ ខ្ញុំបានបង្រៀន ប៉ុន្តែខ្ញុំមិនបានបែងចែកពួកគេជាក្រុមទេ។ <វាមានន័យ>ថាអ្នកសួរចម្លើយ<អាច>ប្រើវិធីសាស្ត្រ<មួយ>ណា<ក៏បាន អាស្រ័យទៅលើអ្នកទោសដែលគេសួរ>។” អ៊ីចឹង លោកសាក្សី តើលោកអាចនឹងឆ្លើយតបដូចម្ដេចចំពោះចម្លើយរបស់ ឌុច បែបនេះ?

[១៤:០៥:៣២]

**ឆ៖** បាទ ចម្លើយនេះ ការរៀនសូត្រនៅក្នុងសាលានយោបាយរបស់ឌុច – ឌុច គេបានលើកឡើងជារឿយៗ ប៉ុនថាមិនប្រាកដថា ពាក្យហ្នឹងបានមកពីត្រឹមណា ខ្ញុំអត់ដឹងទេ។ ប៉ុនគ្រាន់ថា ឌុច បង្រៀនសូត្រ -- អ៎! បង្រៀនបុគ្គលិកជាទូទៅហ្នឹង ឲ្យរៀនសូត្រតាមវិធីសាស្ត្រដែលគាត់បង្ហាញ ដែលគាត់ប្រាប់។ ប្រើវិធីទី១ហ្នឹង គឺក្រុមត្រជាក់, វិធីទី២ -- អ៎! ទី១ ក្រុមក្តៅអ៊ីចឹង, ទី២ ក្រុមត្រជាក់, ទី៣ ក្រុមអង្កៀមអ៊ីចឹង។ ឲ្យតាមក្រុមមួយៗហ្នឹង ត្រូវធ្វើការតាមណែនាំរបស់គាត់ ព្រោះក្រុមក្តៅ យើងយកទៅ សួរក្តៅ សួរវ៉ៃ ធ្វើទារុណកម្មអី។ ដល់ក្រុមត្រជាក់ យើងយកទៅ យើងសួរឲ្យរបៀបថាស្លូតត្រជាក់ ធ្វើនយោបាយឲ្យអ្នកទោសហ្នឹង ជឿទុកចិត្តលើយើង ហើយដល់ក្រុមអង្កៀម អាហ្នឹងបានន័យថានៅអង្កៀម សួរចុះសួរ សាចុះសាឡើង ទាល់តែអ្នកទោសហ្នឹង វិលវល់ទាល់ច្រក។ ហ្នឹងជាវិធីសាស្ត្ររបស់គាត់ ដែលគាត់បានបង្ហាត់បង្ហាញ។

**ស៖** អ្វីដែលលោកលើកឡើង ហាក់បីដូចថា ក្រុមអង្កៀមហ្នឹង គឺ E3/2007, ERN ជាភាសាខ្មែរ 00039568, អង់គ្លេស 00233755, បារាំង 00863798។ ឯកសារនេះ និយាយអំពីក្រុមអង្កៀម ដែល ឡាច មាន <ក៏ជាសមាជិកដែរ។ ឯកសារនេះចុះកាលបរិច្ឆេទ>ថ្ងៃទី២៤ ខែឧសភា ៧៨។ ចុះហត្ថលេខាដោយក្រុមអង្កៀម មានមនុស្សម្នាក់អាចឈ្មោះ ណាន ឬក៏ ណន។ លោកដឹងថា ណាន ឬក៏ ណន នេះ ជាអ្នកណា? ជាប្រធានក្រុមអង្កៀម មែនឬ?

**ឆ៖** បាទ ឈ្មោះ ណាន មាន។ ណាន, ឈិន, ទិត ជាដៃស្តាំរបស់ ឌុច យកពីអមលាំងមក បីនាក់ហ្នឹង។ អ៊ីចឹង ណាន ហ្នឹង ខ្ញុំជាទូទៅ ខ្ញុំឃើញនៅកន្លែងគុកពិសេស មិនដែលឃើញមកនៅក្នុងកន្លែងសួរចម្លើយធម្មតាទេ។ ឃើញតែនៅចេញចូលៗ កន្លែងគុកពិសេស។ អ៊ីចឹង ណាន, ឈិន សុទ្ធតែក្បាលទំពែកដូចគ្នា ហើយក្មេងៗ អត់មានសក់ទេ ខ្មៅក្រញេសៗ អ្នកអមលាំង។ អ៊ីចឹង ណាន ហ្នឹង មិនមែនមកនៅកាន់ក្រុមអង្កៀមទេ គឺនៅខាងគុកពិសេសនោះ។ ទិត ហ្នឹងបាននៅខាងក្រុមអង្កៀម។

[១៤:០៩:១៨]

**ស៖** ឥឡូវនេះ ខ្ញុំនិយាយអំពីការសួរចម្លើយចំនួន២០លើក ដែលលោកបាននិយាយនោះ។ តើលោកតែងតែប្រើវិធីសាស្ត្រអង្កៀមជាមួយនឹងការសួរចម្លើយអ្នកទោស២០នាក់ ២០លើកនេះ ឬក៏លោកប្រើវិធីសាស្ត្រក្តៅ វិធីសាស្ត្រត្រជាក់ដែរ?

**ឆ៖** បាទ ការសួរចម្លើយក្នុងក្រុមអង្កៀមនេះ គឺមិនមែនដឹងតែសួរ មិនធ្វើទារុណកម្មទេ គឺសួរ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ផង សួរត្រជាក់ផង សួរក្តៅផង ធ្វើហិង្សាផង អ៊ីចឹងវារួមផ្សំទាំងអស់។

**ស៖** ខ្ញុំ ឥឡូវនេះសូមកម្រិតការសួររបស់ខ្ញុំតែទៅលើលោកទេ គឺការ<សួរចម្លើយ២០នាក់ដែលលោក>ពាក់ព័ន្ធ។ <តើ>ខ្លួនលោកផ្ទាល់តែម្តង បានប្រើប្រាស់វិធីសាស្ត្រទាំងបី<នេះទេ> ប្រសិនណាជាចាំបាច់ ទាំងវិធីក្តៅ វិធីអង្អៀម វិធីត្រជាក់?<> អ៊ីចឹងឆ្លើយរង្វង់ត្រឹមខ្លួនលោកហ្នឹងបានហើយ។

**ឆ៖** បាទ អាហ្នឹងវាមានដូចខ្ញុំបានរៀបរាប់ប្រាប់អ៊ីចឹង គឺមានប្រើធម៌ត្រជាក់ ធម៌ក្តៅ អាហ្នឹងអង្អៀមនេះ គឺពាក្យអង្អៀមហ្នឹង គឺនៅតាមត្រាំត្រែងយូរអង្វែង មិនមែនអង្អៀមអត់វ៉ៃ អត់ធ្វើបាបទេ។

**ស៖** ប្រហែលជាខ្ញុំគួរកម្រិតខ្លួនខ្ញុំសួរទៅលើការសួរចម្លើយតែមួយមុខណាឲ្យច្បាស់លាស់។ ឥឡូវពាក់ព័ន្ធទៅនឹង អេង ម៉េង<ហ៊ាង ហៅ ឆុន> គឺ <E3/1549> គឺការសួរចម្លើយដោយលោកផ្ទាល់។ តើលោកមានប្រើវិធីក្តៅជាមួយនឹងអ្នកទោសម្នាក់នេះទេ? ហើយបើសិនណាជាមានប្រើមែន តើលោកប្រើ<មួយ>ណា?

**ឆ៖** បាទ អ្នកទោសម្នាក់ដែលឈ្មោះ ឆុន ហ្នឹងគឺខ្ញុំបានសួរដោយផ្ទាល់ ហើយកាលណោះក៏មានប្រើទារុណកម្មដែរ ប៉ុន្តែគ្រាន់តែប្រើតិចតួច។

**ស៖** តើលោកធ្វើយ៉ាងដូចម្តេចជាមួយគាត់នុ៎ង?

[១៤:១២:២៧]

**ឆ៖** បាទ ធ្វើទារុណកម្មហ្នឹង គឺកាច់មែកត្របែក មែកទៀប ក្បែរៗកន្លែងនៅហ្នឹងយកមកវ៉ៃ ដៃ វ៉ៃជើង វ៉ៃខ្នងអីហ្នឹង។

**ស៖** <ហើយដោយពិតប្រាកដទៅ តើលោកធ្វើយ៉ាងម៉េច? តើ>លោកទុកគាត់នៅក្នុងបន្ទប់ លោក<>ចេញទៅក្រៅ<>កាច់មែកឈើ ហើយវាយទៅលើអ្នកទោសរូបនេះ?

**ឆ៖** បាទ អ្នកទោសនៅខាងក្នុងបន្ទប់ ហើយមែកឈើនៅ ថានិយាយឲ្យចំប្រហែល១ម៉ែត្រ ២ម៉ែត្រអីពីជញ្ជាំងផ្ទះហ្នឹង ក្បែរៗផ្ទះហ្នឹង វាមានមែកឈើ មែកអីហ្នឹង គ្រាន់តែឈោងកាច់ ប៉ុន្តែចំហទ្វារផ្តុង មើលឃើញ។

**ស៖** តើលោកនៅចាំទេ ហេតុម៉េចបានជាពេលនោះ រំពេចនោះឲ្យលោកសម្រេចចិត្តថាធ្វើទារុណកម្មវាយគាត់នឹងមែកឈើនេះ?

**ឆ៖** បាទ ខ្ញុំសូមមិននិយាយ។

**ស៖** ម៉េចបានមិននិយាយអ៊ីចឹងលោកសាក្សី?

**ឆ៖** បាទ សូមមិននិយាយ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំយល់ហើយថា សាក្សីគឺថាមិនត្រូវឆ្លើយដាក់បន្ទុកលើខ្លួនឯងទេ ក៏ប៉ុន្តែគាត់បានឆ្លើយរួចមកហើយហ្នឹងថា គាត់បានវាយអ្នកទោសនឹងមែកឈើហ្នឹង។ អ៊ីចឹងខ្ញុំ<មិនយល់>ថា <តើវាអាចដាក់បន្ទុកខ្លួនគាត់យ៉ាងម៉េចទៀត បើគាត់និយាយអំពីមូល>ហេតុ<នោះ>?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មេធាវីប្រឹក្សាប្រហែលលោកអាចខ្សឹបៗជាមួយកូនក្តីរបស់លោក នេះជានាទីរបស់លោកហើយ។

*(សាក្សីពិភាក្សាជាមួយមេធាវីប្រឹក្សា)*

[១៤:១៥:៥៥]

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ រឿងនេះ ដែលខ្ញុំថាមិននិយាយនោះ មកពីរឿងនោះ វាបាននិយាយច្រើនសា ច្រើនលើកមកហើយ ប៉ុន្តែគ្រាន់ថា ខ្ញុំមិនចង់និយាយតទៅទៀត ព្រោះជារឿងបន្ទុកលើខ្ញុំ។ ប៉ុន្តែបើថា ចង់ដឹងខ្ញុំនិយាយតទៀត។ ថាវ៉ៃនឹងរំពាត់ គឺវ៉ៃដោយសារ អ្នកទោសហ្នឹងប្រើពាក្យក្រឡេចក្រឡុចម្តងអ៊ីចេះ ម្តងអ៊ីចុះ អ៊ីចឹងខ្ញុំត្រូវប្រើ ហៅថាប្រើពាក្យគំរាម ពាក្យបន្លាចឱ្យអ្នកទោសហ្នឹងមានការភ័យខ្លាចអ៊ីចឹងទៅបានវ៉ៃខ្លះ និយាយខ្លះ។ ហ្នឹងដែលខ្ញុំកាច់មែកឈើរំពាត់យកមកវ៉ៃហ្នឹង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំយល់ហើយលោកសាក្សី តើផ្នែកមួយណានៃចម្លើយរបស់គាត់ គាត់ឆ្លើយក្រឡេចក្រឡុចហ្នឹង គាត់ឆ្លើយក្រឡេចក្រឡុចយ៉ាងដូចម្តេចដែរ? <តើអ្វី>ដែលធ្វើឱ្យលោកសម្រេចចិត្តវាយ<នរណាម្នាក់ជាលើកដំបូង>នោះ?

**ឆ៖** ខ្ញុំមិនអាចចាំបាននូវចំណុចណាដែលគេក្រឡេចក្រឡុចមិនព្រមនិយាយទេ ព្រោះដឹងថាគ្រាន់តែពេលកាលហ្នឹង វាមានពាក្យក្រឡេចក្រឡុច មិនព្រមនិយាយ មិនព្រមអី ម្តងថានិយាយ ម្តងថាមិននិយាយអ៊ីចឹង អាហ្នឹងបានខ្ញុំស្នើយោបល់ទៅសុំយោបល់ទៅថ្នាក់លើហ្នឹង ហើយថ្នាក់លើក៏ឱ្យធ្វើទារុណកម្មហ្នឹង បានខ្ញុំធ្វើទៅ។ ប៉ុន្តែត្រង់ចំណុចណាមួយខ្ញុំមិនចាំបានទេ។

**ស៖** នេះជាឧទាហរណ៍។ នេះគឺជាលើកទី១ ដែលលោកវាយដំ ឆុន ហ្នឹង ហើយអ្នកណាបញ្ជាឱ្យលោកប្រើប្រាស់មែកឈើដើម្បីធ្វើទារុណកម្មគាត់នោះ?

**ឆ៖** បាទ ឌុច។

**ស៖** តើលោកវាយគាត់អស់រយៈពេលយូរប៉ុនណាដែរ? <តើលោកវាយគាត់ប៉ុន្មានរំពាត់ដែរលើកដំបូងនោះ?>

**ឆ៖** កាលនោះមិនជាយូរអីទេ ព្រោះ ឆុន ហ្នឹងគាត់ចេះសរសេរ គាត់ជាសាស្ត្រាចារ្យផង អ៊ីចឹងគាត់សរសេររៀបរាប់ទាំងអស់ ប៉ុន្តែគ្រាន់ថានៅចំណុចណាដែលសរសេរទៅនិយាយស្ដាប់មិនបានអីអាហ្នឹងក៏មានបញ្ហាដែលត្រូវវ៉ៃ ត្រូវអីមាន ប៉ុន្តែដល់ក្រោយៗមក ក៏គាត់សរសេររៀបរាប់បានច្បាស់ល្អ។

[១៤:១៨:៤៧]

**ស៖** ចុះលោកវាយគាត់នឹងមែកឈើហ្នឹងប៉ុន្មានដងដែរ?

**ឆ៖** អត់ចាំទេ សាមសិបឆ្នាំជាងហើយ។

**ស៖** តើមានពេលណាមួយទៀត ឬថ្ងៃណាមួយទៀត លោកវាយគាត់ទៀតទេ?

**ឆ៖** មិនបានចាំ។

**ស៖** តើលោកមានប្រើវិធីក្ដៅជាមួយនឹងគាត់ទេ?

**ឆ៖** បាទ ធ្វើទារុណកម្មហ្នឹងហើយ ដែលវិធីក្ដៅ។

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែ តើលោកវាយគាត់<>តែនៅថ្ងៃហ្នឹងម្ដង ឬក៏លោកវាយគាត់ម្ដងហើយម្ដងទៀតៗ?

**ឆ៖** រឿងធ្វើទារុណកម្មហ្នឹងមិនមែនម្ដងទេ គឺច្រើនដង ប៉ុនថាដឹងប៉ុន្មានៗដងខ្ញុំមិនចាំទេ។

**ស៖** តើលោកមានប្រើខ្សែទូរស័ព្ទ ឬក៏ខ្សែភ្លើងដើម្បីឆក់គាត់ទេ?

**ឆ៖** ចំពោះអ្នកទោសម្នាក់នេះ អត់ដែលបានធ្វើទេកាលណោះ រឿងខ្សែទូរស័ព្ទ ខ្សែអី ក្រោយមកបានមានឆក់មានអី អាហ្នឹងរឿងមុនអត់ទេ។

**ស៖** <តើ>វិធី<សាស្ត្រ>នេះ <គេបានណែនាំឲ្យលោក>ប្រើនៅពេលណាដែរ?

**ឆ៖** ប្រើវិធីឆក់នេះ ប្រើនៅពេលក្រោយៗមកទៀត។

**ស៖** ចុះលោកមានប្រើថង់ប្លាស្ទិក ស្បោងប្លាស្ទិកដើម្បី ធ្វើឲ្យគាត់ថប់ដង្ហើមទេ?

**ឆ៖** មាន វិធីនេះមាន។

**ស៖** សំណួររបស់ខ្ញុំសួរថាតើលោកមានប្រើថង់ប្លាស្ទិកនេះ ជាមួយ ឆុន ទេ?

**ឆ៖** អត់ទេ អត់មានប្រើទេ ជាមួយ ឆុន ហ្នឹងអត់មានទេ។

**ស៖** តើលោកនៅចាំទេ មានពេលណាមួយលោក<បន្ទាបបន្ថោក> ផុន <ធ្វើឲ្យអាម៉ាស់មុខ> ទេ?

**ឆ៖** បំភ័យ ប៉ុន្តែថា ពេលណា ម៉ោងណា ខ្ញុំមិនបានចាំច្បាស់ទេ ប៉ុនគ្រាន់តែដឹងថាមាន។

**ស៖** ខ្ញុំមិនចូលនិយាយលម្អិតទេ ក៏ប៉ុន្តែតើលោកដឹងការចោទប្រកាន់ទៅលើ ផុន នេះ ជារួមគឺថា ផុន នេះត្រូវបានចោទប្រកាន់ពីអ្វីដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៤:២២:៥២]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ ដូចដែលមេធាវីការពារក្តីជំទាស់ខ្ញុំកាលពីម្សិលមិញអ៊ីចឹង។ យើងដឹងហើយសាក្សីនេះគាត់និយាយ<ថា> គាត់<>អត់បានទទួលឯកសារ<ណាមួយ ចោទប្រកាន់>ប្រឆាំងនឹង<អ្នកទោស>នោះទេ។ <វាស្រេចលើគាត់ក្នុងការស្វែងរកនូវអ្វីដែលខ្លាំងបានធ្វើ> អ៊ីចឹង <>សំណួរនេះចោទមិនត្រូវទេ។ <គាត់ត្រូវរកឲ្យឃើញដោយខ្លួនគាត់ វាមិនអាស្រ័យលើ>អ្នកទោស<>ប្រាប់គាត់ <ឬនរណាម្នាក់ប្រាប់គាត់ ថាគាត់ត្រូវបានគេចោទប្រកាន់>អំពីរឿងអ្វីខ្លះនោះ<ទេ>។

**លោក វិុចទ័រ កូប៉េ៖**

ឥឡូវនេះសហព្រះរាជអាជ្ញារងអន្តរជាតិ ហាក់បីដូចជាផ្តល់សក្ខីកម្មជំនួសឲ្យសាក្សី។ តាមការកត់សម្គាល់របស់ខ្ញុំ ខ្ញុំកម្រិតសំណួរខ្ញុំតែព្រឹត្តិការណ៍ជាក់លាក់តែប៉ុណ្ណោះ ហើយសំណួររបស់ខ្ញុំនេះគឺអង្គជំនុំជម្រះគួរអនុញ្ញាតឲ្យខ្ញុំសួរ ដូចខ្ញុំសួរគ្រាន់ថា ជាទូទៅនោះ តើគេចោទប្រកាន់ទៅលើ ផុន ហ្នឹងពីបទអ្វីដែរ?

**ប្រធានអង្គជំនុំ៖**

បាទ សំណួរនេះអាចសួរបាន ហើយបដិសេធនូវសេចក្តីជំទាស់។ សាក្សីឆ្លើយតបនឹងសំណួរដែលសួរនេះ។ សមស្របនឹងសួរ អាចសួរបានហើយ។

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ ឈ្មោះ ផុន នេះ គឺកាលខ្ញុំសួរ គឺគាត់សារភាពគាត់ថា ជាខ្សែ សេ.អ៊ី.អា។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមងាកចេញពីចំណុចនេះចុះ។ លោកសាក្សីខ្ញុំចង់និយាយអំពីរយៈពេលមួយខែ ឬពីរខែ មុនពេលលោកសួរចម្លើយ ឆុន។ ប្រហែលជានិយាយសំដៅឲ្យចំខែមករា ឆ្នាំ៧៧ នៅពេលនោះ តើលោកមានបានឮផែនការធ្វើរដ្ឋប្រហារ ការចាប់ផ្ដើមធ្វើការបះបោរ ដែលដឹកនាំដោយ កុយ ធួន, ចាន់ចក្រី, យ៉ា ដែលជាលេខាភូមិភាគពាយ័ព្យ លោកមានបានឮអំពីរឿងនេះទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹង បានឮទេ រឿងនេះ ទើបតែឮពេលហ្នឹង។

**ស៖** ខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យយកខ្លឹមសារនៃចម្លើយសារភាពមកសួរលោកទេ ក៏ប៉ុន្តែ<ខ្ញុំមិនដឹងថាចម្លើយនោះសមល្មមនឹងជឿឬអត់ទេលោកសាក្សី។ ប៉ុន្តែ>តើលោក<>ធ្លាប់ដែលឮការពាក់ព័ន្ធរបស់ កុយ ធួន <ជាមួយ>មេបញ្ជាការកងពល ឈ្មោះ អឿន, មេបញ្ជាការឈ្មោះ សឿង <មកពីកងពល៤៥០> ដែលអ្នកទាំងនេះ ចូលរួមពាក់ព័ន្ធនៅក្នុងផែនការផ្ដួលរំលំរបបស្របច្បាប់របស់កម្ពុជាប្រជាធិបតេយ្យ។ លោកធ្លាប់ដែលឮទេ?

**ឆ៖** បាទ អត់ដែលឮទេ។

[១៤:២៧:១១]

**ស៖** តើនៅពេលណាមួយ លោកធ្លាប់ឮការចោទប្រកាន់ទៅលើ កុយ ធួន ទេ?

**ឆ៖** បាទ ខ្ញុំដឹងថា គេចាប់ខ្លួន កុយ ធួន ប៉ុន្តែត្រង់ផែនការយ៉ាងណាៗនោះ គឺមិនបានដឹងទេ។

**ស៖** ខ្ញុំហៀបនឹងយកចំណុចនេះមកសួរហើយ ក៏ប៉ុន្តែខ្ញុំមិនយកទេ ប៉ុន្តែខ្ញុំសូមរំឭកដល់ការចងចាំរបស់សាក្សី។ លោកសាក្សី ចាន់ គឺជាមេកោយរបស់លោកមែនទេ?

**ឆ៖** ចាន់ គឺមិនៗឃើញមានតួនាទីអីឲ្យពិតប្រាកដនៅក្នុងហ្នឹងទេ ប៉ុនគ្រាន់ថាដឹង ឃើញនៅកន្លែង ឌុច ចេញចូល។ ការងាររបស់ ឌុច ហ្នឹង គឺគាត់ប្រៀបដូចថាជំនួយការរបស់ ឌុច ហ្នឹងហ្នង។

**ស៖** លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញសម្រង់មួយចេញពី<>សៀវភៅកត់ត្រារបស់ចាន់។ ជា<>សម្រង់ដែល<>សរសេរ<ក្នុងទម្រង់មួយ ដែលដូចជាមិន>យកចេញពីចម្លើយសារភាព<ទេ។ វាហាក់ដូចជាផលិតផលនៃ>អ្វីដែលគាត់ឮពីការសិក្សារៀនសូត្រ គឺឯកសារ E3/833, ERN ជាភាសាខ្មែរ 00077826 មិនមានការបកប្រែជាភាសាបារាំងទេ។ ខ្ញុំនឹងលើកយក<ចំណុចនេះ>មកបង្ហាញដាច់ដោយឡែក<ពីគ្នា ព្រោះវាហាក់ដូចជាមាន>ការបកប្រែទៅជាបារាំង<មួយផ្នែក> និងការបកប្រែទៅជាភាសាអង់គ្លេស<មួយផ្នែក>។ ខ្ញុំសូមបង្ហាញឯកសារចេញពីកំណត់ត្រារបស់ឈ្មោះ ចាន់

នេះ ដើម្បីជួយរំឭកដល់ការចងចាំរបស់សាក្សី។ សូមការអនុញ្ញាត។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

តើលោកអាចផ្តល់លេខ ERN ម្តងទៀតបានទេ? ព្រោះថាខ្ញុំ<>កត់អត់ទាន់អម្បាញ់មិញ។

[១៤:៣០:២៩]

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកសារដែលខ្ញុំមាននៅក្នុងដៃនេះ គឺដូចជាចម្លែកបន្តិចដែរ លោកចៅក្រម ឡាវែន៍។ ឯកសារនេះ មាន E3 គឺឯកសារ E3/833 ប៉ុន្តែអត់មានឃើញ ERN <>ជាអង់គ្លេសទេ តែរកឃើញ ERN ជាភាសាខ្មែរ។ ដោយសារសរសេរឯកសារដើម គឺសរសេរជាភាសាខ្មែរ។ <វាហាក់ដូចជាអត់មានលេខ ERN ជាភាសាបារាំងនៅលើទំព័រពិសេសនេះទេ។> អ្វីដែលខ្ញុំខិតខំប្រឹងប្រែងរកឲ្យឃើញនេះ គឺគេមានបកទៅជាភាសាអង់គ្លេស នៅកន្លែងណាមួយផ្សេង ឬបារាំងនៅកន្លែងណាមួយផ្សេង មានភាពច្របូកច្របល់អ៊ីចឹងមែន។ ប៉ុន្តែអ្វីដែលខ្ញុំមានចំពោះមុខនេះ មានតែជាភាសាខ្មែរ គឺE3/833។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ក្នុងលក្ខខណ្ឌនេះ តើយើងអាចពិនិត្យមើលខ្លឹមសារនៃឯកសារដែលលោកចង់បង្ហាញទៅសាក្សីហ្នឹងយ៉ាងម៉េចដែរ? ព្រោះថា ខ្ញុំសមត្ថភាពយល់ភាសាខ្មែរហ្នឹងមានកម្រិតណាស់។ តើយើងពិនិត្យពិចារណាយ៉ាងម៉េច?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមាន ERN ជាភាសាអង់គ្លេស។ ខ្ញុំមិន<មែនជាអ្នកបង្កើត>ឯកសារនេះ<ទេ។> ខ្ញុំនេះ គឺ E3/833 មានចំណងជើងថា “សៀវភៅកត់ត្រារបស់ ចាន់”។ <វានិយាយពី “អត្ថបទគន្លឹះសំខាន់”> ERN ជាភាសាអង់គ្លេសដែលសរសេរនោះគឺ 00184579 ប៉ុន្តែយើងបានរកឃើញ ERN ចេញពីឯក-សារនេះ គឺ 00077826។ អ៊ីចឹងហើយបានជាខ្ញុំសូមបង្ហាញជាភាសាខ្មែរ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<>មានលេខ ERN ជាភាសាអង់គ្លេសអ៊ីចឹង <តើជាការ>បកប្រែ<ពីភាសាខ្មែរដែលលោកចង់បង្ហាញនោះឬ? តើខ្ញុំយល់ត្រឹមត្រូវ>ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីលោកមេធាវី មកបង្ហាញលោកស្រីចៅក្រម។

**លោក វ៉ិចទ័រ កូប៉េះ**

ឥឡូវនេះ <ដើម្បីប្រតិចារឹក> ខ្ញុំសូមឲ្យ ERN ជាភាសាអង់គ្លេសពេញលេញតែម្តង គឺ 00184579 ដល់ 00184618។

[១៤:៣៣:៥១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំសូមការបំភ្លឺមួយ ខ្ញុំមិនយល់ច្បាស់ថា តើទំព័រដែលលោកមេធាវីចង់ប្រើនោះ ត្រូវបានបកប្រែជាភាសាបារាំង ឬក៏អង់គ្លេស ឬអត់ទេ។ បើតាមខ្ញុំយល់ ដូចអត់មានទេ។ <ប៉ុន្តែ តើគាត់អាចបញ្ជាក់បានទេ? ព្រោះខ្ញុំជឿ>ថា មានការបកប្រែដោយផ្នែកជាភាសាបារាំង និងអង់គ្លេស។ ក៏ប៉ុន្តែ<>ទំព័រដែលយកមកប្រើនៅទីនេះ វាអត់មានជាភាសាបារាំង ឬភាសាអង់គ្លេសទេ។ <តើខ្ញុំយល់ត្រឹមត្រូវទេ?>

**លោក វ៉ិចទ័រ កូប៉េះ**

មិនអ៊ីចឹងទេ មិនត្រឹមត្រូវទេ។ មានការបកប្រែជាភាសាអង់គ្លេស នេះតាមដែលខ្ញុំដឹង។ សហព្រះរាជអាជ្ញាកាលពីម្សិលមិញ ក៏បានប្រើប្រាស់ឯកសារដែលមានការបកប្រែតែជាភាសាបារាំងដែរ។ តាមដែលខ្ញុំយល់នោះ គឺឯកសារជាភាសាខ្មែរនេះ គឺត្រូវបានបកប្រែខ្លះៗទៅជាភាសាអង់គ្លេស ហើយនិងបកប្រែទៅជាភាសាបារាំងខ្លះ ប៉ុន្តែមានភាពច្របូកច្របល់គ្នា មិនទំនាក់ទំនងគ្នាទេ។ នេះស្ថានភាពឯកសារវាយ៉ាងដូច្នេះឯង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

<នៅពេលលោកនិយាយថា មិនមានទំព័រជាក់លាក់ តើទំព័រជាក់លាក់មួយណាដែល>លោកចង់និយាយ<នោះ?> ខ្ញុំមិនយល់។ ខ្ញុំចង់និយាយថា ទំព័រដែលលោកកំពុងប្រើហ្នឹង ឬក៏យ៉ាងម៉េច?

[១៤:៣៥:០៨]

**លោក វ៉ិចទ័រ កូប៉េះ**

<អ្វីដែល>ខ្ញុំ<នឹង>ប្រើប្រាស់<គឺទំព័រ>ភាសាខ្មែរនិងភាសាអង់គ្លេស ដែល<យកមកពីឯកសារតែមួយ។> ខ្ញុំមិនដឹង<ថាតើមានការបកប្រែជាភាសាបារាំងឬអត់ទេ។ ប៉ុន្តែប្រហែលជាអត់មានទេ។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញានឹងនិយាយដូច្នោះដែរ>។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមបញ្ជាក់លោកប្រើប្រាស់អត្ថបទជាភាសាខ្មែរ ដែលអង់គ្លេសនោះគឺ 00184579 ដល់ 4618 អ៊ីចឹងមែនទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ត្រឹមត្រូវហើយលោកស្រីចៅក្រម។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំកំណត់ទំព័រហ្នឹងហើយ ខ្ញុំអាចជួយទៅលោកមេធាវីបាន។ ជាភាសាអង់គ្លេសគឺ 00184591 និងជាផ្នែកមួយដែលទាក់ទងនឹងខែកុម្ភៈ ឆ្នាំ១៩៧៨ មានឈ្មោះ <សុត>, <ឈូក>, <ចក្រី>។ ខ្ញុំគិតថា ផ្នែកនេះមិនមានការបកប្រែជាភាសាបារាំងទេលោកប្រធាន។

[១៤:៣៦:០៩]

**លោក វ៉ិចទ័រ កូប៉េ៖**

ពិតហើយលោកសហព្រះរាជអាជ្ញា គឺជាសម្រង់ហ្នឹងឯង។ <ខ្ញុំគិតថា សាក្សីមានអត្ថបទដើមជាភាសាខ្មែរហ្នឹងហើយ។>

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី <តើលោកមានពេលដើម្បីអានសម្រង់នេះបាន>ទេ?

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ អត់មានឃើញឯកសារផង។

[១៤:៣៧:២៧]

**ស៖** ឥឡូវខ្ញុំសូមអានឲ្យលោកស្តាប់<>ជាភាសាអង់គ្លេស។ ជាភាសាអងគ្លេសហ្នឹងគឺ "គឺមានពួកអាសុត, អាឈូក, អាចក្រី ជាឈ្នាន់។ ខែមិថុនា ៧៦ ធ្វើរដ្ឋប្រហារ<ជាមួយ>អា<>ចក្រី ជាស្នូលគឺវាយមជ្ឈិមបក្ស ពិសេសបងទី១, បងទី២។ ក្រោយមកទៀត គឺកង អាអឿន ក្បាលម៉ាស៊ីន គឺបក្សពលករកម្ពុជា ដែល<មាន>ចក្រពត្តិអាមេរិក ដែលមានពួកអាយួន, អាសូវៀត នៅពីលើ។ វាប្រុង<នឹងចាប់បង>នៅបុរីកីឡា។ យើងចាប់បានចំនួនច្រើន ពិសេស គឺ១៧០។ កម្លាំងយួន និង សូវៀត រលំរលាយ នៅសល់តែកម្លាំង អាធុច<>"។ <ខ្ញុំសន្និដ្ឋានថា ទាំងអស់នេះជាកំណត់ហេតុ ដែលកត់ក្នុងវគ្គសិក្សារៀនសូត្រមួយ។ ប៉ុន្តែខ្ញុំមិនច្បាស់ទេ។> ឥឡូវនេះ សំណួរខ្ញុំសួរថា តើ<>លោកស្គាល់អក្សរ

សរសេរដោយដៃនេះទេ? <តើលោកស្គាល់អត្ថបទនេះទេ?>

**ឆ៖** បាទ អក្សរនេះ ខ្ញុំមិនដឹងជាអក្សរអ្នកណាទេ។

**ស៖** មិនបញ្ហាអ្វីទេ លោកនៅចាំខ្លឹមសារនៃឯកសារនេះទេ<?> តើខ្លឹមសារនៃឯកសារនេះ វាជួយរំឭកដល់ការចងចាំរបស់លោកនៅពេលដែលលោកសួរចម្លើយ ឆុន នោះទេ?

[១៤:៣៩:១៩]

**ឆ៖** បាទ ឯកសារនេះគឺអត់មានពាក់ព័ន្ធទៅចម្លើយរបស់ ម៉េង ហៅ ឆុន ទេ។

**ស៖** ឥឡូវទុក ឆុន នេះមួយពន្លើសិនចុះ។ តើលោកនៅចាំឯកសារនេះដែលនិយាយពីផែនការរដ្ឋប្រហារដឹកនាំដោយ កុយ ធួន និងមេបញ្ជាការកងពលម្នាក់ទៀតឈ្មោះ អឿន លោកដឹងដែរទេ?

**ឆ៖** បាទ ផែនការនេះខ្ញុំអត់ដឹងទេ ព្រោះរឿងការងារពួកខាងលើៗ ហើយខ្ញុំជាស្រមោចសង្អារខាងក្រោម អាចនឹងដឹងរឿងនេះដែរអត់ទេ ព្រោះខ្ញុំអត់ដឹងសុទ្ធរឿងអស់នេះ ហើយគេខាងលើក៏គេមិនមកប្រាប់ខ្ញុំថាគេចាប់បានអ្នកនេះអ្នកនោះដែរ អត់ដឹងសុទ្ធ ដល់ក្រោយៗមកបានដឹងថា ពួកហ្នឹងត្រូវគេចាប់ហើយទេ។ អ៊ីចឹងផែនការគេរៀបចំយ៉ាងណា គេអត់ដែលបានប្រាប់ យើងខ្ញុំឲ្យបានដឹងទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតៗដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៤:៥៩ នាទី)*

[១៤:៥៩:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅសហមេធាវីអន្តរជាតិការពារក្តីលោក នួន ជា លោក វ៉ិចទ័រ កូប៉េ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

អរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជាដំបូង ខ្ញុំសូមអភ័យទោស ដើម្បីជម្រាបបញ្ជាក់អំពីឯកសារ E3/833 ដោយសារការបោះពុម្ពថតចម្លងមកមិនបានបង្ហាញ ERN តាមពិតវាមាន ERN ជាអេឡិចត្រូនិច។ ប៉ុន្តែដោយកូពីទៅវាផុត វាដាច់ អ៊ីចឹងគឺសូមអភ័យទោស។ លោកសាក្សីខ្ញុំបានអានជូនលោកអំពីកំណត់ហេតុរបស់ ចាន់ អំពី កុយ ធួន, ចក្រី ជាដើម។ តើវាបានរំឭកការចងចាំដល់លោកទេ? ឥឡូវនេះ ខ្ញុំព្យាយាមចុងក្រោយដើម្បីសួរលោកពាក់ព័ន្ធទៅនឹង កុយ ធួន ហើយនិងមេបញ្ជាការកងពលឈ្មោះ អឿន ដែលថាពួកគាត់សហការគ្នាដើម្បីធ្វើរដ្ឋប្រហារ។ ចំពោះមុខខ្ញុំនេះ ខ្ញុំមានចម្លើយរបស់កម្មាភិបាលនារីជាសមាជិករបស់កងពល៣១០ គឺថាឯកសារ <E3/7540> ខ្ញុំនឹងអានពី ERN 00337712 ហើយខ្ញុំទើបតែបញ្ចប់ ERN ខ្មែរ <00055078>, បារាំង <00364274>។

[១៥:០១:៥៨]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ លោកប្រធាន នៅក្នុងសេចក្ដីផ្ដើមអម្បាញ់មិញនេះ ខ្ញុំឮមេធាវីការពារក្ដីគាត់និយាយថា កុយ ធួន និង អឿន បានរៀបចំផែនការរដ្ឋប្រហារ។ <ខ្ញុំមិនគិតថា មេធាវីការពារក្ដីបានបង្កើតមូលដ្ឋានក្នុងការអះអាងដូច្នេះនៅពេលនេះទេ ក្រៅពីផ្អែកទៅលើធនធានដែលបានមកពីចម្លើយសារភាពនៅស-២១នោះទេ>។ <ខ្ញុំគិតថា មេធាវីការពារក្ដី>គួរតែ<>រៀបចំ<>ឡើងវិញ<ដោយផ្អែកលើមូលដ្ឋានសម្រាប់បញ្ហានេះ>។ សូមអរគុណ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនយល់ពីការជំទាស់នេះទេ <លោកប្រធាន។ ខ្ញុំនឹងប្រាប់>ពី<>មូលហេតុ។ <ថ្មីៗនេះ> យើងបានដាក់ពាក្យស្នើសុំសាក្សីប្រាំមួយរូប<បន្ថែម>មកពីកងពល៣១០ ដែលនិយាយអំពីរដ្ឋប្រហារជាផែនការរបស់ កុយ ធួន និង មេបញ្ជាការកងពល អឿន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកមេធាវី មិនទាន់មានអ្វីត្រូវបានបង្កើតឡើងទេ រហូតទាល់តែអង្គជំនុំជម្រះបង្កើតវាឡើង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សិន។ សូមប្រយ័ត្ននឹងភាសានិយាយនេះ។>

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** <ខ្ញុំប្រាប់ប្រាស់ពាក្យថា "បង្កើតឡើង" ពីព្រោះនោះជា>អ្វីដែល<>សហព្រះរាជអាជ្ញា <និយាយពីវា។ ហើយខ្ញុំពន្យល់។ ប៉ុន្តែ> ខ្ញុំ<ពិតជា>មិន<យល់ថា>ហេតុ<អីបានជាខ្ញុំត្រូវបន្តពន្យល់>ពីភស្តុតាងដែលយើងមាននោះទេ។ <មើលទៅលោកស្រីចៅក្រមដូចជាខឹង ប៉ុន្តែរឿងគឺវាអ៊ីចឹង។> ប៉ុន្តែលោកប្រធាន ខ្ញុំមានចំពោះមុខខ្ញុំ<នូវឯកសាររបស់>មជ្ឈមណ្ឌលឯកសារកម្ពុជា។ <លោកសាក្សី ខ្ញុំនឹងអានឲ្យលោកស្តាប់។ ដូចខ្ញុំនិយាយអ៊ីចឹង>ឯកសារ<គឺជាកិច្ច>សម្ភាសន៍ <>ជាកម្មាភិបាលនារី ដែលបានពាក់ព័ន្ធនៅក្នុងការប៉ុនប៉ងធ្វើរដ្ឋប្រហារ។ ក្រោយមក ត្រូវបានគេបញ្ជូនទៅព្រៃស។ ហើយនៅក្នុងកំណត់<>ហេតុស្តាប់ចម្លើយរបស់ ឌី.ស៊ី.ខេម គាត់និយាយថា "តើលោក<ស្រី>ស្ថិតនៅក្រោមការដឹកនាំរបស់ អឿន <នៅក្នុង>កងពល<នេះ>ទេ? គាត់ឆ្លើយថា ចាស។ បន្ទាប់ពីរំដោះបានទីក្រុងភ្នំពេញគេចាប់ អឿន តើលោកស្រីដឹងទេ? ចម្លើយ៖ ខ្ញុំបានដឹងនៅពេលគេចាប់ខ្លួនគាត់ ប៉ុន្តែយើងមិនដឹងធ្វើដូចម្តេចទេ ពីព្រោះយើងនៅឆ្ងាយពេក។ បើសិនជាយើងបាននៅជិតគាត់ យើង<អាចនឹង> -- <សំណួរ៖> តើអាចនឹងផ្ទុះ<អាវុធ>ឡើងទេ? វាផ្ទុះ<អាវុធ>ឡើងនៅក្នុងឆ្នាំ ១៩៧៦ ប៉ុន្តែខ្ញុំភ្លេចខែហើយ។ ប៉ុន្តែនៅចុងឆ្នាំ១៩៧៦ យើងបម្រុងនឹងផ្ទុះឡើង ប៉ុន្តែ<វាបាន>បែកការណ៍។ <>កងពល២ នៅភូមិភាគឧត្តរ គឺត្រៀមរៀបចំហើយ នៅខាងវត្ត<ជើង>ភ្នំ <>ភូមិភាគបូព៌ា<គ្រប់គ្រងផ្នែកខាងត្បូង បានត្រៀមវាយប្រហាររួចរាល់ហើយ> ប៉ុន្តែគេបានបែកការណ៍។ <ហើយ> ឃួន ឬ កុយ ធួន <ដែលជាប្រធានភូមិភាគឧត្តរ>ត្រូវបានគេចាប់ខ្លួន។"

[១៥:០៥:០២]

ហើយបន្ទាប់<>ក្រោយមក នៅក្នុងកំណត់ហេតុ<មជ្ឈមណ្ឌលឯកសារកម្ពុជាដដែល> គឺ អង់គ្លេស 00337714, ខ្មែរ <00055079>, បារាំង 00364275។ គាត់និយាយដូចខាងក្រោមនេះ "នៅខែមីនា ឆ្នាំ១៩៧៦" ខ្ញុំគិតថា<>គាត់និយាយពីឆ្នាំ៧៧ "គេបានចាប់ខ្លួនខ្ញុំ ហើយយកខ្ញុំទៅព្រៃស ហើយគេប្រកាសថា <យើងត្រូវតែទទួលស្គាល់ថា> មិនមែនតែយើងទេ <នៅក្នុងលំដាប់>កម្មាភិបាល<ផ្សេងៗ>ទៀត<នៅក្នុងទីក្រុង ដែល>ជាជនក្បត់ <សូម្បីឪពុកម្តាយពួកយើងនៅសមរភូមិក្រោយនោះក៏ជាជនក្បត់>ដែរ ពីព្រោះថាភូមិភាគឧត្តរ និងភូមិភាគបូព៌ាគឺចូលរួមជាមួយឃួន។ <ពួកគេបានប្រកាសបែបនេះនោះ>ព្រៃស។ <អ៊ីចឹងហើយទើបខ្ញុំដឹង។>" សូមបញ្ចប់សេចក្តីដកស្រង់។ លោក

សាក្សី <នេះជា>កម្មាភិបាលនារីនៅកងពល៣១០ គាត់បាននិយាយពីផែនការវាយប្រហារ<>ទីក្រុងភ្នំពេញដែលថា កុយ ធួន ហើយនិងមេបញ្ជាការកងពល អឿន ក៏មានការពាក់ព័ន្ធនឹងផែនការរដ្ឋប្រហារ។ តើព័ត៌មានទាំងអស់នេះអាចធ្វើឲ្យលោកនឹកឃើញ ឬក៏រំឭកនូវការចងចាំរបស់លោកដែរទេ?

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ ផែនការទាំងអស់នេះ ខ្ញុំអត់បានដឹងទេ ព្រោះអារឿងការឃុបឃិតគ្នាខាងលើៗខ្ញុំមិនអាចដឹងរឿងរ៉ាវនេះបានទេ។

**ស៖** តើលោកដឹងអ្វីខ្លះអំពីអាវុធដែលគេរក្សាទុក ឬក៏អាវុធដែលគេបម្រុងនឹងប្រើសម្រាប់វាយប្រហារ<>នៅភ្នំពេញទេ?

**ឆ៖** បាទ អត់ដឹងទេ។

**ស៖** តើលោកបានដឹងអ្វីខ្លះអំពីការប្រជុំសម្ងាត់អ្វីនៅផ្ទះម្ដុំជិតវត្តភ្នំដែរឬទេ?

**ឆ៖** អត់ដឹង។

[១៥:០៧:៣៣]

**ស៖** នៅពេលដែលលោកនៅស-២១ លោកធ្លាប់ឮអំពីផែនការវាយប្រហារយោធាទៅលើអាកាសយានដ្ឋាននៅពោធិ៍ចិនតុង ហើយនិងវិទ្យុភ្នំពេញ។ តើធ្លាប់ឮផែនការវាយប្រហារពីរកន្លែងនេះដែរឬទេ?

**ឆ៖** បាទ កន្លងមកដូចជាមិនច្បាស់ទេ ព្រោះមានចម្លើយសារភាពខ្លះអាចមាននិយាយពីរឿងការវាយប្រហារនៅអាកាសយានពោធិ៍ចិនតុង និងកន្លែងឃោសនាការដើម្បីផ្ដាច់ការទាក់ទង អាហ្នឹងមានចម្លើយសារភាពរបស់អ្នកទោសខ្លះមាន ប៉ុន្តែអារឿងផែនការរបស់អ្នកធ្វើរដ្ឋប្រហារនេះអត់ដឹងទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ រ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ចម្លើយរបស់សាក្សីហ្នឹង គឺចូលទៅក្នុងខ្លឹមសារនៃចម្លើយសារភាពដែលគាត់ទទួលបាន<ពី>ស-២១ <ហើយយើងបានដឹងថាលក្ខខណ្ឌប្រភេទណា ដែលពួកវាត្រូវបានចងក្រងឡើងនោះ។> ដូច្នេះយើងធ្វើហួសព្រំដែនហើយ ព្រោះថាវាចូលទៅដល់ខ្លឹមសារនៃចម្លើយសារភាពហើយ <ពួកគេមិននិយាយពីអ្វីដែលសាក្សីបានដឹងក្នុងអំឡុងពេលវគ្គ>រៀនសូត្រ ឬក៏ប្រភព

ផ្សេងទេ គឺគាត់ដឹងរឿងនេះ ដោយសារតែគាត់សួរអ្នកទោសហើយទទួលបានចម្លើយសារភាពពីអ្នកទោស។

[១៥:០៣:១០]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំមិនអាចត្រួតត្រាលើចម្លើយរបស់សាក្សីទេ ខ្ញុំគ្រាន់តែសួរសំណួរមួយចំនួន អំពីភស្តុតាងដែល<ចងក្រង> ឌី.ស៊ី.ខេម <និងភស្តុតាងដែលចេញមកពីសវនាការនេះ> ហើយបើសិនជាគាត់ឆ្លើយនៅទីនេះ គឺគាត់ផ្សាភ្ជាប់ទៅនឹងចម្លើយសារភាព អានោះជាអ្វីដែលខ្ញុំមិនអាចត្រួតត្រាគាត់បានទេ។

ខ្ញុំសូមអនុញ្ញាតបន្តលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសួរលោកជាសាមញ្ញបន្តទៀតលោកសាក្សី។ នៅពេលដែលលោកចាប់ផ្ដើមសួរចម្លើយ ឆុន តើលោកបានដឹងថា កុយ ធួន ជាអ្នកណាទេនៅពេលនោះ?

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ រឿងរ៉ាវនេះខ្ញុំមិនចាំទេ។

**ស៖** បាទ តើលោកមិនអាចចាំអ្វី? មិនអាចចាំឈ្មោះ ឬក៏មិនអាចចាំហេតុការណ៍អ្វី?

**ឆ៖** បាទ មិនអាចចាំពីរឿងហេតុការណ៍និងឈ្មោះដែល គាត ឆុន ហ្នឹង ហៅ -- ឆ្លើយដាក់ទេ ព្រោះរឿងរ៉ាវយូរទៅពេក ខ្ញុំមិនអាចនឹកឃើញ។

**ស៖** អ៊ីចឹងខ្ញុំសួរលោករបៀបនេះវិញ។ មុនពេលលោកចាប់ផ្ដើមសួរចម្លើយ ឆុន តើលោកបានដឹងថា កុយ ធួន ហៅថា ធុច ហៅថា ឃួន ដឹងថាគាត់ហ្នឹងជាអ្នកណាទេ?

**ឆ៖** បាទ កាលពីដើមឡើយអត់ដឹងទេ ទើបក្រោយៗមក ដល់ជិតដល់ថ្ងៃ០៧ មករា ហើយបានដឹងថា កុយ ធួន នៅខាងភូមិភាគឧត្តរ ហ្នឹងដឹង តែពីមុនមកអត់ដឹងទេ។

[១៥:១១:៥៥]

**ស៖** តើលោកស្គាល់ថា អឿន ហ្នឹងជាអ្នកណាទេ?

**ឆ៖** អឿនហ្នឹងក៏ទើបដឹងក្រោយដែរ ពេលអាចាប់ហើយ យូរឆ្នាំមក បានគេចេះតែនិយាយសាយសុសទៅ ថា អឿន ហ្នឹងជាប្រធានកងពល៣១០។

**ស៖** អ៊ីចឹងតើលោកចង់ប្រាប់តុលាការថា នៅពេលដែលលោកសួរចម្លើយ ឆុន នោះ លោកមិន

ស្គាល់ថា អឿន ទើបតែត្រូវបានគេចាប់ខ្លួនទេ។ តើអ៊ីចឹងឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ ខ្ញុំអត់ស្គាល់ទេពីមុនមក។

**ស៖** តើចម្លើយសារភាពរបស់ ឆុន គឺជាចម្លើយដែលផុសចេញពី ឆុន ខ្លួនឯង គឺមិនឆ្លើយតាមអ្វីដែលលោកចង់ឲ្យគាត់ឆ្លើយ។ បានន័យថា នាំមុខឲ្យគាត់ឆ្លើយទេឬ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សំណួរនេះមិនសមស្របទេ ហើយជាសំណួរច្រំដែលទៅទៀត។ អម្បាញ់មិញនេះ មេធាវីការពារក្តីបាន<បង្កើតមូលដ្ឋាន>ថា សាក្សី<បាន>វាយ<ឆុន> អ៊ីចឹងឥឡូវនិយាយថាពីចម្លើយសារភាពដោយឯកឯង។ <ខ្ញុំគិតថា មានមូលដ្ឋានខុសគ្នានៅទីនេះ>។ មេធាវីការពារក្តីគួរតែរៀបចំសំណួរនេះឡើងវិញ <ឬមួយក៏ប្តូរប្រធានបទតែម្តង>។ សូមអរគុណលោកប្រធាន។

[១៥:១៤:០៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មេធាវី លោកហាក់ដូចជាវិលចុះ វិលឡើង ទៅលើខ្លឹមសារចម្លើយសារភាពហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

<ដោយសារខ្ញុំមិនអាចបង្ហាញចម្លើយសារភាពឲ្យគាត់បាន ហើយដោយសារ>ថា<គាត់> និយាយអំពី កុយ ធួន ហើយនិង អឿន។ យ៉ាងហោចណាស់ ខ្ញុំគួរតែអាចបង្ហាញភស្តុតាងថាចម្លើយសារភាពនោះ គឺជាអ្វីដែល ឆុន សរសេរដោយខ្លួនឯង ឬក៏ថាអាចនឹង<ឆ្លើយតាមសំណួររបស់>អ្នកសួរចម្លើយ។ <ដោយសារតែនោះជាចំណុចកណ្តាលរបស់យើងនៃការការពារក្តី ហើយមានសារសំខាន់ដើម្បីយល់>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ខ្ញុំគិតថា សំណួរទាំងពីរនោះមិនមានបញ្ហាអីនោះទេ។ ខ្ញុំគ្រាន់តែនិយាយឡើងវិញ។ សំណួរមួយរបស់លោក>គឺថា តើគាត់<>សរសេរដោយខ្លួនឯង<ដោយគ្មានអ្នកប្រាប់ឬ? ដូច្នេះតើលោកអាចឆ្លើយបានទេ? តើលោកចាំទេ ថាតើ ឆុន នៅពេលដែលលោកសួរចម្លើយនោះ> គាត់<សរសេរចម្លើយដោយខ្លួនឯង ដោយមិនមានអ្នកណាប្រាប់ទេឬ? លោកឆ្លើយយ៉ាងម៉េចក៏បានដែរ>។

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ ចម្លើយរបស់ គាត ឆុន នេះ គឺខ្ញុំបាទធ្វើទៅតាមការឆ្លើយរបស់គាត់។ គាត់សរសេររបស់គាត់ អក្សរគាត់ បានខ្ញុំយកមកចម្លងអង្គុលីលេខតាមច្បាប់ដើមរបស់គាត់ទាំងអស់ ខ្ញុំមិនមានបង្ខិតបង្ខំពាក្យណាដែលឲ្យគាត់កែតម្រូវតាមខ្ញុំចង់បានទេ។ អ៊ីចឹង ការសរសេរហ្នឹង គឺការសារភាពរបស់គាត់ហ្នឹងហ្មង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៥:១៥:៥៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ពេលខ្លះទៅខ្ញុំមានអារម្មណ៍ថា តើខ្ញុំកំពុងតែស្ដាប់ដូចលោកមេធាវី កូប៉េ ឬក៏អត់។ អម្បាញ់មិញនេះ សាក្សី គាត់និយាយថា គាត់ត្រូវយកមែកឈើមកវាយអ្នកទោសដែលគាត់សួរចម្លើយ។ ហើយគាត់ថា គាត់ប្រើការគំរាមកំហែង បំភិតបំភ័យទៅទៀត។ អ៊ីចឹង មានន័យថា វាផ្ទុយពីចម្លើយដែលឆ្លើយដោយឯងៗហើយ។ មានន័យថា អ្នកទោសមិនមែនឆ្លើយដោយឯងៗទេ ទាល់តែត្រូវទទួលអំពើហិង្សាបានឆ្លើយ។ អ៊ីចឹង កាលណាដែលសួរអ៊ីចឹង មិនត្រឹមត្រូវទេ លោកមេធាវី កូប៉េ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមដកពាក្យថា គាត់ឆ្លើយដោយឯងៗ ដោយខ្លួនឯងវិញ។ ខ្ញុំយល់ថា ពាក្យនេះ អាចនឹងបកស្រាយខុស។ អ្វីដែលខ្ញុំចង់បង្ហាញភស្តុតាងហ្នឹង តើ ឆុន បាននិយាយអំពីការប៉ុនប៉ងធ្វើរដ្ឋប្រហាររបស់ កុយ ធួន <ឬក៏>គាត់សរសេរដោយខ្លួនគាត់ ឬក៏<នៅ>ពេល<ឆ្លើយនឹងសំណួរ>។ ពីព្រោះថា <បើវាជាការខុសគ្នាពីដំបូងនោះ នោះវាជាភស្តុតាងដ៏មានសារ>សំខាន់ <ដែល>មិនមែនចេញពីចម្លើយ<សារភាព>ទេ។ <ម្យ៉ាងវិញទៀត គាត់មិនអាចដឹងពីអ្វីដែល>៤០ឆ្នាំក្រោយ<នឹងមានការផ្ដល់សក្ខីកម្មក្នុងសវនាការបែបនេះទេ>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី លោកហាក់ដូចជាប្រើខ្លឹមសារនៃចម្លើយសារភាពហើយ។ កាលពីម្សិលមិញ យើង<បាន>រំឭក<លោករួចហើយ ជាពិសេសពីភស្តុតាងនៃភាពត្រឹមត្រូវនោះ>។ នេះហើយជាសេចក្ដីសម្រេចភាគច្រើន ថាយើងហាមឃាត់។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

គឺថាចម្លើយសារភាពហ្នឹង គឺ<ត្រូវបានគេសន្មតថា>ទទួលបានដោយការធ្វើទារុណកម្ម។ អ៊ីចឹងដូចជាមិនមានអីពិបាកយល់ទេ លោកមេធាវី។

[១៥:១៨:០៥]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកសាក្សី តើដែលថា ឈ្មោះ ឆុន សរសេរនៅសំណេរសារភាពនេះ មុនពេលដែលលោកប្រើហិង្សា លោកគំរាមកំហែងតាមការហិង្សា ដូចជាវាយតប់នឹង វាយនឹងមែកត្របែក ឬក៏គាត់សរសេរមុន ហើយបានលោកប្រើហិង្សាក្រោយ?

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ ចម្លើយឯកសាររបស់ គាត ឆុន ហ្នឹង គឺគាត់សរសេរមុនហើយ បានក្រោយមកមានការលាក់លៀមហ្នឹងបានខ្ញុំមានការគំរាមកំហែងតាមក្រោយ ដើម្បីឱ្យសេចក្ដីសារភាពហ្នឹងវាច្បាស់លាស់។

**ស៖** ចុះបើសរសេររួចហើយ ហេតុអីមានស្អីដែលជាមូលហេតុអីដែលត្រូវធ្វើទារុណកម្ម -- អ៎! ដែលទៅប្រើហិង្សាជាមួយគាត់ទៅទៀត ហើយគំរាមកំហែងទៀត? ហើយបើក្រោយពីការគំរាមកំហែង ការប្រើចំណុចដែលប្រើហិង្សាហ្នឹង តើវាមានការកែប្រែផ្លាស់ប្ដូរនូវការផ្ដល់សក្ខីកម្ម -- ផ្ដល់ចម្លើយដោយសរសេរហ្នឹងដែរឬទេ?

[១៥:១៩:២៤]

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់។ អារឿងចម្លើយសារភាពរបស់ គាត ឆុន នេះ មិនមែនជាសាទី១ សាទី២ទេ គឺមិនដឹងជាប៉ុន្មានសាទេ។ ការធ្វើឯកសារហើយ ខ្ញុំបញ្ជូនទាំងសំណុំរឿងដែលមិនទាន់ចម្លងអង្គុលីលេខឱ្យទៅ ឌុច, ទៅ ចាន់ ហ្នឹង គឺគេចារ គេសំណេរមកវិញ ឱ្យសាកសួរពីចំណុចនេះ ចំណុចនោះ ជាហូរហែ បួនប្រាំសាឯណោះ។ ទម្រាំបានសម្រេចថា វាយអង្គុលីលេខបញ្ជូនទៅជាការស្រេច។ អ៊ីចឹងឱ្យសាកសួរហើយ ដេញដោលអ៊ីចឹង មានការសួរដោយត្រជាក់ ដោយអីទៅ ខ្លះក៏ទាល់តែប្រើហិង្សទៅ។ អ៊ីចឹងបានខ្ញុំជម្រាបលោកចៅក្រមថា នេះជាចម្លើយដែលសារភាពហើយ ប៉ុន្តែមិនទាន់ច្បាស់លាស់ បានវ៉ៃធ្វើទារុណកម្មថែម។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធានយើងបានពន្យល់រួចមកហើយនៅក្នុងចម្លើយរបស់យើងទៅនឹងសំណើរបស់មេធាវីការពារក្តីដែលបានដាក់កាលពីថ្ងៃចន្ទ។ ទោះជាយ៉ាងណាក៏ដោយ យើងគិតថា អ្នកទោសទាំងអស់នៅ ស-២១ ទោះបីជាត្រូវបានវាយ ឬក៏អត់<ក៏ដោយ ត្រឹមតែការ>ឃុំខ្លួននៅក្នុងលក្ខខណ្ឌបន្ទាបបន្ថោក <ការដកហូតសិទ្ធិសេរីភាព និងការប្រព្រឹត្តទៅលើ>ដូចជាសត្វធាតុ <ការឮសម្រែកក្នុងអំឡុងពេលមានការសួរចម្លើយអ្នកទោសផ្សេងទៀត គឺពួកគេរងនូវ>ការគំរាមកំហែង មានការប្រើការបោកបញ្ឆោត <ការបំភិតបំភ័យ>ដើម្បី<បំបាក់ផ្លូវចិត្ត>ឱ្យអ្នកទោសឆ្លើយ។ ទោះបីជា<មុនពេល>ប្រើ<ហិង្សាលើរូបរាងកាយ>ក៏ដោយ <ទាំងអស់>នេះគឺវាចូលទៅក្នុង<និយមន័យ>ស្តីពី<ការធ្វើ>ទារុណកម្មហើយ <យោងទៅតាមអនុសញ្ញា>ដែលហាមឃាត់ការប្រើប្រាស់ចម្លើយសារភាព<ក្នុងទម្រង់នីតិវិធីបែបនេះ។ នេះជាជំហររបស់យើង>។ ដូច្នេះ យើងគិតថាទោះបីជា<នរណាម្នាក់ មិនត្រូវបានគេ>វាយមុនពេលឆ្លើយក៏ដោយ បរិបទនៅក្នុងស-២១ បានបញ្ជាក់ថា<អ្នកទាំងនោះជាកម្មវត្ថុនៃការបង្ខិតបង្ខំ និង>ការធ្វើទារុណកម្ម<>។ ដូច្នេះ សូមឱ្យដកសំណួរទាំងអស់នេះចេញវិញ។

[១៥:២១:៥១]

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំសូមអនុញ្ញាតឆ្លើយតប យើងនឹង<មិន>តបទល់នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់<ថា វិធីសាស្ត្រក្តៅ ឬការធ្វើទារុណកម្មគឺស្របច្បាប់>នោះទេ។ គឺថាយើង<នឹង>មិន<តវ៉ាលើរឿងនេះឡើយ។ ហើយយើងក៏នឹងមិន>ទាមទារថា <>ចម្លើយសារភាពបានពីទារុណកម្ម <ឬការធ្វើបាប>នោះទេ។ ប៉ុន្តែយើងនិយាយពីការចាប់ខ្លួន ឆុន ហើយនិងការឃុំខ្លួន ឆុន នោះ គឺវាជាស្ថានភាព<ស្របច្បាប់> ពីព្រោះថា គាត់គឺជាជនសង្ស័យ<នៃការប្រព្រឹត្ត>បទល្មើស <ដែលបច្ចុប្បន្នគឺជាបទឧក្រិដ្ឋនៅតាមបណ្តា>ប្រទេស<នានា>។ អ៊ីចឹង <យើងគួរតែអាចលើករឿងនេះឡើង ហើយនៅក្នុងការសម្រេចសេចក្តីលើរឿងក្តី ឌុច មានសេចក្តីសម្រេចជាច្រើននៅក្នុងរឿងនេះ> គឺថា<>ការចាប់ខ្លួន ហើយនិងការឃុំខ្លួន<មួយចំនួននោះក៏មិនត្រឹមត្រូវតាមច្បាប់ផងដែរ>។

<យើងនឹងតវ៉ាថា ការចាប់ខ្លួន និងការឃុំខ្លួននោះ មិនមែនជាបញ្ហានោះទេ។ ហេតុដូច្នេះហើយខ្ញុំគិតថា វាសមរម្យ ដែលយើងព្យាយាមរកចម្លើយពីសាក្សីនេះ នូវអ្វីដែលគាត់បានដឹងអំពីខ្លឹមសារនៃការចោទប្រកាន់ អំពីអ្វីដែលគាត់បានសួរ និងអំពីអ្វីដែលគាត់បានស្វែងរកនៅពេលនោះ ដើម្បីលើកឡើងថា

ក្នុងឧទាហរណ៍>ពិសេសនេះ គឺថា ផុន ហ្នឹងគឺត្រូវបានគេចាប់ខ្លួនដោយត្រឹមត្រូវ ហើយ<ជាបន្តបន្ទាប់មកទៀត ត្រូវបាន>ឃុំខ្លួន<ដោយ>ស្របច្បាប់។ <សំណួរសួរថា តើគាត់ត្រូវបានគេវាយដោយស្របច្បាប់ទេ?> ទេ <រឿងនេះយើងនឹងមិនតវ៉ាឡើយ។> ប៉ុន្តែ<នោះជាបញ្ហាមួយ ដែល>យើងចង់<លើកឡើងជាមួយ>សាក្សីនេះ<>។

[១៥:២៣:៣៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៤:៥៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមឲ្យបំភ្លឺមួយចំនួនគឺថា មានបញ្ហាលើកឡើងច្រើន យើងមិន<>យល់ច្បាស់ពីបញ្ហានេះ។ តើ<យើងកំពុងតែនៅចំណុចណា? តាមទស្សនៈរបស់លោក នៅ>ពេលនេះ <តើ>អង្គជំនុំជម្រះ <ត្រូវតែសម្រេចដោយបើកចំហទទួលយករាល់>សំណួរ<ទាំងអស់ឬ? ហេតុអ្វី? ព្រោះថាដោយពិតប្រាកដទៅពេលនេះខ្ញុំវង្វេងអស់ហើយ។ យើងបានជជែកគ្នាអំពីអ្វីដែលលោកព្យាយាមរកភស្តុតាង និងមិនរក>ភស្តុតាង<>។ <សូមបំភ្លេចរឿងនេះចុះនៅពេលនេះ។ តើ>អង្គជំនុំជម្រះ<ត្រូវធ្វើសេចក្តីសម្រេចដោយបើកចំហមួយទេ?> បើសិនជា<ណាជាត្រូវធ្វើ តើសម្រេចលើរឿងអ្វី>?

**លោក វ៉ិចទ័រ កូប៉េ៖**

<អ្វីដែល>ខ្ញុំចង់ព្យាយាម<ស្វែងរកពី>សាក្សីនេះ <គឺថា>តើការបញ្ជាក់<របស់> កុយ ធួន នៅក្នុងចម្លើយសារភាពនោះ <ត្រូវបានលើក>ឡើង<ដោយ> ផុន ខ្លួនឯង ឬក៏ជាចម្លើយ<>ដែលផ្អែកតាមសំណួររបស់អ្នកសួរចម្លើយ<>។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ប៉ុន្តែ<នៅពេលដែលលោកនិយាយថា ទោះបី>វាជាលទ្ធផលនៃ<ការសម្រេចចិត្ត>របស់ ផុន <ក៏ដោយ ហើយតើលោកនិយាយថា វាជាការសម្រេចចិត្តមួយ ដែលបានធ្វើឡើងដោយសេរី ដោយមិនមានការ>ប្រើទារុណកម្ម <ហើយមិនមែនជាលទ្ធផលនៃការឆ្លើយសារភាពដែលបានមកពីការធ្វើទារុណកម្មទេ> លោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

**លោក វ៉ិចទ័រ កូប៉េ៖**

<សំណួរទាំងអស់នេះគឺជាការសួរនាំមុខឲ្យឆ្លើយតាម ដោយហេតុថា គាត់និយាយថា នៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពេល>ដែល<គាត់ចាប់ផ្ដើមសួរ>ចម្លើយ <ផុន នោះ> គាត់មិនដឹង<អំពី>ផែនការរដ្ឋប្រហារ <អំពី កុយ ធួន និងអំពី អឿន >ទេ។ <ហើយបើសិនណាវាជាការពិត ហើយ> ផុន <>បានផ្ដល់<ព័ត៌មាននេះដោយខ្លួនឯង ដោយមិនមានសាក្សីនេះសួរនាំមុខឲ្យឆ្លើយតាមទេ អ៊ីចឹងសម្រាប់យើង វាជាព័ត៌មានគួរឲ្យចាប់អារម្មណ៍បំផុត -- ជាភស្តុតាងគួរឲ្យចាប់អារម្មណ៍>។

[១៥:២៦:៤០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៨:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីចេញដីកាសម្រេចផ្ទាល់មាត់លើបញ្ហាជំទាស់ក្នុងការតាំងសំណួរចុងក្រោយរបស់មេធាវីការពារក្ដីនេះ ដើម្បីឲ្យមានភាពច្បាស់លាស់ ហើយនិងនីតិវិធីប្រព្រឹត្តទៅមុខ។ សូមអញ្ជើញលោកចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដោយហេតុថា សំណួរហ្នឹងគឺទាក់ទងទៅនឹងចម្លើយសារភាព វាស្ថិតនៅក្រោម -- គឺជាចំណុចដែលត្រូវបានហាមឃាត់ដោយយោងទៅរកសេចក្ដីសម្រេចភាគច្រើនអំពីការប្រើប្រាស់នូវចម្លើយសារភាព។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ខ្ញុំនឹងបន្តទៅប្រធានបទផ្សេង។ លោកសាក្សី កុយ ធួន ហៅ ធុច ហៅ ឃួន ហ្នឹង <ហាក់ដូចជា>មិនធ្វើឲ្យលោកនឹកឃើញអ្វីទេ<>។ តើលោកធ្លាប់ឮមនុស្សម្នាក់ឈ្មោះថា សោ ភឹម ដែរឬទេ?

[១៥:៣០:០០]

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ សោ ភឹម ធ្លាប់ឮឈ្មោះ ហើយនិងឃើញទាំងរូបថតទៀត ដែលពេលដែលគាត់បាញ់ខ្លួនគាត់ស្លាប់នៅភូមិភាគបូព៌ា។

**ស៖** តើ<>លោកដឹង<អ្វីខ្លះ>អំពី សោ ភឹម <>នៅពេលដែលលោកចាប់ផ្ដើមការសួរចម្លើយ<ជាលើកដំបូង>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ តាមការសួរចម្លើយអ្នកផ្សេងៗដឹងថា សោ ភឹម ជាប្រធានភូមិភាគបូព៌ា ហើយក្រោយមកក៏គឺថាអង្គការរកចាប់រកអីហ្នឹងក៏រត់ៗទៅរត់មិនរួចទាល់ច្រកហ្នឹង ក៏គាត់សម្រេចចិត្តបាញ់ខ្លួនឯងសម្លាប់ចោល។ ដោយ ឌុច ហ្នឹងបានយករូបថតរបស់ សោ ភឹម ដែលបានបាញ់ស្លាប់ហ្នឹងថតយកមកឲ្យមើលនៅក្នុងមន្ទីរស-២១ហ្នឹង។

**ស៖** ខ្ញុំយល់ថា សោ ភឹម គាត់បាញ់សម្លាប់ខ្លួនឯងដែលថាគេចោទថាគាត់ក្បត់ជាតិ។ អ៊ីចឹងខ្ញុំសួរលោកថាតើលោកដឹងអ្វីខ្លះអំពី សោ ភឹម នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧?

**ឆ៖** បាទ រឿងរ៉ាវផ្សេងទៀត ខ្ញុំអត់ដឹងទេ។

**ស៖** តើអំពើអ្វី<ខ្លះ>ដែល សោ ភឹម <បានធ្វើ? តើ>គាត់ធ្វើ<អ្វីដែល>គេចោទគាត់ថាគាត់ក្បត់ជាតិ? <តើអ្វីជាអំពើក្បត់ជាតិរបស់គាត់ ដែល>លោក<ដឹង នៅពេល>ដែលលោក<ធ្វើជាអ្នកសួរចម្លើយនៅ ស-២១ នោះ>?

**ឆ៖** បាទ អត់ៗដឹងរឿង ដឹងខ្ញុំនិយាយថាម៉េច។

[១៥:៣២:២៥]

**ស៖** អ៊ីចឹងខ្ញុំនឹងព្យាយាមជួយឲ្យលោកចងចាំ។ ខ្ញុំត្រឡប់មក<និយាយពី>សៀវភៅកំណត់ហេតុរបស់ ចាន់ គឺថាឯកសារ E3/833, អង់គ្លេស 00184614, ខ្មែរ 00077946 ខ្ញុំសូមអនុញ្ញាតបង្ហាញទំព័រមួយអំពីសៀវភៅកំណត់ហេតុរបស់ ចាន់ នេះជូនសាក្សីពិនិត្យលោកប្រធាន បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** នៅក្នុងសៀវភៅកំណត់ត្រានេះសរសេរថា "ហេតុអ្វីបានជាយើងត្រូវរកភស្តុតាងឲ្យបានរឹងមាំនោះ?" <ហើយវាសរសេរបន្តថា> "កិច្ចប្រជុំជាមួយ អាភឹម ដែលជាប់ពាក់ព័ន្ធនឹងយួន" បញ្ចប់ការដកស្រង់។ លោកសាក្សី ចំណុចនេះ វាជួយរំឭកដល់ការចងចាំរបស់លោកទេដែលថា<ភស្តុតាងដែលលោក និង ចាន់ ក៏ដូចជាអ្នក>សួរចម្លើយ<ផ្សេងៗទៀតស្វែងរកនោះ គឺការជួបប្រជុំជាមួយ> សោ ភឹម <ដែលជាប់ពាក់ព័ន្ធជាមួយវៀតណាមនោះ>?

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយបានទេ? អានោះគ្រាន់តែជាមូលដ្ឋានទេ អាដែលកំណត់ត្រានោះ សំខាន់លោកស្តាប់

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សំណួរ ហើយលោកអាចឆ្លើយបានទេ លោកដឹងទេព័ត៌មាននេះ មានព័ត៌មានអីដែលលោកទទួលបានព័ត៌មាននេះទេ? ហើយចូរចាំច្បាស់ថាព័ត៌មានដែលលោកផ្តល់សក្ខីកម្មនេះ មិនយកការដឹងរបស់លោកក្រោយថ្ងៃ០៧ មករា ៧៩ ទេ គឺយកដឹងសម័យដែលលោកធ្វើការនៅមន្ទីរសន្តិសុខស-២១។ លោកឆ្លើយសំណួរនេះបានទេ?

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ សំណួរនេះ ខ្ញុំអត់បានដឹងរឿងរបស់ សោ ភឹម ច្រើនទេ ព្រោះដឹងថា ដូចខ្ញុំរៀបរាប់ថា ពេលបាញ់ស្លាប់ហើយ ឃើញតែរូបថតទេ ប៉ុន្តែរឿងអីផ្សេងទៀត ខ្ញុំអត់ដឹង។

[១៥:៣៥:៤១]

**ប្រធានអង្គជំនុំ៖**

អរគុណសាក្សី យើងប្រាប់រំឭកលោកថា ក្នុងករណីលោកមិនដឹង គឺចម្លើយរបស់លោកចាំបាច់ត្រូវតែឆ្លើយតបទៅនឹងសំណួរ គឺថាលោកមិនដឹងទេ ការណ៍ដែលលោកឆ្លើយថាមិនដឹង គឺជាចម្លើយរបស់លោកហើយ គឺជាការចម្លើយតបរបស់លោកតាមកាតព្វកិច្ចដែលអង្គជំនុំជម្រះកំណត់ និងជម្រាបអំពីករណីយកិច្ចរបស់លោក ក្នុងនាមកាតព្វកិច្ចក្នុងការឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះ និងភាគីហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមចូលទៅសៀវភៅកត់ត្រាមួយទៀត លោកសាក្សី។ ខ្ញុំនឹងអានឲ្យលោកស្តាប់ <> សៀវភៅកត់ត្រារបស់ <ប៉ុន> និង ទុយ ដែលនិយាយអំពី សោ ភឹម។ ERN ជាភាសាខ្មែរនៃឯកសារនេះ គឺ 00077476, ERN ជាភាសាអង់គ្លេស 00184483, ERN មួយទៀតហ្នឹង គឺថា ខ្ញុំនឹងផ្តល់ជូននៅពេលក្រោយ។ នៅក្នុងសៀវភៅកត់ត្រានេះ ប៉ុន និយាយអំពីការកម្ទេចខ្សែរយៈ សោ ភឹម ក៏ដូចគ្នាទៅនឹងជ័យជម្នះ ១៧ មេសា ១៩៧៥ ឬអាចនិយាយម្យ៉ាងទៀតបានថា “មហាជ័យជម្នះរបស់ អាភឹម និងបក្សពួករបស់វា <និងទិស>ដៅ<ការងារអនាគត>ទៅលើ<>សាខាពិសេស”។ <>ហើយក្រោយមកបន្តនិយាយទៅទៀតថា ថ្ងៃ ១៧ មេសា <និង>ជ័យជម្នះ<ទៅលើ> សោ ភឹម ត្រូវបានគេឃើញដូចគ្នានេះឯង។ តើចំណុចនេះរំឭកដល់ការចងចាំរបស់លោកដែរទេ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ប្រហែលជាត្រូវសួរទៅសាក្សីថា តើ<សាខា>ពិសេសហ្នឹង<ជាអ្វី>? <តើទាំងអស់ហ្នឹង

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ជាអ្នកសួរចម្លើយឬ? តើយើង>កំពុងតែយោងទៅលើខ្លឹមសារនៃសារភាព<>ដែល<ទទួលបាន>ដោយអ្នកសួរចម្លើយ<>ឬយ៉ាងម៉េច?

**លោក វ៉ិចទ័រ កូប៉េ៖**

ឥឡូវខ្ញុំសូមដកផ្នែកថា ផ្នែកពិសេស ឬសាខាពិសេសនេះចុះ។

[១៥:៣៨:០៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំនិយាយអំពីកិច្ចប្រជុំមួយដែលអ្នកសរសេរសៀវភៅកត់ត្រានេះ និយាយយោងទៅលើមហាជ័យជម្នះទៅលើ សោ ភឹម គឺថាមហាជ័យជម្នះទៅលើ សោ ភឹម ហ្នឹង ចាត់ទុកថាដូចគ្នាទៅនឹងមហាជ័យជម្នះថ្ងៃ១៧ មេសា<>ដែរ។ <តើ>លោកចាំទេ? <តើបរាជ័យរបស់> សោ ភឹម <>នេះ <ត្រូវបានគេមើលឃើញអ៊ីចឹង>ទេ?

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ ចំណុចនេះ ឮសួរ ឌុច គេនិយាយថា សោ ភឹម ងាប់ទៅ បរាជ័យទៅដោយសារស្នាដៃរបស់បក្សដឹងខ្លួនទាន់ អាហ្នឹងឮសួរនិយាយមែន។

**ស៖** ចុះលោកធ្លាប់ឮពាក្យថា "បក្សពលករកម្ពុជា" ដែរទេ?

**ឆ៖** បាទ ពាក្យ "បក្សពលករកម្ពុជា" ហ្នឹង ឮសួរថា កាលពីសម័យមុន សម័យបក្សកកើតអាហ្នឹងគេមានធ្លាប់បង្រៀន រៀនសូត្រឲ្យដឹង តែសម័យក្រោយមកជាបក្សកុម្មុយនីស្តកម្ពុជា។

**ស៖** យោងតាមបក្សកុម្មុយនីស្តកម្ពុជា មានផ្នែកមួយ ហៅថា "បក្សពលករកម្ពុជា" ដឹកនាំដោយ សោ ភឹម, រស់ ញឹម, យ៉ា, កុយ ធួន និងអ្នកដទៃទៀត។ <តើ>លោកធ្លាប់ឮទេ?

**ឆ៖** បាទ ពាក្យក្រោយនេះ អត់ដែលឮទេ។

**ស៖** លោកបាននិយាយអំពីវៀតណាមពីខាងដើមនោះ គឺថាវៀតណាម គឺជាខ្មាំង។ <តើ>លោកយល់<អ្វីខ្លះ> នៅពេលដែលលោកធ្វើការនៅស-២១ <អំពី>គោលបំណងរបស់វៀតណាម? <តាម>ការយល់ឃើញរបស់ ឌុច និង សុន សេន ក៏ដូចជាអ្នកដទៃទៀត តើវៀតណាមមានគោលបំណងអ្វីដែរ?

**ឆ៖** ខ្ញុំស្តាប់តាមការលើកឡើងរបស់ ឌុច ថាវៀតណាម ហើយនិងបក្សកុម្មុយនីស្តកម្ពុជាហ្នឹង គឺចង់ផ្តួលរំលំគ្នា ដោយលើកឡើងពីជ័យជម្នះថ្ងៃ១៧ មេសា គឺឌុច បានលើកថា បក្សកុម្មុយនីស្តកម្ពុជា

ឈ្លាសវៃ វៃបានជ័យជម្នះថ្ងៃ១៧ មេសា។ រីឯ វៀតណាម វៃបានជម្នះពួកធីវគី នៅថ្ងៃ៣០ ខែមេសា។ អ៊ីចឹង បានជ័យជម្នះក្រោយបក្សកុម្មុយនីស្តកម្ពុជា។ ដល់អ៊ីចឹង បក្សទាំងពីរហ្នឹង ត្រូវមានការប្រឆាំងគ្នាដោយមានអំនួតម្ខាងៗ។

**ស៖** តើលោកធ្លាប់<ឮពាក្យថា>សហព័ន្ធឥណ្ឌូចិនដែរទេ?

**ឆ៖** បាទ ពាក្យហ្នឹង ឮ ប៉ុន្តែនិយមន័យយ៉ាងម៉េច ខ្ញុំអត់យល់ដែរ។

[១៥:៤៣:០៣]

**ស៖** លោកសាក្សី ខ្ញុំចូលប្រធានបទថ្មីមួយទៀត។ នៅពេល<មួយ>នោះ<ក្នុងអំឡុងពេលលោកផ្តល់សក្ខីកម្ម ខ្ញុំគិតថា កាលពីម្សិលមិញ> លោកបាននិយាយថា <>លោកជឿជាក់ថា ប្រហែលជា៥០ ទៅ ៦០ភាគរយនៃអ្នកដែលត្រូវបានឃុំឃាំងនៅស-២១ ត្រូវបានគេសួរចម្លើយ។ តើលោកធ្វើម៉េចបានលោកបានសន្និដ្ឋានពីតួលេខហ្នឹង ថាយ៉ាងហោចណាស់ក៏ពី៥០ ទៅ៦០ ភាគរយដែរ ត្រូវបានគេយកមកសួរចម្លើយនោះ?

**ឆ៖** បាទ ការប៉ាន់ស្មានរបស់យើងខ្ញុំ ដោយសារមើលឃើញអ្នកទោសវាច្រើន ហើយអ្នកសួរហ្នឹង វាតិច។ ហើយម្យ៉ាង អ្នកទោសដែលខ្ញុំដើរទៅដើរមក ពេលយកអ្នកទោសទុកដាក់អីហ្នឹង គឺអ្នកណានៅក្នុងគុកហ្នឹង គឺនៅក្នុងគុកដដែលហ្នឹង ទាល់តែថ្ងៃមុន០៧មករាហ្នឹង យកទៅចេញក្រៅអស់ហ្នឹង អត់មានឃើញយកមកសួរ យកអី។ អ៊ីចឹង បានខ្ញុំអាចសន្និដ្ឋានបានថា អ្នកទោសណាថាដែលសំខាន់ ឬក៏បក្សចង់ដឹងពីចម្លើយ ចង់ដឹងពីខ្សែរយៈហ្នឹង អាហ្នឹងឱ្យយកមកសួរមក អ្នកណាដែលថា មិនសំខាន់មានឋានៈតូចទាបអីហ្នឹង ក៏គេមិនទៅសួរនាំទេ ទុកដល់ចាំថ្ងៃវៃចោលតែម្តង។

**ស៖** ប៉ុន្តែធ្វើម៉េចបានជាលោកដឹងថា អ្នកដែលគេឃុំខ្លួននៅក្នុងបន្ទប់តូចៗហ្នឹង មិនត្រូវបានគេយកទៅសួរចម្លើយ ដូចជាថាបើលោកឃើញ លោកប្រាកដថា នៅថ្ងៃបន្ទាប់ គេមិនទៅយកទៅសួរចម្លើយ។ ធ្វើម៉េចបានជាលោកដឹងថាគេមិនយកអ្នកខ្លះទៅសួរចម្លើយនោះ?

**ឆ៖** អាហ្នឹងខ្ញុំឆ្លើយតាមខ្ញុំឃើញ ខ្ញុំឆ្លងកាត់ឡើងចុះរាល់ថ្ងៃ យើងយកអ្នកទោសហ្នឹងយកមកសួរ។

**ស៖** ឥឡូវខ្ញុំសួររបៀបផ្សេងទៅវិញ។ តើលោកអាចផ្តល់ឧទាហរណ៍មួយបានទេ លើកយកតែអ្នកទោសណាម្នាក់ក៏បានដែរ ដែលត្រូវបានគេឃុំខ្លួន ហើយមិនត្រូវបានគេសួរចម្លើយនោះ?

**ឆ៖** បាទ ខ្ញុំលើកជាឧទាហរណ៍ អ្នកទោសនារី ស្រីៗ នៅតាមអគារ “អា”, “បេ”, “ដេ”,

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01249496



"សេ" នៅបន្ទប់លើហ្នឹងអត់មានវ៉ើបន្ទប់តូចៗទេ អ៊ីចឹងនៅពេញៗទាំងអស់ ប៉ុន្តែមិនដែលឃើញយកចុះមកសួរចម្លើយទេក្នុងមួយបន្ទប់ ម្តែសាមសិបនាក់អ៊ីចឹងយកម្នាក់អី ឬក៏អត់ក៏មានដែរ។

**ស៖** សំណួរខ្ញុំសួរថា តើលោកដឹងដោយរបៀបណា?

**ឆ៖** បាទ ដឹងដោយខ្ញុំឃើញ។

[១៥:៤៦:២៤]

**ស៖** ខ្លួនលោកផ្ទាល់នេះ គឺថារវល់សួរចម្លើយអ្នកទោសដទៃទៀត គឺថារវល់សួរចម្លើយស្ទើរតែរាល់ថ្ងៃ អ៊ីចឹងធ្វើម៉េចបានជាលោកដឹងថា អ្នកទោសស្ត្រីរូបនេះមិនត្រូវបានគេសួរចម្លើយនោះ?

**ឆ៖** បាទ ព្រោះខ្ញុំដឹងថា ខ្ញុំឃើញបានខ្ញុំហ៊ាននិយាយ ព្រោះខ្ញុំដើរយកអ្នកទោសឆ្លងកាត់ទៅមករាល់ថ្ងៃ ចេញចូលរាល់ថ្ងៃ ព្រឹកល្ងាចយប់ អ៊ីចឹងបានខ្ញុំហ៊ានថា បើខ្ញុំមិនឃើញ ខ្ញុំមិនថា ខ្ញុំមិនឃើញ ខ្ញុំមិនឆ្លើយ។

**ស៖** ខ្ញុំសូមព្យាយាមសួរតាមរបៀបផ្សេងម្តងទៀត ហេតុអ្វីបានជាអ្នកទោសស្រីរូបនេះមិនត្រូវបានគេយកទៅសួរចម្លើយ? តើមានមូលហេតុអីដែរ?

**ឆ៖** ខ្ញុំមិនអាចពណ៌នាបាន ព្រោះខ្ញុំអត់ដឹង។ ប៉ុន្តែគ្រាន់ឃើញថាជាប់នៅហ្នឹង មិនដឹងជាគេទុករង់ចាំពេលណា ឬមួយក៏យ៉ាងម៉េច ខ្ញុំអត់ដឹង អត់យល់។

**ប្រធានអង្គជំនុំ៖**

លោកសាក្សី បើលោកមិនដឹងឆ្លើយថាត្រឹមមិនដឹងបានហើយ កាលណាលោករៀងធ្វើប្រហាក់ប្រហែលទៀត អាហ្នឹងគឺវាមិនមែនជាការដែលផ្តល់សក្ខីកម្មត្រឹមត្រូវតាមការណែនាំរបស់អង្គជំនុំជម្រះទេ។ មួយទៀត គឺលោកមិនគប្បីប្រើពាក្យសន្និដ្ឋានទេ ព្រោះលោកជាសាក្សី។ ហើយយើងបានប្រាប់ហើយ គឺជាការកត់សម្គាល់ ឬក៏បទពិសោធន៍ ឬក៏ការសង្កេតរបស់លោកដែលលោកបានឆ្លងកាត់ នោះជាៗកិច្ចការដែលអង្គជំនុំជម្រះបានប្រាប់អំពីករណីយកិច្ចដែលសាក្សី គឺប្រើប្រាស់បានក្នុងករណីនេះក្រៅពីឃើញ ក្រៅពីដឹងឮដោយផ្ទាល់ គឺមានការសង្កេតដោយផ្ទាល់ ព្រោះដោយសារអង្គហេតុចោទប្រកាន់មានរយៈពេលវែង ៣ឆ្នាំ ៨ខែជាងឯណោះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំព្យាយាមសួរតាមរបៀបផ្សេងជាចុងក្រោយទៅលើចំណុចដដែល។ សូមចាប់ផ្តើមនិយាយអំពីសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង០០១ ពាក់ព័ន្ធទៅនឹងអ្នកទោស

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែលចំនួន<ប្រហែល>១២.០០០នាក់ បើតាមលោកស្មាន <ហើយភាគរយរបស់លោកគឺត្រឹមត្រូវ អ្នកទោស>៦.០០០នាក់<មិន>ត្រូវបានយកមកសួរចម្លើយ។ លោកបានប្រភពតួលេខនេះមកពីណា ដែលថាអ្នកទោសតែប្រហែលជាជាង៦.០០០នាក់ទេ ដែលត្រូវបានគេយកមកសួរចម្លើយ?

**លោក ប្រាក់ ខន៖**

**ឆ៖** ខ្ញុំអត់មានអាងអ្វីទេ អានេះជាការសន្និដ្ឋានរបស់ខ្ញុំដែលឃើញអ្នកទោស ហើយគិតជាភាគរយតែប៉ុណ្ណឹងទេ ដោយសារអស់លោកចេះតែដេញដោលសួរខ្ញុំ។ បាទ ខ្ញុំរ៉ៃប្រហែល៥០, ៦០ភាគរយប៉ុណ្ណឹង ហើយប្រភពជាក់លាក់អត់មានទេ។

[១៥:៥០:០៦]

**ស៖** ព្រឹកមិញលោកត្រូវបានសួរសំណួរអំពីអ្នកទោសជាជនជាតិចាម។ តើអ្នកសួរចម្លើយ នៅស-២១ មានអ្នកណាមានជាតិកំណើតហ្នឹងជាចាមទេ?

**ឆ៖** បាទ មាន១ឈ្មោះ ម៉ាន។

**ស៖** តើលោកចាំអ្វីខ្លះពីឈ្មោះ ម៉ាន នេះ?

**ឆ៖** បាទ ឈ្មោះ ម៉ាន ហ្នឹងប៉ុន ម៉ាន ជនជាតិចាម ប៉ុនចេះភាសាខ្មែរដូចតែខ្មែរដែរទេ។ ប៉ុន្តែម៉ាន ហ្នឹង ក្រោយមកក៏គេយកទៅសម្លាប់ចោលបាត់ហើយ។

**ស៖** តើវាចោទជាបញ្ហាអីដែរទេ នៅស-២១ នោះ ដោយសារតែ ម៉ាន ជាជនជាតិចាម តើវាចោទជាបញ្ហាអីទៅលើគាត់ទេ?

**ឆ៖** អានេះ តាមខ្ញុំដឹងអត់មានចោទពីរឿងបញ្ហាជនជាតិចាម ជនជាតិខ្មែរអីទេ អាហ្នឹងវាមានរឿងរ៉ាវផ្ទៃក្នុងបានជាគេចាប់។

**ស៖** ដើម្បីឲ្យច្បាស់លាស់ ១០០ភាគរយតែម្តង លោកប្រធាន ខ្ញុំមានរូបថតរបស់ ម៉ាន ហើយខ្ញុំសុំការអនុញ្ញាតបង្ហាញរូបថតនេះ ទៅឲ្យសាក្សីមើល និងសួរទៅសាក្សីមើល ថាតើរូបថតនេះគឺជាម៉ាន ដែលគាត់កំពុងនិយាយនេះ ឬក៏យ៉ាងណា? គឺរូបថតនេះ បានមកពីសៀវភៅ អ៊ីសា ឧស្មាន គឺ E3/1822, ERNអង់គ្លេស 00078508 សូមបង្ហាញតែត្រឹមរូបថតតែប៉ុណ្ណោះ ខ្ញុំនឹងផ្តល់ ERNជាភាសាខ្មែរ បន្តិចទៀតនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១៥:៥២:៥៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើរូបថតនេះ ជារូបថត ម៉ាន កំពុងនិយាយគ្នាហ្នឹងមែនទេ?

**លោក ប្រាក់ ខន៖**

**ឆ៖** មិនមែន ម៉ាន ដែលសួរចម្លើយនៅជាមួយខ្ញុំ។

**ស៖** ចុះបើមិនមែនជា ម៉ាន ហ្នឹងតើរូបថតនេះ គឺជាអ្នកណា?

**ឆ៖** អត់ស្គាល់ ព្រោះ ម៉ាន នោះចាស់ ហើយមុខជ្រុង មិនមែនមុខនេះទេ។

**ប្រធានអង្គជំនុំ៖**

ប៉ុណ្ណឹងសិនចុះលោក វ៉ិចទ័រ កូប៉េ ប៉ុណ្ណឹងសិនចុះ! យើងផ្តល់វេទិកាទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ តាំងសំណួរចុងក្រោយប្រើប្រាស់ពេលវេលាចុងក្រោយថ្ងៃនេះ។

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ក្រែងថាមានសំណួរចង់សួរទៅកាន់សាក្សី សូមអញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ លោកមេធាវី កូប៉េ លោកមានសេចក្តីសន្និដ្ឋានដើម្បីបញ្ចប់ប្រធានបទរបស់លោក ឬក៏យ៉ាងម៉េច? ខ្ញុំមានពីរបីសំណួរសួរទៅលោកសាក្សីនេះ ហើយខ្ញុំមិនចង់កាត់ផ្តាច់លោកក្នុងពេលដែលលោកកំពុងសួរទេ។ បើសិនជាលោកចង់បញ្ចប់លោកអាចធ្វើបាន។

[១៥:៥៤:៤៣]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំកំពុងចូលដល់ចំណុចមួយដែលខ្ញុំ<ត្រូវនិយាយថា ខ្ញុំ>មិនទាន់បញ្ចប់សំណួររបស់ខ្ញុំនៅឡើយ។ ខ្ញុំកំពុងតែរៀបនឹងសួរអំពីការបួមឈាម ស្ថានភាពក្មេងៗ ការចាប់ខ្លួនប្រពន្ធកូន <និងសាកសពដែលគាត់និយាយថា គាត់បានឃើញនៅពេលគាត់ធ្វើ>ជាអ្នកយាម។ ហើយ<យើងក៏ត្រូវ>សួរពីរឿងចម្លើយសារភាពរបស់ កុយ ធួន <ផងដែរ>។ ដូច្នេះយើងខ្ញុំសូមអនុញ្ញាតឲ្យអង្គជំនុំជម្រះផ្តល់ពេលវេលាឲ្យខ្ញុំមួយវគ្គទៀត <ដើម្បីបញ្ចប់សំណួររបស់ខ្ញុំ។> ហើយខ្ញុំក៏ដឹងថាក្រុមមេធាវីការពារក្តី ខៀវ សំផន ក៏ត្រូវការសួរដែរ តែមិនដឹងត្រូវសួររយៈពេលប៉ុន្មាននោះទេ។ <ខ្ញុំបានបញ្ចប់លើប្រធានបទជនជាតិចាមរួចហើយ> បើអង្គជំនុំជម្រះអនុញ្ញាតឲ្យខ្ញុំបន្តទៅសួរប្រធានបទមួយទៀតនៅព្រឹកថ្ងៃចន្ទ គឺថាខ្ញុំមិនជាថ្វីទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំគិតថាយើងទាំងអស់គ្នាដូចជា<មិនសប្បាយចិត្តចំពោះ>ការគណនា<មិនត្រឹមត្រូវ>ដោយសហព្រះរាជអាជ្ញា<ពីខាងដើមនោះ។> បើតាមពិតទៅគឺថាលោកមេធាវី កូប៉េ អាចបន្តនៅ<ព្រឹក>ថ្ងៃចន្ទបាន ព្រោះថាយើងមានរយៈពេលមួយថ្ងៃឯណោះ <ដូច្នេះហើយ យើងមិនទាន់បានប្រើពេលវេលារបស់យើងពេញទាំងបួនវគ្គនោះទេ>។ ចំពោះខ្ញុំនេះ ខ្ញុំត្រូវការរយៈពេលមួយវគ្គសម្រាប់សួរសំណួរទៅសាក្សីនេះ ហើយក៏ប៉ុន្តែ វាអាស្រ័យនឹងការជឿនលឿនទៅមុខនៃការចោទសំណួររបស់លោកមេធាវី កូប៉េ ហើយនិងដោយលោកចៅក្រម ឡាវែន៍ តែប៉ុណ្ណោះទេ ក៏ប៉ុន្តែខ្ញុំទំនងជាមានពេល -- ត្រូវការពេលវេលាតែមួយវគ្គទេ ហើយបើថែមពេលវេលាវិញ ក៏មិនជាច្រើនប៉ុន្មានដែរ លោកប្រធាន ខ្ញុំនឹងព្យាយាមសួរអាស្រ័យទៅតាមពេលវេលាដែលនៅសេសសល់សម្រាប់ពួកខ្ញុំ។

[១៥:៥៦:៤២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ សូមអរគុណលោកប្រធាន។ បាទ ខ្ញុំសូមចោទសំណួរមួយចំនួន<ទៅ>សាក្សីទាក់ទងទៅនឹងអ្វីដែលគាត់បាននិយាយកាលពីព្រឹកមិញទាក់ទងទៅនឹងលោក កេត ដារ៉ា ដែលជាលោកស័ក្តិ៥ ដែល<>សាក្សីនេះទទួលបន្ទុកខាងកប់សាកសពគាត់។ លោកសាក្សី លោកមានចាំអំពីអ្វីដែលលោកនិយាយអំពីលោកស័ក្តិ៥ កេត ដារ៉ា ដែរឬទេ? ហើយលោកមានចាំដែរឬទេថាមានគេប្រាប់លោកថាលោក កេត ដារ៉ា នេះជាប្រធានចលនា ម៉ូណាស្សូ ឬចលនាជាតិមួយដែរឬទេ?

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ ពេលនោះ ខ្ញុំអត់បានដឹងពីចលនាអីៗទេ ព្រោះខ្ញុំបានដឹងពីកងដូចគ្នាហ្នឹងថាពួក កេត ដារ៉ា ហ្នឹងនៅកន្លែងពេទ្យចិន លួចបាញ់កងទ័ពស្លាប់អស់ពីរបីនាក់ឯណោះ ទម្រាំតែព័ទ្ធចាប់បាន។ ទាល់តែអត់អាហារ បានចូលចាប់បាន។ ដល់អ៊ីចឹងយកមកដាក់នៅសាលាដំបូងតាខ្មៅ ហើយក៏បានដឹកយកតាមឡាន សេ.អឹម.សេ ហ្នឹងពីរឡាន ទាំងប្រពន្ធកូន ហើយនិងបក្សពួកហ្នឹងចំនួនប្រហែលជា៥០នាក់ចុះអីហ្នឹង វាក្នុងឡានមួយៗវាមិនពេញណែនទេ យកទៅហ្នឹង ប៉ុន្តែមិនដឹងជាលោកស័ក្តិ៥ កេត ដារ៉ា ហ្នឹងគាត់ជាចលនាអីទេ គ្រាន់តែដឹងថាគាត់ជាស័ក្តិ៥។

**ស៖** ក៏ប៉ុន្តែនៅក្នុងសំណុំរឿង ហើយនិងនៅក្នុងសាលក្រមរបស់យើងៗយោងទៅឈ្មោះហែម កេត ដារ៉ា ដែលគាត់មានតួនាទីពេលខ្លីទេនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដែលជាប្រធានចលនាម៉ូណាស្សូ។ មានសរសេរពីឈ្មោះ ហែម កេត ដារ៉ា នេះដែរនៅក្នុងអត្ថបទកាសែត <> អា.អេហ្វ.ប៉េ <របស់>អ្នកនិពន្ធហ្សង់ហ្សាកកាហ្សូ ឯកសារE3/3365។ <ហើយ>ឈ្មោះ <ហែម> កេត ដារ៉ា នេះ<ក៏មានសរសេរ>ផងដែរ <>នៅក្នុង<កំណត់ហេតុ>របស់ សេនប៊ឹក ស៊ីដនី <> គឺឯកសារ E3/9749 ហើយឯកសារនេះលេខ ERN មានដូចតទៅ គឺជាភាសាបារាំង 00955412 ទៅដល់ 5414 ។ នៅក្នុងកំណត់ត្រារបស់ សេនប៊ឹក នេះ ឬក៏អត្ថបទរបស់កាហ្សូ នោះមានលើកឡើងថា ហែម កេតដារ៉ា នេះរៀបការមានប្រពន្ធបារាំង គាត់មានកូនពីរនាក់ ហើយគាត់បានកោះហៅអ្នកកាសែត មកមុខក្រសួងព័ត៌មាននៅថ្ងៃទី១៧ មេសា ឆ្នាំ<១៩៧៥> ហើយ<>គាត់បានលើកបង្ហាញកាំភ្លើង *រ៉ឺវ៉ុលវែរ* កាំភ្លើងខ្លីរបស់គាត់ដើម្បីបញ្ជា។ ហើយយើងឃើញមានរូបថត ហែម កេត ដារ៉ា នេះ។ អ៊ីចឹងខ្ញុំចង់បង្ហាញរូបថតនេះ ទៅសាក្សីរូបនេះ ដើម្បីសួរគាត់ថាតើគាត់ស្គាល់រូបថតដែលមាននៅលើរូបថតមួយសន្លឹកនេះដែរឬក៏អត់ ហើយសូមផ្តល់ទៅដល់ភាគីផងដែរលោកប្រធាន។

[១៦:០០:៣៨]

**ប្រធានអង្គជំនុំ៖**

បាទមន្ត្រីរដ្ឋបាលតុលាការ ចាត់ចែងតាមការស្នើសុំរបស់លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំសូមបញ្ជាក់ផងដែរថា រូបថតនេះ មាននៅក្នុងខ្សែវីដេអូមួយនៃឯកសារយើង គឺឯកសារ E3/3939R នៅនាទី០២:០៥ សីហ្គុង ហើយក៏មានបោះពុម្ពផ្សាយនៅក្នុងអត្ថបទមួយនៅក្នុងទស្សនាវដ្តីញ៉ូវរ៉ឹក នៅថ្ងៃទី១៩ ឧសភា ឆ្នាំ១៩៧៥ ហើយនិងអត្ថបទមួយទៀត ឈ្មោះ *ខេមបូឌា ញូវ ហ្វ៊ីខេសិន*។ គឺឯកសារ <E190.1.307>, ERN ជាភាសាអង់គ្លេស <00445259>។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ប្រហែលជាមានការលំបាកក្នុងការកំណត់អត្តសញ្ញាណរបស់គាត់ហើយ ព្រោះលោកបានឃើញតែសាកសពគាត់នៅពេលនោះ ក៏ប៉ុន្តែ<តើ>រូបថត<របស់>គាត់<នេះ -- គឺ>រូប<>មនុស្សម្នាក់ដែលកាន់កាំភ្លើងខ្លីហើយស្រែក តើលោកធ្លាប់ឃើញរូបថតនេះដែរឬទេ ឃើញរូបនេះដែរឬទេ? ហើយរូបដែលមាននៅលើរូបថតនេះ ធ្វើឲ្យលោកនឹកឃើញដល់រូបអ្នកណាមួយដែលលោកធ្លាប់ស្គាល់ទេ?

[១៦:០២:២១]

**លោក ប្រាក់ ខន៖**

**ឆ៖** បាទ ខ្ញុំមិនច្បាស់ដែរ ព្រោះវាយូរពេកហើយ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធានសូមអរគុណ លោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

នេះគឺសម្រាប់មេធាវីការពារក្ដីពាក់ព័ន្ធទៅនឹងការអនុញ្ញាតផ្ដល់ពេលវេលាទៅដល់មេធាវីការពារក្ដីទាំងពីរក្រុមនៅថ្ងៃចន្ទ។ <>តើទាំងពីរក្រុមនេះ ត្រូវការពេលវេលាប៉ុន្មាន?

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនពូកែគណនាទេ លោកស្រីចៅក្រម ខ្ញុំបានជម្រាបជូនអម្បាញ់មិញ ថាខ្ញុំត្រូវការរយៈពេលមួយវគ្គ ហើយខ្ញុំទុក<>វេទិកាឲ្យលោកមេធាវី កូប៉េ ឆ្លើយថាគាត់ត្រូវការប៉ុន្មាន។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសង្ឃឹមថា គឺថាត្រូវការតែមួយវគ្គ លោកស្រីចៅក្រម។ <>

**<ចៅក្រម ក្លូឌា ហ្វេនស៍៖>**

អ៊ីចឹង មួយវគ្គមួយក្រុមៗ មួយព្រឹកសម្រាប់ថ្ងៃចន្ទគ្រប់ហើយ?

**<លោក វ៉ិចទ័រ កូប៉េ៖>**

<ត្រឹមត្រូវហើយ។>

**<ចៅក្រម ក្លូឌា ហ្វេនស៍៖>**

<អ៊ីចឹងសម្រេចនៅថ្ងៃចន្ទ។>

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

ខ្ញុំគ្រាន់តែបញ្ជាក់បំភ្លឺអំពីការគណនាពេលវេលាឡើងវិញ។ ខ្ញុំសោកស្ដាយដែលខ្ញុំគណនាខុសអម្បាញ់មិញដើម្បីឲ្យស្មោះត្រង់ទាំងអស់គ្នាបើសិនជាភាគីខាងការពារក្ដីនេះ គាត់ប្រើពេលដល់ម៉ោងដប់មួយថ្ងៃចន្ទនោះ គឺជាការត្រឹមត្រូវហើយ គឺស្មើនឹងពេលវេលាដែលយើងបានប្រើប្រាស់ដែរលោកប្រធាន។ <បើពួកគេត្រូវការពេលវេលាច្រើនជាងនោះ គេត្រូវតែធ្វើសំណើសុំបន្ថែមទៀត។>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ យើងនឹងបញ្ជាក់បន្ថែមនៅព្រឹកថ្ងៃចន្ទ ប្រហែលជាការគណនារបស់សហព្រះរាជអាជ្ញារងអន្តរជាតិសមស្របនឹងអ្វីដែលយើងបានគណនារួចហើយ ហើយដោយសារមានបញ្ហាបន្តិចបន្តួចដែរនៅព្រឹកមិញនេះ -- នៅល្ងាចមិញនេះ អ៊ីចឹងហើយបានជាអាចគ្រប់សមស្របរហូតដល់ម៉ោងដប់ ដប់មួយនោះ។ ប៉ុន្តែយើងនឹងបញ្ជាក់បន្ថែមឲ្យបានច្បាស់លាស់ ពីព្រោះយើងនឹងគ្រប់ពេលវេលាកំណត់នូវការគ្រប់គ្រងពេលវេលាសម្រាប់ភាគីក្នុងការតាំងសំណួរដេញដោលឲ្យបានសមស្រប ហើយនិងវាប្រហាក់ប្រហែលគ្នា យើងមិនដល់អាចគ្រប់គ្រងពេលវេលាហ្នឹង ឲ្យវាជាក់លាក់រហូតដល់សឺហ្គុងដល់មីនុតនោះទេ។

សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អែកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី០២ ខែឧសភា ឆ្នាំ២០១៦ ហើយសវនាការនៅថ្ងៃចន្ទនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ប្រាក់ ខន បញ្ចប់ ហើយនិងផ្តើមសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-808 សូមភាគីជ្រាប និងអញ្ជើញចូល--

[១៦:០៥:៥៨]

**លោក វ៉ិចទ័រ កូប៉េ៖**

តាមការបកប្រែ ខ្ញុំឮសួរពាក្យថា ថ្ងៃអង្គារ លោកប្រធាន។ ប៉ុន្តែអ្វីដែលនិយាយគ្នាអម្បាញ់មិញគឺថ្ងៃចន្ទទេ។

**ប្រធានអង្គជំនុំ៖**

ខ្ញុំនិយាយនេះគឺច្បាស់លាស់ហើយ ថ្ងៃចន្ទ ហើយថ្ងៃចន្ទនេះគឺច្បាស់លាស់ ព្រោះខ្ញុំអាននូវសំណេររបស់ខ្ញុំ។ ខ្ញុំអានទេនេះ ខ្ញុំអានណា៎ ខ្ញុំអានឯកសារ ខ្ញុំអត់ប៉ាននធ្វើអ្វីផ្តេសផ្តាសទេ ឥឡូវនេះ។ ឆ្នាំនេះ ខ្ញុំគ្រប់គ្រងតាំងពីដើមទី គឺខ្ញុំសរសេរឯកសាររហូត។

អ៊ីចឹង សាម្តងទៀត។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី០២ ខែឧសភា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃចន្ទ ដើមសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ប្រាក់ ខន បញ្ចប់ ហើយនិងផ្តើមសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-808។

ហើយអង្គជំនុំជម្រះសូមអរគុណលោកសាក្សី ការស្ដាប់សក្ខីកម្មរបស់លោក ក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ។ ហើយអង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តសក្ខីកម្មនៅថ្ងៃចន្ទ ទី០២ ខែឧសភា ឆ្នាំ២០១៦ ដើមសប្ដាហ៍ក្រោយនេះ ថែមទៀត។ ហើយអង្គជំនុំជម្រះក៏សូមអរគុណ លោក ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សី អង្គជំនុំជម្រះអញ្ជើញលោកមកចូលរួមប្រឹក្សាសាក្សីរូបនេះ នៅថ្ងៃចន្ទ ដើមសប្ដាហ៍ក្រោយទៀត។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីរ លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃចន្ទ ទី០២ ខែឧសភា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៧ នាទី)*